ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jan-2012, 09:08
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការ សវនាការផ្ទាល់មាត់លើឯកសារនានា

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី១៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាវស្ទី

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វេង ហ៊ាត់

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោកស្រី សារ៉ាស អេនឌ្រូ
*(Ms. Sarah ANDREWS)*

**ជនជាប់ចោទ៖**

លោក ខៀវ សំផន

លោក នួន ជា

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

លោក ហ្សាស្ពើ ប៉ៅ

*(Mr. Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គីមសួន

លោកស្រី ស៊ីន សុវ៉ន

លោក វ៉ែន ពៅ

លោក សំ សុគង់

លោកស្រី ទី ស្រ៊ីនណា

លោក ឡៅ ជុនធី

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ *(Ms.Phillipine SUTZ)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ច័ន្ទ តារាស្មី | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក បាណាបេ ណោគ្នី | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្សុី | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៥៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តបើកសវនាការ។ កាលពីរសៀលម្សិលមិញ មុនពេលបញ្ចប់អង្គជំនុំជម្រះបានជម្រាបជូនរួចហើយ តាមកាលវិភាគនៃកិច្ចដំណើរការសវនាការ ដែលកាលពីម្សិលមិញយើងធ្វើមិនទាន់ចប់នៅឡើយ គឺឥឡូវនេះដល់នាទីសហព្រះរាជអាជ្ញាក្នុងការធ្វើការឆ្លើយតបទៅនឹងការជំទាស់របស់មេធាវីទាំងបីក្រុម។

ដូច្នេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅភាគីសហព្រះរាជអាជ្ញា ដោយសហព្រះរាជអាជ្ញាមានរយៈពេលមួយម៉ោងដើម្បីធ្វើការឆ្លើយតបចំពោះការទំទាស់របស់មេធាវីទាំងបីក្រុម។ សូមអញ្ជើញ!

[០៩:០៤:២៥]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ លោក លោកស្រីចៅក្រម និងមេធាវី និងសាធារណជន លោកលោកស្រីចៅក្រម ដូចដែលយើងខ្ញុំបានបញ្ជាក់ពីម្សិលមិញ ថ្ងៃនេះខ្ញុំនឹងលើកឡើងអំពីបញ្ហាជាទូទៅជាការជំទាស់ជាទូទៅរបស់សហព្រះរាជអាជ្ញា ទៅលើការជំទាស់របស់មេធាវីការពារក្តីទៅលើភាពអាចទទួលបាននៃឯកសារ។ បន្ទាប់មក សហសេវិករបស់ខ្ញុំ លោក តាភារស្មី នឹងពិនិត្យមើលឯកសារជាក់លាក់ និងផ្តល់ឧទាហរណ៍មួយចំនួន ថាតើឯកសារទាំងនេះអាចទុកចិត្តបានប៉ុនណា ដែលយើងនឹងបង្ហាញនៅក្នុងឯកសារទាំងនោះ។ និយាយដោយសង្ខេបពីម្សិលមិញនោះ មេធាវីការពាក្តី ហើយនិងសហព្រះអាជអាជ្ញា យើងមានការព្រមព្រៀងជាទូទៅទៅលើតេស្តជាទូទៅ ដែលថាឯកសារត្រូវតែមានភាពពាក់ព័ន្ធក្នុងការមើលមួយក្រឡេកនៃផ្នែកចៅក្រម។ ដូច្នេះ យើងពិនិត្យមើលភាពអាចទទួលយកបានភាពខុសគ្នានោះគឺវាអាស្រ័យ ថាតើតេស្តហ្នឹងយើងយកមកប្រើក្នុងកម្រិតណាបែបណា។ អ៊ីចឹង ផ្អែកលើមូលហេតុ មូលដ្ឋានអំពីវិធី ដែលយើងយកតេស្តនេះមកវាស់វែង ពិនិត្យមើល។

[០៩:០៥:៤៩]

ជាបឋម ខ្ញុំសុំអនុញ្ញាតដើម្បីលើកឡើងនូវចំណុចបួន ទាក់ទងទៅនឹងការឆ្លើយតបជាទូទៅទាក់ទង

ទៅនឹងការជំទាស់ទាំងបួនយ៉ាងដែលលើកឡើងដោយមេធាវីការពារក្តីលើឯកសារនោះ។ ប៉ុន្តែ ខ្ញុំ យើងនឹងបញ្ជាក់ពីចំណុចបឋមទាក់ទង ថាតើជនជាប់ចោទម្នាក់ៗ ដែលថាមេធាវីការពារក្តីបានលើកឡើងអំពីបញ្ហាទាក់ទងនឹងភាពទទួលយកបាននេះ។ ដូច្នេះ វិធីសាស្ត្រនេះត្រូវបានលើកឡើងដោយមេធាវីការពារក្តី មិនមែនស្របទាំងស្រុងទៅនឹងការអនុវត្ត ឬក៏ទម្លាប់អនុវត្តនៃនីតិវិធីដែលយើងបានព្រមព្រៀងនោះទេ។

[០៩:០៦:៣២]

ជាបឋម ទាក់ទងទៅនឹងមេធាវីរបស់លោក ខៀវ សំផន។ មេធាវីរបស់គាត់បានលើកឡើងនូវកាតព្វកិច្ចជូនតុលាការថា សហព្រះរាជអាជ្ញាមានបន្ទុក មានការទទួលខុសត្រូវក្នុងការបង្ហាញភស្តុតាងឲ្យហួសពីវិមតិសង្ស័យ នេះជាការពិតហើយ គឺជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា។ នេះគឺជាបន្ទុកក្នុងការផ្តល់ភស្តុតាង គឺកម្រិតខ្ពស់ណាស់ខាងសហព្រះរាជអាជ្ញានោះ។ ក៏ប៉ុន្តែមេធាវីរបស់លោក ខៀវ សំផន ក្រុមរបស់គាត់នោះបានព្យាយាមធ្វើឲ្យមានសមតុល្យរវាងបន្ទុកនៃការបង្ហាញភស្តុតាង និងបន្ទុកថា បន្ទុករបស់ខ្លួនក្នុងការបង្ហាញ ដែលថា លោកលើកឡើងពីច្បាប់ដែលបានបញ្ជាក់កាលពីម្សិលមិញនោះគឺថា មានកត់ត្រានៅក្នុងទឡ្ហីករណ៍របស់គាត់។ ប៉ុន្តែ បញ្ហានោះមិនមែនជាករណីនៅទីនេះទេពីព្រោះថាការទទួលយកបាននៃឯកសារ គឺច្បាប់អនុញ្ញាតឲ្យតុលាការយកភស្តុតាងដែលហៅថា ភស្តុតាងពិនិត្យមួយ-- ពិនិត្យបឋម គេហៅថា *"ព្រីម៉ា ហ្វេស៊ី អេវីឌិន"* ហ្នឹង យកមកដាក់ដេញដោល ហើយយើងត្រូវមានសវនាការដេញដោលនៅក្នុងដំណាក់កាលហ្នឹង ហើយដំណាក់កាលហ្នឹងចេះតែបន្តទៅ ហើយដើម្បីការការពារដល់ជនជាប់ចោទនោះគឺថា អង្គហេតុសំខាន់ៗនៅក្នុងដីកាបញ្ជូនមកជំនុំជម្រះនោះ គឺថាត្រូវព្រះរាជអាជ្ញាបង្ហាញឲ្យហួសពីវិមតិសង្ស័យ។

[០៩:០៨:០៦]

ដូច្នេះហើយ ជារូបភាពទាំងមូលជាវិសាលភាពទាំងមូលនៃភស្តុតាងដែលតុលាការនឹងត្រូវសម្រេចថាតើផ្នែកណាមួយ ថាតើការចោទប្រកាន់សំខាន់ណាមួយដែលកំណត់បង្ហាញនូវអង្គហេតុឲ្យតុលាការជឿហួសពីវិមតិសង្ស័យនោះ។ បើយើងពិនិត្យមើលកំណត់អត្រា ឬបទដ្ឋានដ៏ខ្ពង់ខ្ពស់ក្នុងការទទួលយកបាននៃឯកសារនេះ គឺថា យើងត្រូវតែពិនិត្យមើលឯកសារ ពីព្រោះថា ការដែលសួរដេញដោលទៅម្ចាស់អ្នកផលិតឯកសារនោះគឺជាលក្ខខណ្ឌមួយ។ ប៉ុន្តែ យើងត្រូវប្រើតែស្តង់ដែលថាវាមានស្តង់ដារទាបជាង

ហ្នឹងក្នុងមូលដ្ឋាននៃសវនាការនេះ។

[០៩:០៨:៤៩]

ក្នុងករណីមេធាវីរបស់ នួន ជា យើងក៏មានការព្រមព្រៀងជាទូទៅលើការប្រើតេស្តដើម្បីវាស់វែងនេះ។ អង្គជំនុំជម្រះក៏បានពិនិត្យមើលការអនុវត្តជាអន្តរជាតិ ជាពិសេសសាលាក្តីអន្តរជាតិផ្សេងៗទៀតដែលមានរឿងក្តីប្រហាក់ប្រហែលនេះ និងមើលវិធីសាស្ត្រដែលតុលាការនោះទទួលយកនូវភស្តុតាង។ ប៉ុន្តែមេធាវីរបស់លោក នួន ជា និយាយថា វិធីសាស្ត្ររបស់សាលាក្តីផ្សេងៗទៀតប្រហែលជាវិធីសាស្ត្រដែលមានសេរីភាពច្រើនជាងវិធីសាស្ត្រតុលាការជាតិ ដូចជាតុលាការកម្ពុជាផ្សេងទៀតនោះ ឬតុលាការផ្សេងទៀតនោះ។ ដូច្នេះតាមពិត ក្នុងករណីនេះ គឺជាករណីធំ រឿងក្តីធំ ដែលលោក លោក ស្រីចៅក្រមត្រូវអនុវត្តនូវវិធីសាស្ត្រមួយដែលរឹងមាំទាក់ទងនឹងភាពទទួលយកបាននៃភស្តុតាង។

ប៉ុន្តែ យើងមិនពិនិត្យឃើញថា រូបភាពទាំងមូលនៃបណ្តុំនៃភស្តុតាងនោះទេ។ ដូច្នេះហើយចៅក្រមបានពិចារណា ត្រូវពិចារណាមើលអំពីបទឧក្រិដ្ឋដែលមានទ្រង់ទ្រាយធំទូទាំងប្រទេសកម្ពុជា។ យើងមិនអាចពិនិត្យមើលតែចំណុចនីមួយៗ ដែលមេធាវីលើកឡើងបានទេ អំពីការកាន់កាប់ត្រួតត្រាផ្ទេរឯកសារ...។ល។ ហ្នឹង ក៏ប៉ុន្តែចៅក្រមអាចនឹងពិនិត្យ និងយល់នូវឯកសារទាំងអស់នោះ អាចនឹងធ្វើសេចក្តីសម្រេចនូវអង្គហេតុមួយក្រុមណា មួយចំនួនណា ដែលជ្រើសរើស ដែលថាវាមានការទាក់ទង។ បើផ្នែកណាមួយដែលមិនពាក់ព័ន្ធ អាចនឹងដកចេញពីភស្តុតាងដែលជាបង្អែកនៃសេចក្តីសម្រេច ក៏ប៉ុន្តែគាត់បានយល់ស្របទៅលើនឹងតេស្តផ្លូវច្បាប់មួយ ហើយក៏បានសុំឲ្យតុលាការដាកចេញពីទម្លាប់អនុវត្តអន្តរជាតិ ដោយហេតុថា តុលាការអន្តរជាតិបានធ្វើការក្នុងរឿងក្តីផ្សេងៗ ក្នុងរបៀបមួយដែលថាគេប្រើវិធីសាស្ត្រមួយបែបសេរីទូលំទូលាយជាង។

[០៩:១០:៥៥]

ការដែលបញ្ជាក់បែបនេះ គឺថាយើងយល់ស្របជាមួយមេធាវីលោក នួន ជា ថាយើងថាតុលាការនេះត្រូវអនុវត្តនូវគោលការណ៍ជាមូលដ្ឋាន ដែលតុលាការជាតិកម្ពុជាក៏បានប្រើ ហើយច្បាប់ក៏តម្រូវឲ្យប្រើ។ ក៏ប៉ុន្តែតុលាការនេះ ក៏ត្រូវបង្កើតជាឧទាហរណ៍ ជាគំរូក្នុងការអនុវត្តនូវសវនាការដ៏មានប្រសិទ្ធ-ភាព មានយុត្តិធម៌ ផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណី ហើយធ្វើឲ្យប្រាកដថា យើងមើលភស្តុតាងទាំងអស់ដែលមាន ហើយយើងនឹងទទួលយកនូវគោលការណ៍ទាំងអស់នោះ ដែលដូចគ្នានឹងគោលការណ៍របស់តុលាការជាតិនោះដែរ ហើយក៏ជាការណែនាំទៅដល់តុលាការជាតិ ជាគំរូមួយសម្រាប់ការវិវត្តន៍នៃសវនាការទៅអនាគត។ ប៉ុន្តែបើនិយាយអំពីលក្ខណៈបច្ចេកទេសនៃការទទួលយកនូវភស្តុតាង យើង

មើលនូវស្តង់ដារអន្តរជាតិមួយចំនួន ដែលបានប្រើរួចមកហើយ ហើយតុលាការនេះគឺបានផ្អែកទៅលើអ្វីដែលមានស្រាប់ ហើយជាពិសេសដោយសារទំហំរឿងក្តីនេះវាមានភាពធំផង។

[០៩:១២:០៨]

ជាថ្មីម្តងទៀត មេធាវីរបស់លោក អៀង សារី ក៏បានបង្ហាញលើការប្រើតេស្តដើម្បីភាពទទួលយកបាននូវភស្តុតាងនេះដែរ។ ហើយយើងត្រូវពិនិត្យឲ្យបានលម្អិត ជាពិសេសគឺថាឯកសារមួយចំនួនវាមានលក្ខណៈជាកម្រិតបណ្ឌិតសភា ក៏ប៉ុន្តែអាចនឹងយកមកប្រើនៅតុលាការនេះបាន ឬតុលាការផ្សេងក៏បានដែរ។ មេធាវីរបស់លោក អៀង សារី ហ្នឹងបានលើកឡើងថា ភាពអាចទទួលយកបាន ការធ្វើតេស្តនោះក៏ត្រូវតែៗពិនិត្យមើលយថាភាពនៃឯកសារ។

បើសិនជាមានយថាភាព ហើយយើងត្រូវបន្តទៅមើលភាពអាចទទួលយកបាន-- ភាពអាចជឿជាក់បាននោះទៀត។ ហើយបន្ទាប់មកនឹងមើលភាពពាក់ព័ន្ធ ដែលក្រៅពីអង្គហេតុ ដែលយើងបានយល់ស្របគ្នាថាមេធាវីការពាររបស់ អៀង សារី នោះគឺថាធាតុទាំងអស់នោះ គឺជាធាតុផ្សំនៃតេស្តដែលយើងត្រូវវាស់វែង។ ប៉ុន្តែពីម្សិលមិញ គឺថាយុត្តិសាស្ត្រអន្តរជាតិបានបង្ហាញថា យថាភាព តាមពិតនោះ គឺជាធាតុផ្សំនៃភាពអាចជឿជាក់បាននៃភស្តុតាង។ ដូច្នេះហើយតុលាការទេ ជាអ្នកវិភាគក្នុងករណីនេះ។

[០៩:១៣:២០]

ដូច្នេះ គំនិតដែលតុលាការនឹងត្រូវពិនិត្យមើលភាពយថាភាពនោះ វាជាកត្តាមួយ ជាធាតុផ្សំមួយដែលវាអាចនាំ បើយើងមើលកត្តានេះមុន វាអាចនាំឲ្យដំណើរការនីតិវិធីវែង ប្រសិនបើយើងមើលឃើញថា មិនពាក់ព័ន្ធពីដំបូងទេ គឺថាយើងនឹងត្រូវប្រើពេលច្រើនមុននឹងយើងឈានទៅដល់យថាភាពនោះ។

អ៊ីចឹងគឺថាតុលាការ ឬលោក លោកស្រីចៅក្រមនឹងប្រើនូវវិធីសាស្ត្រមួយ ដែលថាអាចនឹងឆ្លើយតបទៅនឹងរឿងក្តីធំបែបនេះ ដូចជារឿងក្តី០០១ ពីឆ្នាំទៅហ្នឹង ហើយក៏យើង-- តុលាការក៏បានចេញសេចក្តីសម្រេចមួយចំនួនកំណត់នូវវិធីសាស្ត្រដែលថាភាពពាក់ព័ន្ធនៃភស្តុតាង ឯកសារភស្តុតាងហ្នឹងគឺត្រូវបានសម្រេចទៅតាមវិធីមួយ ហើយតេស្តហ្នឹងក៏បានប្រើរួចមកហើយដែរ។

[០៩:១៤:១២]

ចំពោះការជំទាស់ទាំងបួន ជាការឆ្លើយតបទៅនឹងការបដិសេធលើឯកសារភស្តុតាង ដោយមេធាវីការពារក្តីទាំងបួននោះ។ ហើយពួកគាត់ក៏បានលើកចំណុចបួនសំខាន់ៗ គឺថាភាគច្រើននៃឯកសារទាំងអស់នេះ ដែលមាននៅក្នុងដីកាដំណោះស្រាយនោះ គឺមិនទាន់ត្រូវបានទទួលស្គាល់ជាបានការទេ។

ហើយមេធាវីការពារក្ដីបានលើកឡើងថា ជនជាប់ចោទ គឺថាមានសិទ្ធិក្នុងការកោះហៅអ្នកនិពន្ធ អ្នកធ្វើឯកសារទាំងអស់នោះ ដើម្បីមកដេញដោលទៅតាមវិធាន៨៤(១) នៃវិធានផ្ទៃក្នុង។

វិធាន៨៤ កថាខណ្ឌមួយ នេះគឺថាសិទ្ធិរបស់មេធាវីការពារក្ដីក្នុងការកោះហៅសាក្សីណាមួយដែលគាត់មិនមានឱកាសក្នុងការដេញដោល ក្នុងការសួរ នៅក្នុងស៊ើបអង្កេតនោះទេ។

យើងសូមស្នើថាការបកស្រាយនូវវិធាននោះ គឺថាវាទាក់ទងទៅនឹងសាក្សីដែលផ្ដល់នូវចម្លើយឬក៏ផ្ដល់ជាកំណត់ត្រាជូនសហចៅក្រមស៊ើបអង្កេត ក៏ប៉ុន្តែមិនអនុវត្តនៅចំពោះឯកសារប្រភេទផ្សេងទេ ដូចជាសេចក្ដីថ្លែងការណ៍ព័ត៌មាន សៀវភៅ ឬក៏អត្ថបទរបស់ពួកបញ្ញវន្ត អ្នកប្រាជ្ញជាដើមនោះ គឺមិនយកមកអនុវត្តទេ។ ពីព្រោះនៅក្នុងតុលាការអន្តរជាតិ នៅពេលដែលគេអនុវត្តនូវវិធានភស្តុតាងចំពោះរឿងក្ដីដែលធំបែបនេះនោះ ជាជាងការកោះអ្នកនិពន្ធឲ្យមកនោះ ពួកគេអនុញ្ញាតឲ្យគេប្រើភស្តុតាងមួយចំនួនដែលគេហៅថាភស្តុតាងតាមពាក្យចចាមអារ៉ាម ហើយគេកត់ត្រាតាមក្រឹត្យក្រមត្រឹមត្រូវ ហើយឲ្យចៅក្រមពិនិត្យពិចារណា គេអនុញ្ញាតឲ្យប្រើអត្ថបទសារព័ត៌មានដែលចុះផ្សាយនៅក្នុងរយៈពេលនៃការកើតហេតុនោះ ហើយឲ្យប្រើថាជាភស្តុតាងបឋមដើម្បីដាក់ចូលក្នុងសំណុំរឿង គេអនុញ្ញាតឲ្យប្រើសៀវភៅ ហើយនិងអត្ថបទរបស់អ្នកប្រាជ្ញផ្សេងៗនោះ។

[០៩:១៦:២០]

ការដែលគេអនុញ្ញាតបែបនេះពីព្រោះថារបាយការណ៍សៀវភៅ ផ្ដល់ទាំងនោះ គឺផ្ដល់ឲ្យតុលាការនូវការណែនាំ ហើយនិងជាការណែនាំដ៏គ្រប់គ្រាន់ទាក់ទងទៅបរិបទប្រវត្តិមូលដ្ឋាន អំពីគោលនយោបាយទូទៅ ហើយនិងប្រវត្តិមូលដ្ឋានដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងមកជំនុំជម្រះ។

កិច្ចប្រឹងប្រែងនេះ គឺថាត្រូវដាក់បញ្ចូលនូវភស្តុតាងនៅក្នុងទម្រង់មួយដែលថាវាមានលក្ខណៈធំធេង ហើយវាក៏មានតម្លៃ។ បាទ ជាលទ្ធផលពីការងារនេះ នោះគឺថាតុលាការបានអនុញ្ញាតឲ្យឯកសារទាំងអស់នេះដាក់ចូលនៅក្នុងសំណុំរឿង ជាការលើកលែងទៅនឹងសិទ្ធិក្នុងការសាកសួរសាក្សីនីមួយៗ ពីព្រោះថាឯកសារទាំងអស់នេះ គឺវាមានតម្លៃដែលអនុញ្ញាតឲ្យចៅក្រមអាចពិនិត្យនូវបរិបទ និងខ្លឹមសារ ថាតើភស្តុតាងណាមួយដែលយើងត្រូវយកមកដេញដោលនៅក្នុងសវនាការផ្ទាល់មាត់ ថាតើឯកសារ ភស្តុតាងឯកសារណាមួយដែលអាចនឹងដាក់ចូលយកជាបានការនោះ?

[០៩:១៧:២៥]

តាមធម្មតាឯកសារប្រភេទនេះ គេប្រើជាភស្តុតាងស៊ីសង្វាក់ មិនចាត់ទុកថាជាភស្តុតាងមូលដ្ឋាន

ដូចជាសក្ខីកម្មផ្ទាល់ ដូចជាឯកសារដែលមានបច្ចុប្បន្នភាពនៅក្នុងរយៈកាលនៃបទឧក្រិដ្ឋនោះទេ។

ដូច្នេះរឿងក្ដីនេះ គឺយើងប្រើភស្ដុតាងទាំងនោះដើម្បីគាំទ្រ ហើយយើងក៏ស្នើសុំឱ្យតុលាការគោរពទៅតាមស្ដង់ដារអន្តរជាតិ។ បើមិនដូច្នោះទេ អ្វីដែលវានឹងកើតឡើងនោះ គឺថាអាចនឹងមានឱកាសក្នុងការពិនិត្យថាតើភស្ដុតាងដែលគេហៅថា *ម៉ាទ្រីស* វាទំនាក់នោះ វាទាក់ទងតាមរបៀបណា។ តុលាការជាតិក៏ត្រូវពិនិត្យមើលភស្ដុតាងបែបនេះ គឺគាត់ពិនិត្យមើលទម្ងន់នៃភស្ដុតាង មិនមែនទៅលើតម្លៃនៃភស្ដុតាង ដោយថាជនជាប់ចោទគាត់ធ្វើសេចក្ដីថ្លែងការណ៍ ឬក៏កំណត់ហេតុហាសិបនៅពេលនោះហើយមានចម្លើយផ្សេងៗទៀត វាមានលក្ខណៈប្រភេទស្រដៀងគ្នា ដូចជាគោលការណ៍ ឬក៏នយោបាយទូទៅ ហើយដែលមានចុះផ្សេងនៅក្នុងអត្ថបទសារព័ត៌មាន ហើយនិងអត្ថបទផ្សេងៗ។

ដូច្នេះហើយតុលាការក៏ត្រូវពិនិត្យមើលខ្លឹមសារដើម្បីអនុវត្តតេស្ដថា តើទម្ងន់នូវព័ត៌មានទាំងនោះវាអាចជឿជាក់ ឬក៏ទុកចិត្តបានប៉ុនណា ហើយតុលាការក៏គប្បីអនុវត្តគោរពទៅតាមយុត្តិសាស្ត្រអន្តរជាតិដែលអនុញ្ញាតឱ្យវិធីសាស្ត្រដែលតុលាការយល់ថាអាចមើលភស្ដុតាងទាំងអស់ដែលមាន ដោយមិនគ្រាន់ថាត្រូវកោះហៅសាក្សីជាចាំបាច់ ដើម្បីមកបង្ហាញនៅគ្រប់ភស្ដុតាងនោះទេ។

[០៩:១៩:០៨]

ចំណុចទីពីរ មេធាវីការពារបានជំទាស់ទៅលើឯកសារ ទោះបីជាមានប្រតិចារឹកច្បាប់ដើម ឬក៏ជាកាសែ្សតថតនោះក៏ដោយ ក៏ត្រូវតែមានអ្នកនិពន្ធមកបញ្ជាក់ដែរ ទោះបីជាឯកសារនៅក្នុងសំណុំរឿងហ្នឹងមានហើយក៏ដោយ។ ដូច្នេះក្នុងករណីនេះ យើងខ្ញុំសូមជម្រាបតុលាការថា ការដែលទាមទារឱ្យមានម្ចាស់អត្ថបទសារព័ត៌មានដែលបោះពុម្ពផ្សាយនៅឆ្នាំ១៩៧៥ ដល់៧៩ នោះ ហើយបើយើងទាមទារឱ្យមានឯកសារច្បាប់ដើមនៃកំណត់ដៃមុនដែលគាត់ចុះផ្សាយនោះ អានេះគឺថាជាការកោះអញ្ជើញ ឬក៏ជាបន្ទុកមួយដ៏ធ្ងន់ដែលយើងពិបាកធ្វើ ត្រូវចំណាយពេល។

ដូច្នេះតុលាការនឹងត្រូវពិនិត្យមើល ថាតើភស្ដុតាងណា? ឯកសារណា? វាស័ក្ដិសម វាត្រឹម ត្រូវទៅតាមរឿងក្ដីណាមួយដែលវាសមស្រប ហើយបើសិនជាមានហេតុការណ៍ខាងក្រៅ ដែលសារព័ត៌មានវាស៊ីសង្វាក់នោះ គឺតុលាការគប្បីតែពិនិត្យ ហើយយកមកប្រើ ដើម្បីកំណត់ថា តើភាពជឿជាក់បានអប្បបរមា នោះត្រឹមណា?

[០៩:២០:២៧]

រីឯការទាមទារឱ្យមានកំណត់ផ្ទាល់ដៃ ឱ្យមានខ្សែអាត់ សំឡេងពីសម្ភាសពី៣០, ៤០ឆ្នាំមុននោះ

គឺថា អាហ្នឹងជាការលំបាកមួយ ដែលថាយើងនឹងចំណាយពេលក្នុងការកំណត់នូវអាចជឿជាក់បាន។ នៅក្នុងវិធាន២៥ ទាក់ទងទៅនឹងចម្លើយជាលាយលក្ខណ៍អក្សរហ្នឹង គឺថាមេធាវីការពារក្តីគាត់មានសិទ្ធិនឹងស្តាប់នូវខ្សែអាត់នៅពេលដែល-- គេថតនៅពេលដែលសម្ភាសនោះ។ ដូច្នេះតាមធម្មតាគាត់អាចលើកឡើងជម្រាបតុលាការពីចំណុចមួយចំនួន។ ប៉ុន្តែគំនិតដែលល្អបំផុតដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងហ្នឹង គឺថាវាមានសារប្រយោជន៍ប្រសិនបើ កាស្សែតអាត់ទាំងអស់នោះត្រូវបានយកមកដេញដោល។

ប៉ុន្តែបើយើងធ្វើទៅ គឺថាវាត្រូវប្រើពេលវេលាវែងណាស់ ហើយតុលាការប្រហែលជាមិនត្រូវអនុញ្ញាតឱ្យដេញដោលនូវឯកសារជាខ្សែអាត់នោះទេ ដោយហេតុថា យើងមានប្រតិចារឹកពីសម្ភាសន៍នោះ យើងបានមានដាក់ក្នុងសំណុំរឿងហើយ។ ហើយក៏សាក្សីក៏បានចុះលត្ថលេខា ឬផ្តិតមេដៃលើសេចក្តីកំណត់មួយហេតុមួយទៀត ដែលជាផ្លូវការជំនួសនូវឯកសារទាំងពីរខ្សែអាត់ និងកំណត់ផ្ទាល់ដៃនោះ។

[០៩:២១:៥០]

ដូច្នេះនេះហើយជា ចំណុចមួយដែលយើងត្រូវមើលកត្តាដែលសមតុល្យ ថាតើបើសិនជាសាក្សីគាត់បានអាន ឬក៏ស្តាប់គេអានឱ្យហើយ គាត់បញ្ជាក់ថា ត្រឹមត្រូវខ្លឹមសារ ហើយគាត់ផ្តិតមេដៃ អាហ្នឹងជាឯកសារចុងក្រោយរបស់គាត់ហើយ។

ដូច្នេះលោក លោកស្រីចៅក្រមបានជ្រាបហើយ យើងបានយល់ស្របគ្នាទៅលើអង្គហេតុដែលថា មេធាវីការពារក្តីបានស្នើសុំឱ្យមានវត្តមាននូវសាក្សីទាំងឡាយ ដែលគេមានចម្លើយជូនទៅសហចៅក្រមស៊ើបអង្កេត អំពីអំពើ និងអត្តចរិតរបស់ជនជាប់ចោទនោះ។ ប៉ុន្តែអ្វីដែលយើងជឿនោះ គឺថាសភាពនៃច្បាប់ តាមប្រព័ន្ធតុលាការអន្តរជាតិ គឺថាមិនមែនជាកត្តាតម្រូវទេ។ គឺតម្រូវឱ្យភាគីដាក់ជូនភស្តុតាងគ្រប់យ៉ាងទៅដល់តុលាការ មិនបាច់កោះហៅមកបញ្ជាក់ទេ ដរាបណាតែភស្តុតានោះត្រឹមត្រូវលើកលែងករណីដែលថា ភស្តុតាងមួយចំនួនដែលចាំបាច់ត្រូវតែតទល់អំពីអំពើ ឬក៏អត្តចរិតរបស់ជនជាប់ចោទនោះ។

[០៩:២៣:០៦]

ដូច្នេះហើយយើងនឹងពិនិត្យមើលទៅនឹងកំណត់ត្រាជាលាយលក្ខណ៍អក្សរ ទៅតាមបរិបទនោះ។ ដូច្នេះហើយស្នើថា សុំឱ្យតុលាការហ្នឹងពិនិត្យមើល ពិចារណាក្នុងករណីនេះ ថាតើឯកសារខ្សែអាត់ ឬក៏

កំណត់ហេតុហ្នឹង ថាតើវាបញ្ជាក់អំពីប្រវត្តិសាស្ត្រនៃរបប-- នៃបក្សកុម្មុយនីស្តកម្ពុជា? ហើយនិងមានឯកសារមួយចំនួន ដែលអាចនឹងបញ្ជាក់អំពីអំពើ និងអត្តចរិតរបស់ជនជាប់ចោទ តើតុលាការត្រូវពិចារណាដូចម្តេច? ត្រូវទទួលយកត្រឹមណា? ឬក៏ទុកដោយឡែកមួយកម្រិតណា ហ្នឹងជាឆន្ទានុសិទ្ធិ ឬក៏អំណាចរបស់តុលាការ។

[០៩:២៣:៤៨]

ចំណុចមួយទៀត អំពីការជំទាស់ជាទូទៅអំពីការប្តូរ ការកាន់កាប់នៃឯកសារពីភាគីមួយ ឬពីស្ថាប័នមួយទៅស្ថាប័នមួយ។ ហើយបើមេធាវីការពារតម្រូវឲ្យបង្ហាញលម្អិតទាំងអស់នោះ យើងនឹងពិនិត្យមើលយុត្តិសាស្ត្រអន្តរជាតិ អំពីភាពអាចទទួលយកបាន ដោយផ្អែកទៅលើភាពជឿជាក់បាននៃភស្តុតាង គឺថាមិនត្រូវឲ្យមានលក្ខណៈវិនិច្ឆ័យ ពីភាពអាចទុកចិត្តបានវាមិនមែនជាបុរេលក្ខខណ្ឌ ដែលថាត្រូវឲ្យមានខ្សែចង្វាក់នៃការកាន់កាប់ផ្លាស់ប្តូរហ្នឹងឲ្យត្រូវតែមាននោះទេ។ ហើយក៏មិនតម្រូវថា ឲ្យបង្ហាញតុលាការថា អំពីក្រោយពីរកឃើញឯកសារ ថាហុចពីដៃអ្នកណាទៅដល់អ្នកណា កំណត់ត្រារហូតមកដល់តុលាការនោះ រហូតដល់ចុងបំផុតដល់ចៅក្រម។

[០៩:២៤:៤១]

ពេលខ្លះករណីហ្នឹង គេមិនអាចធ្វើទៅបានទេ ព្រោះឯកសារ ឬបទឧក្រិដ្ឋវាកើតជាង៣០ឆ្នាំទៅហើយ។ ហើយក៏វាមានការលំបាក ហើយវាប្រើពេលវេលាយូរនោះទៅទៀតផង ហើយសវនាការក៏អាចនឹងប្រើពេលយូរហួសហេតុណាស់ពេកនោះផងដែរ។ គោលបំណងចុងបំផុតនៃការទទួលយកបាននៃភស្តុតាងហ្នឹង ក្នុងការកំណត់ថាតើអប្បបរមានៃភាពអាចទទួលយកបានមានហើយឬនៅ? ដូច្នេះហើយយើងក៏មិនដើរផ្លូវខ្លី ចុះហេតុអ្វីយើងដើរផ្លូវវែងដែលថាចំណាយពេលនោះធ្វើអ្វី? នេះជាចំណុចសំខាន់ យើងនឹងមើលលក្ខណៈសម្បត្តិនៃឯកសារ។ ឧទាហរណ៍ថា យើងដើរផ្លូវឆ្ងាយគ្រប់តែភស្តុតាងនីមួយៗទាំងអស់រហូតដល់ចុងនៃផ្លូវនោះ។ ដូច្នេះ សវនាការ ឬតុលាការនេះគឺថានឹងប្រើពេលយូរហើយច្បាប់ក៏មិនតម្រូវឲ្យធ្វើបែបនោះផងទេ។ ជាពិសេសសហព្រះរាជអាជ្ញាគឺថា មានជំហរ និងការពិចារ-ណាថា គាត់មានការព្រួយបារម្ភអំពីការផ្លាស់ប្តូរការកាន់កាប់ឯកសារពីដៃមួយទៅភាគីមួយទៀត ឬក៏ស្ថាប័នមួយទៀតហ្នឹង អាហ្នឹងជាការព្រួយបារម្ភមួយ។ ប៉ុន្តែយើងឃើញ ពិនិត្យឃើញច្បាស់ ហើយនៅក្នុងសំណុំរឿង ដូចជាថាឯកសារទូរលេខដែលថា សាក្សីនឹងបញ្ជាក់ នេះជាតេឡេក្រាមមួយ បញ្ជាក់ថាឯកសារហ្នឹង វាមានយថាភាពត្រឹមត្រូវ គេផលិតនៅកន្លែងណា? ដូចជាទស្សនាវដ្តីទង់បដិវត្ត

ទង់ក្រហម ។ល។ និង។ល។

[០៩:២៦:១៣]

ដូច្នេះហើយ យើងនឹងកោះសាក្សីទាំងនោះមកបង្ហាញខ្លួននៅតុលាការ នឹងបញ្ជាក់នៅតុលាការ ហើយនិងទាក់ទងទៅនឹងការផ្តល់យថាភាព ឬក៏ការកាន់កាប់នៃឯកសារទាំងអស់នោះ ឬក៏ផ្លាស់ប្តូរការកាន់កាប់នោះ គឺយើងនឹងកោះអញ្ជើញមន្ត្រីមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ប៉ុន្តែបើនិយាយអំពីយថាភាព អាហ្នឹងមានតែចៅក្រមទេ ជាអ្នកធ្វើសេចក្តីសម្រេចថា តើឯកសារណាមួយមានយថាភាព ហើយនិងផ្អែកលើអាចជឿជាក់បាន ទុកចិត្តបាននោះ?

ដូច្នេះ តុលាការជាអ្នកមានសិទ្ធិកោះអញ្ជើញភាគីណាមួយ សាក្សី ឬជាអ្នកនិពន្ធ ដើម្បីមកបង្ហាញជាសក្ខីកម្ម។ ដូច្នេះហើយ យើងអាចនឹងបង្ហាញបានអំពីខ្សែចង្វាក់នៃការផ្លាស់ប្តូរការកាន់កាប់ឯកសារនោះ គឺថាមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង គឺថាមានអាយុសមល្មមហើយ វាមិនដល់១៥ឆ្នាំទេ ក៏ប៉ុន្តែគេអាចនឹងកំណត់ត្រាបាន យើងអាចរកឃើញ។

[០៩:២៧:២១]

បើសិនជាលោក លោកស្រីចៅក្រមចង់បានភស្តុតាងផ្សេងបន្ថែមទៀត អំពីការកាន់កាប់ឯកសារគឺសាក្សីដែលយើងបានស្នើឡើងហ្នឹង គឺអាចនឹងផ្តល់បង្ហាញជូនតុលាការបាននូវព័ត៌មានដែលចាំបាច់នោះ។ សហព្រះរាជអាជ្ញាមិនបានដកខ្លួនចេញដែលថា យុ ឆាំង មិនមាន ឬក៏មិនមានភស្តុតាងដែលមានតម្លៃនោះទេ។ ក៏ប៉ុន្តែការសម្រេចថា កោះហៅនោះជាសេចក្តីសម្រេចរបស់តុលាការអាចកោះហៅអ្នកផ្សេងទាក់ទងទៅនឹងការកាន់កាប់ ឬក៏ការផ្តោះប្តូរកាន់កាប់ឯកសារនៅ ឌី.ស៊ី.ខេម ជាដើមនោះ។

ដូច្នេះជាសិទ្ធិរបស់តុលាការ ហើយក៏ការប្តូរនូវការកាន់កាប់នេះមិនមែនជាលក្ខខណ្ឌចាំបាច់នៃភាពនៃអាចទទួលយកបាន និងភាពជឿជាក់នៃឯកសារនោះដែរ។ ដូច្នេះនេះជាកត្តាដែលតុលាការត្រូវពិចារណា។

មតិជាទូទៅមួយទៀតទាក់ទងទៅនឹងទស្សនៈរបស់មេធាវីការពារក្តីដែលថា ទោះជាបើបានផ្តល់ ឬមិនបានផ្តល់ពីខ្សែចង្វាក់នៃការកាន់កាប់ឯកសារតុលាការក្តី គឺថាឯកសារទាំងអស់នេះគេក៏ចង់ដឹងថាតើ ឌី.ស៊ី.ខេម ហ្នឹងគ្រប់គ្រងរបៀបណា? រក្សាទុកបែបណា? ហើយតាមដានបែបណា? ហើយគាត់ចង់ដឹងបែបនេះ គឺថាវាមិនមានតថភាពទេ វាមិនមានភាពសមហេតុផលទេ ដែលថាជាមជ្ឈមណ្ឌលមួយដែលគេធ្វើការងារ ដែលមានភារកិច្ចក្នុងការពិនិត្យមើល ហើយគាត់ស្វែងរកការពិតអំពីអ្វីដែលកើតឡើងនៅ

ក្នុងកម្ពុជាប្រជាធិបតេយ្យ។

[០៩:២៩:០០]

ហើយគេបាននិយាយថា ជាពាក្យជនសាមញ្ញថាគាត់ប្រើពាក្យថា “ជាប្រល័យពូជសាសន៍” ជាពិសេសក៏មានបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៅក្នុងកម្ពុជាផងដែរ។ ក្នុងកម្រិតមួយ ឬក៏កម្រិតទាបណាមួយហ្នឹងគឺថាយើងអាចនិយាយថា គាត់លម្អៀងបន្តិច ក៏ប៉ុន្តែអ្វីដែលគាត់ប្រមូលបាននោះគឺជាព័ត៌មានដ៏សំខាន់។ តាមពិតគាត់មិនមែនធ្វើការងារដើម្បីជំនួសឲ្យភាគីណាមួយ មេធាវី សហព្រះរាជអាជ្ញា ឬក៏ជនណាមួយទេ។ ក៏ប៉ុន្តែអង្គការគេមានអាណត្តិការងាររបស់គេ ហើយអាណត្តិនេះ គឺវាមានការទាក់ទងទៅនឹងស្ថាប័នណាផ្សេងទេ ជាតួនាទីរបស់គេអំពីការប្រមូល អំពីការគ្រប់គ្រង បើយើងចង់ចោទសួរអំពីភាពអាចទទួលយកបាននៃឯកសារនេះ យើងមានវិធី យើងមានតេស្តមួយផ្សេងទៀត។ រាល់អង្គការផ្សេងៗជា ឧទាហរណ៍ ដូចជាស្ថាប័ននគរបាលដែលអង្កេតបទឧក្រិដ្ឋ ថាតើយើងអាចនឹងនិយាយ ថាគាត់លម្អៀងទេដោយផ្អែកថា គាត់ជានគរបាលនោះ? ហើយបើសិនជានគរបាលប្រមូលបានឯកសារតើយើងត្រូវបដិសេធថាមិនឲ្យគេដាក់មកជាភស្តុតាងនៅតុលាការទេ ព្រោះប៉ូលិសដូចជាមានការ លម្អៀងតើយើងអាចនិយាយអ៊ីចឹងបានដូចម្ដេច? ទោះបីជាការអង្កេតហ្នឹងក្នុងករណីដោយសម្ងាត់ ឬដោយចំហនោះ?

សហព្រះរាជអាជ្ញាបាននិយាយថាអ្វីៗដែលមេធាវីការពារក្ដីបានដាក់នូវឯកសារទាំងអស់ ដោយ នួន ជា, ដោយ អៀង សារី, ដោយ ខៀវ សំផន។ សហព្រះរាជអាជ្ញាក៏មិនអាចនិយាយថាឯកសារទាំងអស់នោះប្រមូលបានដោយលម្អៀង ដោយភាគីម្ខាងទេ យើងមិនអាចនិយាយអ៊ីចឹងបានទេ។ គឺថាគេត្រូវវាយតម្លៃទៅលើខ្លឹមសារភស្តុតាង អ៊ីចឹងគឺថាវាត្រូវទាក់ទងទៅនឹងឯកសារ ទៅនឹងខ្លឹមសារ។ គឺមិនមែនការ អង្គការ ឬអ្នករៀបចំនោះទេ។

[០៩:៣១:០០]

ចំណុចចុងក្រោយពាក់ព័ន្ធទៅនឹងការជំទាស់ទូទៅដោយក្រុមមេធាវី ខៀវ សំផន វាបង្ហាញឲ្យឃើញថាមេធាវី ខៀវ សំផន កំពុងតែតវ៉ាថា “ពួកគាត់មិនមានឱកាសក្នុងការពិនិត្យទៅលើឯកសារទាំងឡាយដែលមាន”។ ហើយមេធាវីទាមទារថា “យ៉ាងហោចណាស់នៅក្នុងដំណាក់កាលណាមួយត្រូវតែឲ្យពួកគាត់មានលទ្ធភាពពិនិត្យឯកសារ”។

អង្គសវនាការកំពុងតែធ្វើនៅពេលនេះហើយ យើងកំពុងតែធ្វើការងារនេះ ហើយបាន ធ្វើការងារ

ទាំងអស់នេះបួនឆ្នាំរួចមកហើយ។ មេធាវីការពារក្ដី អៀង សារី មានសិទ្ធិពិនិត្យសំណុំរឿងជាច្រើនឆ្នាំមកហើយ។ គាត់មានការទទួលខុសត្រូវ យើងក៏មានការទទួលខុសត្រូវ។ បាននន័យថា ក្នុងរយៈពេលនេះត្រូវពិនិត្យទៅលើសំណុំឯកសារ។

លោក លោកស្រីចៅក្រមបានឆ្លើយតបនៅក្នុងដីកាបង្គាប់ដែលក្នុងនោះមានបញ្ជីនៃឯកសារដែលយើងនឹងដាក់ជូនអង្គជំនុំជម្រះ។ ដូចដែលលោក លោកស្រីបានជ្រាបហើយ យើងបានដាក់ឯកសារប្រហែលជាបួនពាន់ប្រាំរយឯកសារ និងប្រាំមួយពាន់ប្រាំរយឯកសារ ដែលក្នុងនោះបានរៀបរាប់នូវឯកសារទាំងឡាយ ដែលយើងបង្ហាញថា វាពាក់ព័ន្ធយ៉ាងណានោះ? យើងបានដាក់នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១។

[០៩:៣២:៣១]

មេធាវីការពារក្ដីគាត់ដឹងអំពីវិធានទាំងអស់នេះហើយ។ នៅក្នុងដំណាក់កាលសវនាការ យ៉ាងហោចណាស់គឺគាត់គួរតែយល់អំពីឯកសារទាំងអស់នេះ វិធានមានចែងយ៉ាងច្បាស់ ហើយយើងមានសិទ្ធិអនុញ្ញាតឲ្យភាគីទាំងឡាយធ្វើការជំទាស់ទៅនឹងឯកសារដែលយើងបានដាក់។

លោក លោកស្រីចៅក្រមបានអញ្ជើញភាគីឲ្យជំទាស់ឯកសារទាំងឡាយជាលាយលក្ខណ៍អក្សរ ភាគីទាំងឡាយមានឱកាសនោះរួចមកហើយ។ ហើយនៅពេលនេះយើងបានបើកសវនាការដេញដោលដើម្បីឲ្យគាត់-- ភាគីទាំងអស់លើកយោបល់។ លោក លោកស្រីចៅក្រមក៏ដឹងៗហើយ អំពីឯកសារដែលមាន៩២ទំព័រ ដែលវាពាក់ព័ន្ធទៅនឹងភាពអាចទុកចិត្តបាននៃឯកសារទាំងអស់នោះ។ យើងអាចផ្ដល់សញ្ញាបញ្ជាក់អំពីភាពទុកចិត្តបាននៃឯកសារទាំងអស់នេះ។ ក៏ប៉ុន្ដែយើងខ្ញុំសូមសន្និដ្ឋានថា សហព្រះរាជអាជ្ញាគឺគាត់មានបន្ទុករបស់គាត់ គឺបន្ទុកបទដ្ឋានកម្រិតអប្បបរមាក្នុងការកំណត់ និងបង្ហាញឯកសារទាំងឡាយដែលអាចទុកចិត្តបាន។

[០៩:៣៣:៤២]

យើងបានលើកនៅក្នុងសេចក្ដីសន្និដ្ឋានរបស់យើងរួចមកហើយ។ ហើយនៅក្នុងអាទិត្យនេះ គឺយើងបានបើកឱកាសឲ្យដេញដោលគ្នាដោយផ្ទាល់មាត់ ទៅលើឧបសម្ព័ន្ធមួយទៅដល់ឧបសម្ព័ន្ធ៥ ដែលយើងនឹងដាក់ជូននៅចំពោះអង្គសវនាការ។ ហើយយើងក៏ទទួលស្គាល់ និងសូមអរគុណចំពោះការវិភាគដែលរៀបចំដោយអង្គសវនាការ។

យើងខ្ញុំសន្និដ្ឋានថា ប្រសិនបើមេធាវី ខៀវ សំផន តវ៉ាថាគាត់មិនមានលទ្ធភាពពិនិត្យសំណុំរឿង

នោះ គឺយើងខ្ញុំយល់ឃើញថា អ្វីដែលគាត់លើកឡើងមិនមានមូលដ្ឋានទាល់តែសោះ។ យើងបានផ្តល់ឱកាសឲ្យគាត់ក្នុងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ រួមទាំងសវនាការបើកការដេញដោលដោយផ្ទាល់មាត់ផងដែរ។ ដូច្នេះ ហើយគឺ វាជាការផ្តល់ឱកាសទៅដល់គាត់ក្នុងការពិនិត្យឯកសារសំណុំរឿង។

[០៩:៣៤:៣២]

ក៏ប៉ុន្តែយើងក៏មិនមែនតម្រូវឲ្យភាគីពីមួយថ្ងៃទៅមួយថ្ងៃមើលឯកសាររហូតនោះទេ ដូច្នេះឯកសារទាំងអស់ គឺមានរយៈពេលទុកសិទ្ធិឲ្យមើលបួន-- ជាងបួនឆ្នាំមកហើយ។ ដូច្នេះហើយអង្គសវនាការនឹងធ្វើសេចក្តីសម្រេចទៅលើឯកសារទាំងអស់នោះ។

ខ្ញុំសូមសន្និដ្ឋានថា នៅចំណុចចុងក្រោយនេះ វាជាបញ្ហាពាក់ព័ន្ធទៅនឹងទម្ងន់នៃ-- ទៅដែលយើងត្រូវកំណត់ទៅលើឯកសារទាំងអស់នោះ នៅពេលដែលយើងទទួលយកឯកសារទាំងអស់នោះមក។ ដូច្នេះ យើងនឹងមើល ថាតើឯកសារនោះបានបង្ហាញអ្វីខ្លះ ហើយអង្គសវនាការនឹងទទួលយក ឯកសារទាំងអស់នោះ។ នៅពេលដែលយើងមើលឯកសារទាំងអស់នោះ គឺយើងនឹងយល់អំពីភស្តុតាងដែលមាននៅក្នុងការជំនុំជម្រះនេះ ដែលវាពាក់ព័ន្ធទៅនឹងសាក្សីផងដែរ។

យើងខ្ញុំសូមសន្និដ្ឋានថា អង្គសវនាការក្រុមប្រឹក្សាជំនុំជម្រះគឺមានកាតព្វកិច្ចក្នុងការបង្ហាញនូវការពិត និងការ-- និងមានកាតព្វកិច្ចការពារសិទ្ធិរបស់ជនជាប់ចោទផងដែរ។ យើងខ្ញុំមានកាតព្វកិច្ចក្នុងការបង្ហាញនូវការពិតទាំងឡាយឲ្យអង្គសវនាការពិនិត្យភស្តុតាងឲ្យបានទូលំទូលាយ ហើយក៏ត្រូវពិចារណាទៅលើវិធាននៃការទទួលយកភស្តុតាងដែលមានចែងនៅក្នុងវិធាននីតិវិធី និងភស្តុតាងផងដែរ។ ដូច្នេះ នៅដំណាក់កាលចុងក្រោយ អង្គសវនាការនឹងត្រូវការពិចារណាទៅលើទម្ងន់ដែលវាចងភ្ជាប់ទៅនឹងឯកសារទាំងអស់នេះ។

[០៩:៣៦:០១]

លោក លោកស្រីចៅក្រម នៅពេលនេះខ្ញុំសូមលើកឡើងអំពី តារា ច័ន្ទ ដែលគាត់នឹងផ្តល់ចម្លើយពាក់ព័ន្ធទៅនឹងសំណុំនៃឯកសារមួយចំនួន។ ជាពិសេសទៅលើការលើកឡើងអំពីយថាភាពនៃឯកសារ។ ឯកសារទាំងឡាយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ គឺក៏មានបញ្ចូលនៅក្នុងឧបសម្ព័ន្ធមួយដល់ប្រាំផងដែរ។ ដូច្នេះ ការឆ្លើយតបទាំងអស់នោះ គឺក៏មានការស្តាប់ចម្លើយទៅដល់លោក ញឹម ញ៉ុន ដែលយើងនឹងមកផ្តល់សក្ខីកម្មនៅក្នុងសវនាការលើក្រោយ គឺចម្លើយរបស់ ខឹម ងុន ផងដែរ។

[០៩:៣៦:៥៣]

**លោក ច័ន្ទ តាវារស្មី៖**

សូមគោរពលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។ សូមគោរពអង្គសវនាការទាំងមូល។

ខ្ញុំឈ្មោះ ច័ន្ទ តាវារស្មី ជាសហព្រះរាជអាជ្ញារងជាតិនៅសាលាក្តីខ្មែរក្រហមនេះ។ ជាបន្តទៅនេះ ខ្ញុំសូមអនុញ្ញាតធ្វើការឆ្លើយតបទៅនឹងអ្វីដែលមេធាវីការពារក្តីបានលើកឡើង ទាក់ទិនទៅនឹងឯកសារជាភស្តុតាងមួយចំនួនដូចតទៅនេះ៖

ចំណុចទី១) គឺទាក់ទិននឹងឯកសារដែលមានលក្ខណៈជាវីដេអូ។

ទី២) គឺការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងឧបសម្ព័ន្ធទីពីរ។

ទី៣) គឺកំណត់ហេតុនៃការប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងឧបសម្ព័ន្ធបី។

ទី៤) គឺ*ស្តេតមិន* របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលនៅក្នុងនោះ មានរាប់បញ្ចូលនូវរណសិរ្សបង្រួបបង្រួមជាតិកម្ពុជានិងរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ដែលមានការបោះពុម្ពផ្សាយហើយមានយោងនៅក្នុងឧបសម្ព័ន្ធទីប្រាំ។

ចំណុចទី៥) គឺទាក់ទិនទៅនឹងរបាយការណ៍សារព័ត៌មាន ដែលទាក់ទិនទៅនឹងកម្ពុជាប្រជាធិបតេយ្យ មានឯកសារយោងនៅក្នុងឧបសម្ព័ន្ធទីប្រាំ។

[០៩:៣៨:១៦]

ចំពោះឯកសារជាភស្តុតាងដែលមានលក្ខណៈជាវីដេអូ ខ្ញុំនឹងលើកឡើងអំពីការជំទាស់របស់ អៀង សារី ទៅនឹងវីដេអូចំនួនពីរ ដែលមានឯកសារយោង គឺ E3/81 ឬD108/32.2 និង E3/124a ឬ D299.1.46a។ វីដេអូទីមួយមានឈ្មោះថា “ស្រមោល ប៉ុល ពត” ត្រូវបានជំទាស់ទៅនឹងមូលដ្ឋានថា វាជាឧបសម្ព័ន្ធមួយនៃសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញាដែលបានស្វែងរកការបញ្ចូលសម្ភារៈប្រភេទនេះនៅក្នុងសំណុំរឿង០០១។

មេធាវីការពារក្តីបានលើកឡើងថា ដោយសារសំណើវីដេអូនេះ មិនទាក់ទិននឹងសំណុំរឿងនេះ ដូចនេះវីដេអូនេះ គឺមិនអាចទទួលយកបានទេ។ ការជំទាស់នេះ មិនមានទម្ងន់នោះទេ ព្រោះថាអង្គហេតុដែលវីដេអូនេះភ្ជាប់ គឺភ្ជាប់ទៅនឹងសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញានៅក្នុងសំណុំរឿង០០១។ គឺមិនទាក់ទិនទៅនឹងការពិចារណាសម្រាប់ភាពអាចទទួលយកបាននេះទេ។

[០៩:៣៩:៤១]

ភាពពាក់ព័ន្ធនៃភស្តុតាងនេះ ភ្ជាប់ទៅនឹងវីដេអូ ជាពិសេសគឺការសម្ភាសន៍ជាមួយនឹងជនជាប់ចោទ នួន ជា អំពីតួនាទី និងមុខងាររបស់គាត់នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

ចំពោះវីដេអូទីពីរ ជារបាយការណ៍របស់ *ភារី* ប៊ី.ប៊ី.ស៊ី ដែលរួមមានសម្ភាសន៍ជនជាប់ចោទនួន ជា ត្រូវបានជំទាស់លើមូលដ្ឋានថា វីដេអូនេះគ្រាន់តែមានផ្នែកខ្លះនៃការសម្ភាសន៍មួយរបស់ នួន ជា និងថា ចម្លើយដើមជាភាសាខ្មែរមិនអាចស្តាប់បានទេ។ ដោយសារការនេះ មេធាវីការពារក្តីបានលើកឡើងថា វាពិបាកក្នុងការពិនិត្យលើភាពត្រឹមត្រូវនៃកិច្ចសម្ភាសន៍នេះ។

លោក លោកស្រីចៅក្រម បើទោះបីជាជាសំឡេងរបស់នួន ជា មិនអាចស្តាប់ឮបានតាមការបកប្រែក្តី ក៏មិនអាចនិយាយថា ប៊ី.ប៊ី.ស៊ី ដែលជាស្ថាប័នព័ត៌មានដ៏មានកេរ្តិ៍ឈ្មោះល្បី បានបកប្រែដោយមិនត្រឹមត្រូវនូវការសម្ភាសន៍នោះទេ ឬក៏ថា មិនបានពិនិត្យឡើងវិញ ដែលនាំឲ្យមានការភ័ន្តច្រឡំនោះឡើយ។ ហេតុដូច្នេះ វីដេអូនេះត្រូវតែទទួលយកបានជាគោលការណ៍។ ការជំទាស់របស់មេធាវី ត្រូវតែបានបដិសេធចោល ដោយសារជាពិសេសនៅលើមូលដ្ឋានថា នួន ជា មិនបានអះអាងថា ការសម្ភាសន៍នេះ បកប្រែមិនបានត្រឹមត្រូវឡើយ។

[០៩:៤១:២២]

វីដេអូទាំងពីរនេះ គឺច្បាស់ណាស់ មានការពាក់ព័ន្ធដោយសារតែការសម្ភាសន៍ជាមួយនឹង នួន ជា បានផ្តល់នូវព័ត៌មានពាក់ព័ន្ធអំពីតួនាទីគាត់នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

លោក លោកស្រីចៅក្រមជាទីគោរព ចំពោះឯកសារបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានកំណត់ក្នុងឧបសម្ព័ន្ធពីរ ខ្ញុំសូមធ្វើការឆ្លើយតបដូចតទៅនេះ។ ខ្ញុំនឹងលើកអំពីការជំទាស់របស់ អៀង សារី ទៅនឹងឯកសារបោះពុម្ពផ្សាយចំនួនប្រាំបួនរបស់បក្សកុម្មុយនីស្តកម្ពុជា។ ឯកសារទាំងនោះគឺមាន E3/5 ឬ D243/21.1, E3/99 ឬ IS6.2, E3/12 ឬ IS6.3, E3/50 ឬ D366/7.1.61, E3/4, (D123/3.1), IS11.9 និង D123/3.1, E3/10 ឬ D243/21.7, E3/25 ឬ D243/21.9 E3/11 ឬ D243/2.1.12 និង E3/23 ឬ D135.1។

ឯកសារប្រាំពីរ ក្នុងចំណោមឯកសារប្រាំបួននេះ គឺជាឯកសារបោះពុម្ពផ្សាយដោយបក្សកុម្មុយនីស្តកម្ពុជា ដែលរួមមានឯកសារទង់បដិវត្តចំនួនប្រាំ និងសារាចរមួយ និងឯកសារមួយទៀតរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។

[០៩:៤៣:៤៤]

អៀង សារី បានបដិសេធជាទូទៅលើមូលដ្ឋានថា ការគួរឲ្យជឿបាន និងភាពត្រឹមត្រូវនៃឯកសារទាំងនេះ គឺមិនត្រូវបានពន្យល់ និងថា ខ្លួនមិនមានឱកាសក្នុងការតទល់ជាមួយនឹងអ្នកនិពន្ធនៃឯកសារទាំងនោះទេ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី មេធាវីការពារក្តីបានខកខានក្នុងការបង្ហាញពីភាពពាក់ព័ន្ធនៃឯកសារទាំងនេះ ដូចដែលបានបង្ហាញនៅក្នុងដីកាដំណោះស្រាយ និងថា បញ្ជីឯកសាររបស់ការិយាល័យសហព្រះរាជអាជ្ញាមានកំហុស។

សហព្រះរាជអាជ្ញាបានពឹងផ្អែកទៅលើសេចក្តីថ្លែងការណ៍ ពីភាពពាក់ព័ន្ធនៅក្នុងឯកសារនេះក្នុងការបង្ហាញនៅក្នុងឯកសារ ដូចមានបញ្ជាក់នៅក្នុងសំណុំរឿង។ ឯកសារទាំងនេះ គឺច្បាស់ណាស់ពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រ រចនាសម្ព័ន្ធ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា ចំពោះភាពគួរឲ្យជឿបាន ឯកសារទាំងនេះគឺចាប់អារម្មណ៍ទៅលើសេដ្ឋកិច្ចយុត្តិសាស្ត្រ និងគោលនយោបាយយោធា ក៏ដូចជាសកម្មភាពនានាដទៃទៀត។ ឯកសារទាំងនេះ មាននូវការប្រើប្រាស់ពាក្យ ដែលតែងតែពាក់ព័ន្ធទៅនឹងបក្សកុម្មុយនីស្តកម្ពុជា និងប្រកាន់នូវមនោគមវិជ្ជារបស់ខ្លួន។ ជាឧទាហរណ៍ អត្ថបទបានប្រើពាក្យដូចជា “កងទ័ពបដិវត្តន៍ ពួកចក្រពត្តិអាមេរិក” និងការប្រើពាក្យ “កម្មេច” ជាដើម។ គោលបំណងរបស់អត្ថបទបោះពុម្ពទាំងនេះ គឺច្បាស់ណាស់ ដើម្បីបញ្ចូលនូវមនោគមវិជ្ជាដល់សមាជិកបក្សអំពីគោលនយោបាយ និងទិសដៅរបស់បក្សកុម្មុយនីស្តកម្ពុជា។

[០៩:៤៥:៣០]

ទង់បដិវត្តត្រូវបានបោះពុម្ព និងចែកចាយជាផ្លូវការដោយក្រសួងឃោសនាការទៅឲ្យក្រសួងនានា។ សាក្សីនានារួមមានដូចជា នួន ជា បានបញ្ជាក់ថា ទង់បដិវត្តគឺជាឯកសារបោះពុម្ពរបស់បក្សកុម្មុយនីស្តកម្ពុជា និងថាសមាជិកគណៈអចិន្ត្រៃយ៍ រួមទាំង នួន ជា និងប៉ុល ពត ផងដែរ បានសរសេរអត្ថបទសម្រាប់បោះពុម្ពនៅក្នុងទង់បដិវត្តនេះ។

លោក លោកស្រីចៅក្រមជាទីគោរព អត្ថបទបោះពុម្ពផ្សាយរបស់ទង់បដិវត្តមាននូវសញ្ញា និងទម្រង់ដូចគ្នា។ ទំព័រគម្របខាងមុខមានរូបទង់ពីរ ឬច្រើន។ រូបញញួរ និងកណ្តៀវ ជាសញ្ញាកុម្មុយនីស្តគឺបង្ហាញនៅខាងមុខជំពូកនីមួយៗ និងនៅខាងក្រោយទំព័រគម្របក្រោយ។

ស្រដៀងគ្នានេះដែរមួយក្នុងចំណោមឯកសារទង់បដិវត្តដែលបានបោះពុម្ពនោះ មានរូបញញួរ និងរូបកណ្តៀវពេញទាំងអស់។ មានឯកសារបោះពុម្ពផ្សាយមួយចំនួននៃទង់បដិវត្ត ដែលរួមបញ្ចូល

នៅក្នុងបញ្ជីឯកសារត្រូវបានទទួលដាក់ក្នុងភស្តុតាងនៅក្នុងសំណុំរឿង001 រួចហើយ។ គ្រប់អត្ថបទបោះពុម្ពផ្សាយទាំងអស់របស់ទង់បដិវត្តគឺមានលក្ខណៈដូចគ្នា។

ភាពឲ្យគួរឲ្យជឿជាក់បាននៃឯកសារ ត្រូវបានចង្អុលបង្ហាញ ឬផ្តល់ភាពត្រឹមត្រូវដោយសាក្សី និងទទួលដាក់ជាភស្តុតាងរួចទៅហើយនៅក្នុងសំណុំរឿង០០១។ គឺមានភាពរួមគ្នានឹងអត្ថបទបោះពុម្ពផ្សាយផ្សេងទៀតនៅក្នុងបញ្ជីឯកសារ។

[០៩:៤៧:១៨]

សេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា បើយោងឯកសារ E3/12 ដែលមានឈ្មោះថា "សេចក្តីសម្រេចរបស់គណៈមជ្ឈិមទៅលើបញ្ហាមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦" គឺទាក់ទិនទៅនឹងបការបង្ហាញពីការបង្កើតនៃរចនាសម្ព័ន្ធអង្គការរបស់បក្សកុម្មុយនីស្តកម្ពុជា រួមទាំងអំណាចផ្លូវច្បាប់របស់ជនជាប់ចោទឈ្មោះ នួន ជា ផងដែរ ដែលក្នុងនោះជាប្រធានសភាប្រជាជនកម្ពុជាប្រជាធិបតេយ្យ។ ខៀវ សំផន ជាប្រធានប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ និង អៀង សារី ជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងការបរទេស។

[០៩:៤៨:០៣]

សេចក្តីណែនាំក៏បានបង្ហាញពីការដឹងឮរបស់ជនជាប់ចោទ និងការចូលរួមនៅក្នុងការធ្វើគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា រួមទាំងការសម្លាប់ដោយខុសច្បាប់ទៀតផង។

លោក លោកស្រីចៅក្រមជាទីគោរព ឈ្មោះរបស់សេចក្តីណែនាំបញ្ជាក់ថាឯកសារនេះ គឺបានមកពីគណៈមជ្ឈិម ដូចគ្នាទៅនឹងឯកសារផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជាកម្មេចចក្រពត្តិអាមេរិក និងអត្ថន័យនៅក្នុងឯកសារ គឺមានសង្គតិភាព និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបានដឹងឮ បានន័យថាការប្រើពាក្យពេចន៍ និងអត្ថន័យដែលមាននៅក្នុងឯកសារទាំងអស់នោះ គឺត្រូវបានបង្អុលបង្ហាញថា មានភាពត្រឹមត្រូវ ហើយដែលបញ្ជាក់ដោយប្រធានរបស់ ឌី.ស៊ី.ខេម គឺលោក ឆាំង យុ (យុ ឆាំង) ត្រូវបានទទួលយកជាភស្តុតាងនៅក្នុងសវនាការក្នុងសំណុំរឿង ឌុច រួចហើយ។

[០៩:៤៩:០១]

លោក លោកស្រីចៅក្រម ខ្ញុំសូមអនុញ្ញាតធ្វើការឆ្លើយតបទៅនឹងកំណត់ហេតុនៃការប្រជុំ ដែលមាននៅក្នុងឧបសម្ព័ន្ធទីបី។ កំណត់ហេតុនៃកិច្ចប្រជុំនេះ ក៏បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងឯកសារដែល

សហព្រះរាជអាជ្ញាបានដាក់ជូនរួចហើយ។

ខ្ញុំនឹងលើកឡើងពីការជំទាស់របស់ អៀង សារី ទៅនឹងកំណត់ហេតុប្រជុំកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា ដែលមានឯកសារយោង E3/13 ឬ IS13.34។ ឯកសារនេះ ត្រូវបានធ្វើឡើងដោយកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ ហើយមានឈ្មោះថា "កិច្ចប្រជុំលេខា អនុលេខាកងពល និងវរៈសេនាធំឯករាជ្យ"។

អៀង សារី បានជំទាស់ទៅនឹងការទទួលយកឯកសារនេះ វៀរលែងតែភាពត្រឹមត្រូវ ភាពគួរឲ្យជឿបាន និងការពាក់ព័ន្ធនានាត្រូវបានបង្ហុលបង្ហាញឲ្យបានគ្រប់គ្រាន់ និងអ្នកនិពន្ធត្រូវបានយកមកដេញដោល។ មេធាវីលើកឡើងថា ប្រសិនបើទទួលយកជាភស្តុតាងនេះមាននូវទម្ងន់ក្នុងកម្រិតមួយ។ ទាល់តែមាតិកាឯកសារត្រូវបានយកមកពិនិត្យ ឬគាំទ្រដោយការធ្វើការចង្អុលបង្ហាញ។ នេះបើតាមការពិតជាជំហររបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលថាអ្នកនិពន្ធឯកសារមិនចាំបាច់កោះហៅទេ ប្រសិនបើភាពត្រឹមត្រូវអាចត្រូវបានធ្វើឡើងតាមរបៀបណាផ្សេងណាមួយនោះ គឺកោះហៅអ្នកនិពន្ធគឺជាការមិនចាំបាច់។ នេះនឹងជួយធ្វើឲ្យដំណើរការរឿងក្ដីរបស់យើងដំណើរការបានយ៉ាងលឿន។

[០៩:៥០:៤២]

ការខកខានរបស់មេធាវីការពារក្ដីអៀង សារី នៅក្នុងការពន្យល់ថា ហេតុអ្វីបានជាភាពពាក់ព័ន្ធដែលចង្អុលបង្ហាញនៅក្នុងបទចោទនៃដីកាដំណោះស្រាយ និងការចង្អុលបង្ហាញដោយការិយាល័យសហព្រះរាជអាជ្ញានៅក្នុងបញ្ជីលើកទីមួយមិនមានសុពលភាពនោះ ទិដ្ឋភាពនៃការជំទាស់នេះគួរតែត្រូវបានបដិសេធចោល។ វាមិនមែនជាការប្រើប្រាស់ពេលវេលាតុលាការនោះទេ ក្នុងការលើកឡើងដដែលៗពីភាពពាក់ព័ន្ធឯកសារដែលត្រូវបានផ្ដល់លម្អិតរួចហើយ នៅក្នុងបញ្ជីឯកសារដែលបានដាក់ដោយភាគីនានានៅក្នុងខែមេសា និងម្ដងទៀតនៅក្នុងខែកក្កដា នាឆ្នាំមុនកន្លងមក-- នាឆ្នាំមុនៗ។

ចំពោះភាពគួរឲ្យជឿជាក់បាន មានលក្ខណៈជាច្រើនដែលហាក់បង្ហាញថា ឯកសារគឺត្រឹមត្រូវដូចជាប្រភពមានឈ្មោះអ្នកនិពន្ធ គឺកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា។ ទម្រង់ ប្លង់ទំព័រ និងវាយជាអង្គុលីលេខដូចគ្នាទៅនឹងកំណត់ហេតុប្រជុំយោធាផ្សេងៗទៀត រួមទាំងឯកសារដែលត្រូវបានផ្ដល់អត្តសញ្ញាណដោយ កាំង ហ្គេកអ៊ាវ ហៅ ឌុច។

និងអត្ថន័យគឺមានភាពស៊ីសង្វាក់គ្នាជាមួយនឹងសកម្មភាពរបស់បក្សកុម្មុយនីស្ដកម្ពុជា ក្នុងការចាប់ខ្លួន ការសួរចម្លើយ ឬក៏ការដកជនក្បត់នានា និងការប្រើពាក្យទូទៅរបស់បក្សកុម្មុយនីស្ដកម្ពុជា

ដូចជាការកម្ទេចជាដើម។

[០៩:៥២:១៦]

លើសពីនេះទៀត ឯកសារថតចម្លងត្រូវបានផ្តល់ដោយការិយាល័យសហព្រះរាជអាជ្ញា ដោយ ឌី.ស៊ី.ខេម ក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋមកន្លងមក។

ដូច្នេះយើងស្នើថាភាពត្រឹមត្រូវរបស់ឯកសារ គឺគ្រប់គ្រាន់ហើយ ជាពិសេសក្នុងពេលអវត្តមានការបង្ហាញណាមួយផ្សេងទៀត។ ផ្ទុយពីនេះក្នុងការបំពេញតេស្តមួយក្រឡេកភ្នែកនៃភាពគួរឲ្យជឿជាក់បាននៃឯកសារទាំងនេះ។ ហេតុដូច្នេះអ្នកនិពន្ធគឺមិនចាំបាច់កោះហៅមកសាកសួរនោះទេ។

[០៩:៥២:៥០]

សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងរដ្ឋាភិបាលបង្រួមបង្រួមជាតិ និងរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា អត្ថបទបោះផ្សាយ។ ខ្ញុំសូមបង្ហាញជូនទៅនឹងការ-- របស់ខ្ញុំទៅនឹងការឆ្លើយតបអ្វីដែលមេធាវីការពារក្តីបានលើកឡើង។

អៀង សារី បានជំទាស់ជាទូទៅថាតម្លៃដែលបានបញ្ជាក់ថាឯកសារត្រូវបានបាត់បង់ដោយសារតែភាពលម្អៀងគតិច្បាប់របស់វា និងថាឯកសារនេះមិនគួរឲ្យជឿជាក់ និងមិនសមយកមកបង្ហាញអង្គហេតុដែលត្រូវបានបង្ហាញ និងជនជាប់ចោទមិនមានឱកាសតទល់នឹងអ្នកនិពន្ធអត្ថបទទាំងអស់នោះទេ។ ជាថ្មីម្តងទៀត អៀង សារី មិនបានផ្តល់មូលដ្ឋានអង្គហេតុលើការជំទាស់នេះទេ ដោយសារហេតុផលនេះ យើងស្នើថាការជំទាស់របស់ អៀង សារី ត្រូវតែបដិសេធចោលដោយសារគ្មានមូលដ្ឋានដែលគួរឲ្យជឿបាន។

ចំពោះភាពពាក់ព័ន្ធនៃឯកសារទាំងនេះ ក្នុងការជួយបង្ហាញអំពីអំណាចផ្លូវច្បាប់ និងតាមអង្គហេតុរបស់ជនជាប់ចោទនៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំសូមលើកជាឧទាហរណ៍គឺគេដាក់ ខៀវ សំផន ជានាយករដ្ឋមន្ត្រីស្តីទី និងមានការលម្អិតទៅលើទស្សនកិច្ចផ្សេងៗរបស់ជនជាប់ចោទទៅកាន់ប្រទេសនានាដែលជាផ្នែកនៃទស្សនកិច្ចផ្លូវការ។ ឯកសារទាំងនេះបានជួយបង្ហាញពីភាពជាសមាជិកភាពនៅក្នុងការចូលរួមនៅក្នុងបទឧក្រិដ្ឋសហឧក្រិដ្ឋកម្មរួម។

ចំពោះភាពគួរឲ្យជឿជាក់បាន សូចនាករនៃភាពត្រឹមត្រូវនៃឯកសារទាំងនោះរួមមាន៖ មួយប្រភពឯកសារ ឯកសារត្រូវបានដាក់ថាជាឯកសារផ្លូវការរបស់រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា រដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។ និងទីពីរ ថ្ងៃខែឆ្នាំព្រឹត្តិការណ៍ដែលគេបានកត់ត្រាគឺមានបញ្ជាក់យ៉ាង

ច្បាស់។ ចំណុចទីបី គឺមានបញ្ជាក់សញ្ញាផ្លូវការនៃឯកសារនោះ។ ចំណុចទីបួនបានបញ្ជាក់អំពីគោលបំណងរបស់ឯកសារ គឺដើម្បីបញ្ចូលមនោគមន៍វិជ្ជាដល់ប្រជាជន អំពីគោលនយោបាយ និងទិសដៅរបស់រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា រដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងដើម្បីរិះគន់វៀតណាម។ ដែលអាចមើលឃើញយ៉ាងច្បាស់ថា និងអាចមានន័យយ៉ាងច្បាស់ថា មានភាពស៊ីសង្វាក់គ្នាជាមួយនឹងគោលនយោបាយ និងទិសដៅរបស់អ្នកនិពន្ធ។

៥) ឯកសារត្រូវបានផ្តល់ឲ្យតាមរយៈ ឌី.ស៊ី.ខេម ដែលជាអង្គការមានគោលដៅប្រមូល និងវិភាគភស្តុតាងអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ ជាឧទាហរណ៍មួយទៀត គឺបញ្ជាក់អំពីភាពត្រឹមត្រូវរបស់ឯកសារ E3/114 ដែលជាអត្ថបទបោះផ្សាយរបស់រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា ដែលបានដាក់ឈ្មោះថា ភាសាបារាំង *"នូវែលស៍ ឌុយ កាំបូតស៍"* មានន័យថា ឯកសារនេះ គឺជាឈ្មោះដែលបានសរសេរជាភាសាបារាំងយ៉ាងដូច្នេះ។ បញ្ជាក់ពីភាពត្រឹមត្រូវត្រូវបានគេឃើញនៅទំព័រចំណងជើង។ ទំព័រនេះកំណត់អត្តសញ្ញាណថាជាការបោះផ្សាយដោយ *"អាស្សង់ កម្ពុជា ដង់ហ្វ័រម៉ាស្យុង"* សរសេរជាភាសាបារាំង គឺ *"អាហ្សង់ស៊ីស កម្ពុជា ដង់ហ្វ័រម៉ាស្យុង"* និងមានការលើកឡើងជាក់លាក់មួយអំពីខ្លឹមសារ វារួមមានការបោះពុម្ពផ្សាយ ដែលមានដាក់ជាលេខបោះពុម្ពផ្សាយផងដែរ។

[០៩:៥៦:២៦]

គេអាចមើលឃើញផងដែរនូវទម្រង់នៃឯកសារនេះ ហើយបញ្ជាក់នូវឈ្មោះ និងលេខរៀងមាតិកានៅទំព័រមុខ គឺវាស៊ីសង្វាក់ជាមួយនឹងលេខបោះពុម្ពផ្សាយដទៃទៀតនៃ *នូវែលស៍ ឌុយ កាំបូតស៍*។ ការខកខានរបស់ អៀង សារី ក្នុងការលើកឡើងថា ហេតុអ្វីឯកសារមិនមានពាក់ព័ន្ធដូចចង្អុលដល់លេខយោងទៅលើការចោទប្រកាន់របស់ដីកាដំណោះស្រាយ និងដូចដែលបានកំណត់បង្ហាញយ៉ាងជាក់លាក់នៅក្នុងបញ្ជីលើកដំបូងរបស់ការិយាល័យសហព្រះរាជអាជ្ញា។

[០៩:៥៦:៥៩]

ការលើកឡើងនេះ យើងសូមស្នើថា សូមអង្គជំនុំជម្រះគប្បីជំទាស់ និងត្រូវបដិសេធចោលទាំងអស់។

លោក លោកស្រីចៅក្រមជាទីគោរព ខ្ញុំសូមបង្ហាញជូនមួយទៀត ទាក់ទងនឹងចំណុចរបាយ-ការណ៍សារព័ត៌មានទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ អៀង សារី ជំទាស់ទៅនឹងការទទួលយកឯកសារនេះ ដោយឈរមូលដ្ឋានថា តម្លៃដែលអាចបញ្ជាក់បាននៃឯកសារ គឺត្រូវបានលុបចោល។ លុប

ពីលើដោយសារតែភាពលម្អៀងគតិច្បាប់របស់វា។ មេធាវីការពារក្តីបានថ្លែងថា ឯកសារទាំងនេះមិនគួរឲ្យជឿជាក់បាន និងថាអ្នកនិពន្ធមិនត្រូវបានគេស្គាល់ឡើយ។

[០៩:៥៧:៤០]

ជាថ្មីម្តងទៀត ក្រុមការពារក្តី អៀង សារី ខកខានក្នុងការបង្ហាញថា ហេតុអ្វីបានជាមានភាពពាក់ព័ន្ធបង្ហាញនៅក្នុងដីកាដំណោះស្រាយ? និងថាហេតុអ្វីបានជាបញ្ជីឯកសារលើកទីមួយរបស់សហព្រះរាជអាជ្ញាមិនមានសុពលភាពនោះ? ដោយសារការខកខាននេះ សហព្រះរាជអាជ្ញាពឹងផ្អែកទៅលើភាពពាក់ព័ន្ធនៃឯកសារទាំងនេះ ដូចបានចង្អុលបង្ហាញនៅក្នុងដីកាដំណោះស្រាយ និងបញ្ជីឯកសារលើកទីមួយរបស់ខ្លួន នៅក្នុងការចៀសវាងការនិយាយច្រំដែលដដែលជាដដែល។

ដូចបានបានពិភាក្សាកន្លងមករួចមកហើយ ចំពោះភាពដែលឲ្យគួរជឿជាក់បាន គឺវាមិនចាំបាច់កោះហៅអ្នកនិពន្ធទេ ប្រសិនបើភាពត្រឹមត្រូវរបស់ឯកសារ អាចត្រូវបានបំពេញតាមរបៀបណាផ្សេងនោះរួចទៅហើយ។

[០៩:៥៨:២៤]

ជាទូទៅរបាយការណ៍សារព័ត៌មាន ទាក់ទិននឹងកម្ពុជាប្រជាធិបតេយ្យ គឺជារបាយការណ៍ដែលធ្វើឡើងក្នុងអំឡុងពេលនោះយ៉ាងជាក់ច្បាស់ ដែលបានបង្ហាញអំពីបញ្ហា និងដំណោះស្រាយទាំងឡាយដែលទាក់ទិនទៅនឹងបញ្ហាទាំងឡាយដែលបានកើតមកក្នុងអតីតកាល ហើយវាទាក់ទិនទៅនឹងសវនាការនាពេលនេះ។ ឯកសារទាំងនេះជួយក្នុងការបង្ហាញពីរចនាសម្ព័ន្ធរដ្ឋបាល ពីបក្សកុម្មុយនីស្តកម្ពុជា និងទាក់ទិនទៅនឹងបន្លាស់ទីប្រជាជននៅដំណាក់ទីមួយផងដែរ។ ឯកសារទាំងនេះមានប្រភព ពីប្រភពច្បាស់លាស់ផ្លូវការពីប្រព័ន្ធផ្សព្វផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងមានភាពស៊ីសង្វាក់តាមបែបមួយដូចគ្នាទៅនឹងការប្រើវោហារសព្ទសមទៅនឹងលក្ខណៈរបស់ឯកសារ។

[០៩:៥៩:១១]

ឧទាហរណ៍ ការប្រើប្រាស់ពាក្យពេចន៍ "ចក្រពត្តិអាមេរិក" ការប្រើប្រាស់ពាក្យពេចន៍ "បនក្បត់លន់ នល់" ជាញឹកញាប់ដែលឃើញនៅក្នុងឯកសារនោះ។ ព័ត៌មាននៅក្នុងឯកសារត្រូវបានបញ្ជាក់បន្ថែមដោយសារឯកសារផ្សេងៗទៀត ដែលមាននៅក្នុងសំណុំរឿង និងមានភាពស៊ីសង្វាក់គ្នាជាក់ច្បាស់ជាមួយនឹងគោលនយោបាយ និងការអនុវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលគេបានដឹងឮក្នុងអំឡុងពេលនោះ។

ដោយឡែកឯកសារ E3/119 ដែលស្គាល់ផងដែរថាជា ឯកសារ D262.9 បានពិភាក្សាពីអង្គហេតុនៃដំណាក់ទីមួយ នៃការជម្លៀសប្រជាជន ហេតុផលនៅពីក្រោយគោលនយោបាយនៃការជម្លៀសនេះ និងអំពីការតែងតាំងតួនាទីបុគ្គលមួយចំនួននៅក្នុងជួរបក្ស។ ឯកសារនេះក៏បង្ហាញពីបញ្ហាដែលទាក់ទិនទៅនឹងដំណាក់កាលបច្ចុប្បន្ននៃដំណើរការក្តី និងផ្តល់នូវព័ត៌មានសំខាន់ៗអំពីរចនាបទ-- អំពីបរិបទដែលកើតមានកន្លងមក-- អំពីបរិបទដែលកើតមានកន្លែងមក។ ជាការឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីការពារដែលថា ភស្តុតាងមិនអាចទទួលយកបានដោយសារអ្នកនិពន្ធមិនត្រូវបានលើកឡើងនៅក្នុងករណីនេះទេ គឺសហព្រះរាជអាជ្ញាយល់ថា ការលើកឡើងរបស់មេធាវីការពារក្តី គឺជាការមិនត្រឹមត្រូវ។ គប្បីអង្គជំនុំជម្រះបដិសេធចោលចំពោះការលើកឡើងរបស់មេធាវីការពារក្តីនេះ។

[១០:០០:៣៧]

ម្យ៉ាងវិញទៀត ជាការឆ្លើយតបទៅនឹងការលើកឡើងនេះ សហព្រះរាជអាជ្ញាយល់ឃើញថា ទោះបីជាការបង្ហាញពីភស្តុតាងប្រភពឯកសារ និងចំណងទាក់ទិននៃអ្នកកាន់កាប់ឯកសារ ពាក់ព័ន្ធនឹងការពិចារណា ថាតើឯកសារមួយមានសូចនាករនៃភាពគួរឲ្យជឿជាក់បានគ្រប់គ្រាន់ឬទេ? នោះវាមិនមែនជាការតម្រូវជាមុននៃការទទួលយកភស្តុតាងនោះទេ។ ដូចដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូងនៅតុលាការ យូហ្គោស្លាវី នៅក្នុងករណីរឿងក្តី រដ្ឋអាជ្ញា ទល់នឹង*អ័ររីក* នៅក្នុងសាលដីការបស់ខ្លួនចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦ នៅកថាខណ្ឌទី២៧ ដល់២៨ អង្គជំនុំជម្រះសាលាដំបូងមិនពិចារណាពីការបង្ហាញភស្តុតាងនៃចំណងអ្នកកាន់កាប់ឯកសារគឺជា *ស៊ីនេតហ្ស៍វីង* ឬលក្ខខណ្ឌសំខាន់សម្រាប់ភាពទទួលយកបាននៃភស្តុតាងនោះឡើយ។

[១០:០១:៣៨]

ដូចនេះមានន័យថា គម្លាតនៅក្នុងចំណងនៃអ្នកកាន់កាប់ឯកសារគឺមិនសំខាន់ ដោយសារភស្តុតាងទាំងមូលបានចង្អុលបង្ហាញហួសពីវិមតិសង្ស័យទៅទៀតថា ផ្នែកនៃភស្តុតាងដែលមានបញ្ហាគឺជាអ្វីដែលបានអះអាងរួចទៅហើយ។

លោក លោកស្រីចៅក្រម ដូចដែលបានលើកឡើងពិភាក្សាគ្នារួចមកហើយ ការអនុវត្តនៅ អ.វ.ត.ក ក៏ធ្លាប់បានទទួលយករបាយការណ៍សារព័ត៌មាន ដែលបានបំពេញតាមលក្ខខណ្ឌអប្បបរមានៃភាពពាក់ព័ន្ធ និងភាពគួរឲ្យជឿជាក់បាន ពោលគឺមាននៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះបានទទួលយកនូវរបាយការណ៍សារព័ត៌មានកម្ពុជាប្រជាធិបតេយ្យចំនួន៨៥ រួចទៅហើយ និងរបាយការណ៍

សារព័ត៌មានអន្តរជាតិចំនួន១៣៥ បានដាក់ទុកជាភស្តុតាងរួចទៅហើយ។ ការអនុវត្តនេះគឺត្រូវតាមតុលាការស្តង់ដារតុលាការអន្តរជាតិផ្សេងៗទៀត ដែលរបាយការណ៍ព័ត៌មានគឺជាញឹកញាប់ត្រូវបានទទួលយក និងជាទូទៅបានដាក់បញ្ចូលជាភស្តុតាង ចាត់ទុកថាជាឯកសារដែលមានតម្លៃ និងជាជាងសេចក្តីថ្លែងការណ៍របស់សាក្សី។ ជាពិសេសប្រសិនជារបាយការណ៍នោះបានធ្វើឡើងក្នុងអំឡុងពេលនោះពិតប្រាកដមែន។

[១០:០២:៥៧]

ឯកសារទាំងអស់នោះ នៅក្នុងក្រុមនោះ គឺបានបំពេញតាមលក្ខខណ្ឌតម្រូវ តាមកម្រិតអប្បបរមានៃភាពគួរឲ្យជឿជាក់បាន។ ដូចនេះមិនមានន័យថា មិនមានមូលដ្ឋានណាដែលថាប្រភេទឯកសារទាំងអស់នោះគួរត្រូវបានបដិសេធមិនបញ្ចូលទៅក្នុងសំណុំរឿងនោះឡើយ។ នៅក្នុងពេលដែលអវត្តមានការសង្ស័យណាមួយទៅលើភាពត្រឹមត្រូវនៃឯកសារនោះ បានន័យថា ឯកសារនោះត្រូវបានគេចាត់ទុកជាឯកសារត្រឹមត្រូវ និងគួរឲ្យជឿជាក់បាន។ ដូច្នេះចាត់ទុកថាជាភស្តុតាងដែលមានតម្លៃនៅក្នុងការពិនិត្យ និងជំនុំជម្រះរឿងក្តីនេះ។

លោក លោកស្រីចៅក្រមជាទីគោរព អ្វីដែលខ្ញុំបានលើកឡើងនេះ គឺជាការឆ្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះអ្វីដែលលោកមេធាវីការពារក្តីបានលើកឡើង ទាក់ទិនទៅនឹងបញ្ហាដូចខ្ញុំបានជម្រាបកន្លងមក។

ជាកិច្ចបន្តនេះ ខ្ញុំសូមអនុញ្ញាត-- ប្រសិនបើសហការីខ្ញុំមានអ្វីចង់បង្ហាញទៀត សូមលោកប្រធានមេត្តាអនុញ្ញាត។ ខ្ញុំបញ្ចប់ការអធិប្បាយរបស់ខ្ញុំតែប៉ុណ្ណេះ។ បាទសូមអរគុណលោកប្រធាន។ សូមអរគុណលោកស្រីចៅក្រម។ សូមអរគុណបាទ។

[១០:០៤:០៣]

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញា។

ហើយជាកិច្ចបន្តនេះ អង្គជំនុំជម្រះផ្តល់ឱកាសទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ការធ្វើការឆ្លើយតបនេះ ហើយសហមេធាវីនាំមុខមានពេលវេលា១៥នាទី ក្នុងការឆ្លើយតប។

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទសូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម លោក លោកស្រីដែលជាព្រះរាជអាជ្ញា ជាមេធាវីទាំងអស់គ្នា និងសាធារណជនដែលមានវត្តមានទីនេះ។

មេធាវីនាំមុខនឹងប្រើ-- ចំណាយពេលវេលា១៥នាទី នេះសម្រាប់ឆ្លើយតបចំពោះការលើកឡើងរបស់ខាងមេធាវីការពារក្តី។

ជាបឋមគឺពាក់ព័ន្ធទៅនឹងការជំទាស់ជាពិសេសអំពីភាពទទួលបាននៃឯកសារនេះ មេធាវីនាំមុខយល់ថា នេះគឺជាប្រព័ន្ធតុលាការមួយដែលមានចៅក្រមស៊ើបអង្កេត។ នៅក្នុងប្រព័ន្ធតុលាការដែលមានចៅក្រមស៊ើបអង្កេតនេះ គឺឯកសារទាំងអស់ដែលត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញាក្តី រកឃើញដោយចៅក្រមស៊ើបអង្កេតក្តី ដែលចៅក្រមស៊ើបអង្កេតបានយកទៅប្រើប្រាស់នៅក្នុងការតាក់តែងដីកាដំណោះស្រាយរបស់ខ្លួន។ គឺសុទ្ធតែឯកសារដែលចៅក្រមស៊ើបអង្កេតគាត់បានពិនិត្យអំពីភាពទទួលបាននៃឯកសារទាំងអស់នោះហើយ។ ហើយឯកសារទាំងអស់នេះ ប្រសិនបើចៅក្រមស៊ើបអង្កេតបានយកទៅប្រើប្រាស់នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន គឺត្រូវតែបានសន្មតថាត្រូវបានទទួលអាចយកមកប្រើប្រាស់នៅក្នុងចំពោះមុខនៅអង្គជំនុំជម្រះនេះ។

[១០:០៦:១២]

នៅក្នុងវិធានផ្ទៃក្នុងក៏ទុកសិទ្ធិឲ្យខាងការពារក្តី នៅក្នុងការលើកអំពីការជំទាស់ទៅលើភាពមិនអាចទទួលយកបាននៃឯកសារនោះនៅក្នុងអំឡុងពេលនៃសវនាការនេះ ប្រសិនបើភាគីការពារក្តីយល់ថាឯកសារនោះមិនអាចទទួល-- អាចចាត់ទុកថាអាចទទួលយកបាន។ នេះគឺជាបន្ទុករបស់ភាគីការពារក្តីនៅក្នុងការបង្ហាញថា ឯកសារនោះមិនអាចទទួលយកបាន។ វាមិនមែនជាបន្ទុករបស់ខាងព្រះរាជអាជ្ញានៅក្នុងការត្រូវបង្ហាញថាឯកសារទាំងអស់នោះត្រូវតែអាចទទួលយកបាននោះទេ។

[១០:០៦:៥៨]

ពាក់ព័ន្ធនឹងចំណុចមួយដែលជាយថាភាពនៃឯកសារ។ ខ្ញុំបាទជាការពិតគាំទ្រអំពីការលើកឡើងរបស់ខាងតំណាងសហព្រះរាជអាជ្ញា ហើយគ្រាន់តែមានការបញ្ជាក់បន្ថែមថា មានភាពខុសគ្នាអំពីយថាភាពនៃឯកសារ និងឯកសារដើម។

លោក នួន ជា និងមេធាវីរបស់លោក នួន ជា តែងតែលើកជាញឹកញយថា ឲ្យរកឯកសារដើមនៅពេលដែលសហព្រះរាជអាជ្ញាបានលើកអំពីទង់បដិវត្ត ដើម្បីយកចំណុចណាមួយនៅក្នុងឯកសារទង់

បដិវត្ត ដើម្បីសួរទៅគាត់។

ភាព-- ឯកសារដើម ហើយនិងយថាភាពមិនប្រាកដថា សុទ្ធតែតម្រូវឲ្យមានឯកសារដើមនោះទេ។ យថាភាពនេះគឺសំដៅទៅលើឯកសារមួយ គឺត្រូវបានធ្វើឡើងដោយមានភាពត្រឹមត្រូវ។ ឯកសារនោះអាចជាឯកសារដើម ហើយអាចជាឯកសារមួយដែលត្រូវបានចម្លង និងថែរក្សា ឬក៏គ្រប់គ្រងឲ្យមានលក្ខណៈត្រឹមត្រូវតាមខ្លឹមសារនៃឯកសារដើមផងដែរ។

[១០:០៨:១៥]

ដូច្នេះ ការតម្រូវឲ្យរកឯកសារដើមដែលឯកសារដើមនេះ ដែលត្រូវមានអាយុរហូតមកដល់ពេលនេះលើសពី៣០ឆ្នាំទៅហើយនោះ វាជាការលំបាកមួយ ឬក៏ថាមិនអាចធ្វើទៅកើតសម្រាប់សហព្រះរាជអាជ្ញានៅក្នុងការបង្ហាញឯកសារដើមនេះ។ ដូច្នេះ ឯកសារដែលជាឯកសារចម្លងបានត្រឹមត្រូវតាមលក្ខណៈដើម ដែលមិនមានការកែប្រែខ្លឹមសារនៃឯកសារដើម ដែលយើងអាចហៅថា "ជាឯកសារត្រឹមត្រូវ" នោះ គួរតែត្រូវបានទទួលយក។ ហើយនេះគឺជាអ្វីដែលវិធានផ្ទៃក្នុងកំណត់ថា ជាវិធានអប្បបរមានៅក្នុងការទទួលយកឯកសារ។

[១០:០៩:០៥]

ចំពោះបញ្ហានៅក្នុងការតម្រូវឲ្យមានការកោះហៅសាក្សី ឬដែលជាអ្នកដែលបានតាក់តែងឯកសារដែលជាសៀវភៅនិងជាកំណត់ហេតុផ្សេងៗ។ ការតម្រូវឲ្យមានការកោះហៅបែបនេះ វានឹងធ្វើឲ្យបន្លាយពេលនៅក្នុងសវនាការកាន់តែមានច្រើនថែមទៀត កាន់តែយូរថែមទៀត។ នេះមានន័យថា ឯកសារជាច្រើន ដែលជាសៀវភៅ ជាកំណត់ហេតុសាក្សី ជាឯកសារសរសេរដោយអ្នកកាសែតផ្សេងៗប្រសិនបើគ្រប់ឯកសារទាំងអស់ ទាំងអស់នេះត្រូវឲ្យមានការកោះហៅសាក្សី។ ថាតើនៅពេលណាដែលសវនាការរបស់យើងនឹងអាចចប់?

ដូច្នេះ រឿងក្តីនេះនឹងមិនអាចចប់នៅក្នុងរយៈពេលមួយសមស្របបានទេ។ ហើយវិធានផ្ទៃក្នុងក៏បានលើកឡើងផងដែរថា តុលាការនេះត្រូវដំណើរការនៅក្នុងរយៈពេលមួយដ៏ឆាប់រហ័សដែលអាចទទួលយកទៅបាន។ ការកំណត់ឲ្យមានការតម្រូវហៅសាក្សីមកគ្រប់ករណីបែបនេះ នឹងនាំឲ្យសវនាការនឹងបន្តទៅដោយរកផ្លូវបញ្ចប់មិនឃើញទេ។

ខ្ញុំសូមគ្រាន់តែធ្វើការបញ្ជាក់បង្ហាញពី គោលជំហរខាងមេធាវីនាំមុខតែប៉ុណ្ណេះ។ ហើយជាបន្តទៅទៀតនេះ នឹងសូមអនុញ្ញាតឲ្យលោកប្រធាន អនុញ្ញាតឲ្យលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

ដើម្បីធ្វើការថ្លែងធ្វើការឆ្លើយតបបន្ថែម។

សូមអរគុណ។

[១០:១១:០៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរអស់លោកទាំងអស់គ្នា។

ខ្ញុំនិយាយតែបន្តិចបន្តួចប៉ុណ្ណោះ ការកត់សម្គាល់ទីមួយ ទាក់ទងទៅនឹងសំណើរបស់ភាគី នួន ជា ដែលចង់ស្តាប់យកចម្លើយរបស់លោក យុ ឆាំង ហើយខ្ញុំគាំទ្រសហព្រះរាជអាជ្ញា ដែលថាការកោះហៅនៃការសហការរបស់លោក យុ ឆាំង ដែលធ្វើការនៅមជ្ឈមណ្ឌលកម្ពុជានោះ។ វាមិនជា មិន-- វាជាការគ្រប់គ្រាន់ក្នុងការពន្យល់គ្រប់គ្រាន់លើរបៀបធ្វើការរបស់មជ្ឈមណ្ឌលឯកសារនេះ។ ក៏ប៉ុន្តែទន្ទឹមនឹងនោះ ដើម្បីថាយើងចង់ធ្វើយ៉ាងម៉េចឱ្យបង្រួមបង្រួញនៃការពិភាក្សាដែលថានឹងអាចបន្ថយពេលដល់រាល់អាទិត្យ រាល់ខែទៀតនោះ លើការស្តាប់របស់លោក យុ ឆាំង ហ្នឹង ខ្ញុំគិតថាប្រហែលជាយើងនឹងអាចអញ្ជើញគាត់មកផ្ទាល់តែម្តង។

ការកត់សម្គាល់ទីពីរខ្លីទេ គឺថាទាក់ទងទៅនឹងលក្ខណៈលើការ ភាពទទួលយកបាននៃឯកសារ ហើយនេះខ្ញុំគាំទ្រសហព្រះរាជអាជ្ញាដែរក្នុងចំណុច។ ខ្ញុំគិតថា អង្គជំនុំជម្រះនឹងមាន-- នឹងកំណត់ទៅលើលក្ខណៈវិនិច្ឆ័យខ្លួនឯង ព្រោះថានេះជាសិទ្ធិអំណាចរបស់អង្គជំនុំជម្រះ។

[១០:១២:៣១]

ការកត់សម្គាល់ទីបីរបស់ខ្ញុំ ខ្ញុំគិតថាទាក់ទងទៅនឹងការបង្កើតលក្ខណៈវិនិច្ឆ័យនេះ ហើយនិងទាក់ទងទៅនឹងការរបៀបបដិសេធឯកសារនោះ។ ខ្ញុំសូមស្នើថាលើផ្លូវច្បាប់នេះ យើងត្រូវបែងចែកឱ្យច្បាស់ពីប្រភេទឯកសារពីរ គឺថាៗមានឯកសារដែលត្រូវបានត្រួតពិនិត្យដោយសហចៅក្រមស៊ើបអង្កេត ហើយៗ ឧទាហរណ៍ជាឯកសារដែលមាននៅជើងទំព័រ ឬក៏កំណត់ហេតុសួរចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សាក្សី។ នេះគឺជាប្រភេទឯកសារទីមួយ។ ហើយប្រភេទទីពីរ គឺថាជាឯកសារដែលដាក់ជូនដោយភាគី ដែលសហចៅក្រមស៊ើបអង្កេតមិនបានទទួលស្គាល់នោះទេ។

[១០:១៣:១៨]

អ៊ីចឹង យើងគិតថាការងាររបស់អង្គជំនុំជម្រះទាក់ទងទៅនឹងការពិនិត្យលើការជំទាស់លើភាពអាចទទួលយកបាននោះ គឺថាត្រូវគិត ត្រូវបែងចែកពីប្រភេទឯកសារទាំងពីរនេះ។

ខ្ញុំសូមសង្កត់ធ្ងន់ៗលើវិធានថា ធ្វើយ៉ាងម៉េចដើម្បីផ្ទៀងផ្ទាត់លើភាពម៉ត់ចត់របស់ឯកសារទាំងពីរប្រភេទនេះ។

ការកត់សម្គាល់ចុងក្រោយរបស់ខ្ញុំ គឺទាក់ទងទៅនឹងចំណុចដែលថាទាក់ទងទៅនឹងភាពទទួលយកបាន ហើយនិងទាក់ទងទៅនឹងការផ្ទៀងផ្ទាត់របស់ចៅក្រមស៊ើបអង្កេត។ ខ្ញុំយល់ឃើញថា រហូតដល់ពេលនេះ គឺថាខ្ញុំនិយាយតែចំពោះឯកសារ E3 តែប៉ុណ្ណឹងទេ។ គឺថារហូតដល់ពេលនេះ គឺថាមានការជំទាស់ដែលធ្វើដោយភាគីការពារក្ដីទាំងអស់នេះ គឺជាការជំទាស់ដែលមានលក្ខណៈទូទៅពេកហើយមិនមានជាការជំទាស់អីឲ្យច្បាស់លាស់ ហើយមានធាតុផ្សំច្បាស់លាស់ ដែលថាកំណត់ឲ្យមានថាដូចដែលអ្វីដែលបានកំណត់ដោយសហចៅក្រមស៊ើបអង្កេត ហើយគាត់បានបង្កើតជាលក្ខណៈវិនិច្ឆ័យមួយច្បាស់លាស់នោះទេ។

[១០:១៤:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

ជាកិច្ចបន្តនេះ មេធាវីការពារក្ដីទាំងបីក្រុមមានពេលចំនួន១៥នាទី ក្នុងការឆ្លើយតបនៃ-- ទៅនឹងការឆ្លើយតបរបស់សហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយដោយ១៥នាទីសរុបទាំងបីក្រុម ដូច្នេះមួយក្រុមៗ មានពេលវេលាតែប្រាំនាទីទេ លើកលែងតែក្រុមមេធាវីការពារក្ដីទាំងបីក្រុមមានការបែងចែកផ្សេងពីនេះប៉ុណ្ណោះ។

ឥឡូវសូមជម្រាបសាជាថ្មីម្ដងទៀត ដោយសារមានការខុសគ្នារវាងការប្រើពាក្យពេចន៍ ដោយសារយើងបានខិតខំក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់ថា នាពេលនេះមេធាវីការពារក្ដីទាំងបីក្រុមៗមានពេលវេលាចំនួន១៥នាទី ដើម្បីធ្វើការឆ្លើយតប បានសេចក្ដីថាមេធាវីសម្រាប់មេធាវីការពារក្ដីក្រុមនីមួយៗមានពេលវេលាតែប្រាំនាទីទេ ក្នុងការឆ្លើយតបទៅនឹងចម្លើយតបរបស់ភាគីម្ខាងទៀត គឺសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី លើកលែងតែក្រុមមេធាវីការពារក្ដីមានការបែងចែកពេលវេលាគ្នាផ្សេងពីនេះ។

ឥឡូវនេះអង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្ដី នួន ជា។ សូមអញ្ជើញ!

**លោក ហ្សាស្ដេី ប៉ោ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ មេធាវីលោកនួន ជា ប្រហែលជាប្រើ

ពេលតែប្រាំបី ឬក៏ដប់នាទីប៉ុណ្ណោះ ហើយខ្ញុំនឹងឆ្លើយតបទៅនឹងចំណុចមួយដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅព្រឹកមិញនេះ។ ហើយខ្ញុំនឹងលើកឡើងបញ្ហានេះ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីទាំងបីក្រុមគឺមានតែ១៥នាទីទេ។ ដូច្នេះក្រុមរបស់លោកមានពេលវេលាតែប្រាំនាទីទេ ក្នុងការឆ្លើយតបនេះ មិន-- ដូច្នេះសូមបញ្ជាក់ឡើងវិញ ប្រសិនបើគាត់បើប្រើពេលវេលាផ្សេងពីនេះគឺសូមធ្វើការកែសម្រួល ដើម្បីឲ្យការប្រើប្រាស់ពេលវេលាមានប្រសិទ្ធភាព។

សូមអញ្ជើញ!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណ ហើយខ្ញុំនឹងប្រើពេលតែប្រាំមីនុត ហើយខ្ញុំនឹងនិយាយបានលឿន។ បាទ ជាថ្មីម្តងទៀត យើងការិយាល័យសហព្រះរាជអាជ្ញា គឺថាបានលើកឡើងពីគោលជំហរខុសរបស់មេធាវីការពារក្តី ហើយយើងមិនបានបញ្ជាក់ថា ឯកសារទាំងអស់របស់ ឌី.ស៊ី.ខេម ត្រូវតែប្រកាសថាមិនទទួលយកបាននោះទេ ពីព្រោះថា តាមទស្សនរបស់យើងគឺថា យើងយល់ថា គ្រាន់តែអង្គការហ្នឹងមានការលម្អៀងទស្សនលម្អៀង។ ប្រសិនបើ យុ ឆាំង មិនត្រូវបានមកធ្វើសក្ខីកម្មទេ គឺថា មានតែឯកសារនោះទេ នឹងអាចនឹងត្រូវច្រានចោល។

[១០:១៨:២០]

ក្នុងគំនិតនេះ យើងយល់ថា មានជាបញ្ហាដល់ត្រឹមត្រូវដែលទាក់ទងទៅនឹងបញ្ហាឯកសាររបស់ ឌី.ស៊ី.ខេម នោះ គឺដែលថាមិនត្រូវបានចងក្រងត្រឹមត្រូវ ដោយយើងមិនបានសាកសួរលោក យុ ឆាំង ដែលថា យើងមានឯកសារជាច្រើន ទាក់ទងទៅនឹងការផ្ទេរឯកសារទៅ ឌី.ស៊ី.ខេម ជាឯកសារដ៏ច្រើនទូលំទូលាយ។ អ៊ីចឹងសំណួរដ៏ត្រឹមត្រូវនោះគឺថា តើអ្នកណាជាអ្នកកាន់កាប់ឯកសារហ្នឹងពីមុន? សំណួរមួយទៀត ទាក់ទងថាតើក្រោយមកទាក់ទងទៅនឹងរឿងនេះ ទាក់ទងទៅនឹងសម័យឯកសារដែលចងក្រងឡើងដោយមន្ត្រី ឬក៏អ្នកជំនាញក្រោយរបបខ្មែរក្រហមហ្នឹង ថាតើ ជាពិសេសអ្នកណា ដូចជាទួលស្លែងជាដើមហ្នឹង? ហើយមន្ត្រីរបស់ ឌី.ស៊ី.ខេម អាចនឹងបន្ថែមទៅលើឯកសារទាំងនេះ។

[១០:១៩:១៣]

ចំណុចចុងក្រោយទាក់ទងទៅនឹងសំណួរនេះគឺថា ឆាំង យុ ក៏បានបញ្ជាក់ផងដែរថា ដើម្បីទទួលនូវឯកសារមួយចំនួន គាត់ធ្វើការជាមួយគណៈកម្មការរបស់រដ្ឋាភិបាលរបស់លោក ហ៊ុន សែន ដោយ

ផ្ទាល់ ហើយដោយថា លោក ហ៊ុន សែន គឺថាគាត់ត្រួតត្រាលើឯកសារមួយចំនួនជាក់លាក់។ ដូច្នេះ ហើយយើងត្រូវតែមានលទ្ធភាពសួរដេញដោលលោក យុ ឆាំង អំពីបញ្ហានេះផងដែរ។

ជាថ្មីម្តងទៀតនោះ គឺថា យុ ឆាំង គប្បីតែកោះអញ្ជើញ ដោយហេតុថា គាត់ចូលរួមដោយផ្ទាល់ ទាក់ទងទៅនឹងការប្រមូលឯកសារទាំងអស់នេះ ដោយសារខ្ញុំពន្យល់ម្សិលមិញហើយថា ហើយដែលថា យើងនឹងអាចទទួលយកឯកសារនីមួយៗនោះបាន ហើយគាត់បានបញ្ជាក់នៅក្នុង D3/112 គឺថាសំណួរ ដែលសួរសហចៅក្រមស៊ើបអង្កេតនោះ ថាតើអាចផ្តល់កំណត់សម្គាល់ទូទៅលើឯកសារ និងប្រភេទ ឯកសារហ្នឹងទេ? យុ ឆាំង គាត់ឆ្លើយថា "ខ្ញុំមានកំណត់ផ្ទាល់ដៃ ប៉ុន្តែអ្នកផ្សេងទៀតមិនយល់អត្ថន័យ នេះទេ មានតែខ្ញុំទេ ដែលខ្ញុំយល់" ការបកប្រែដោយខ្ញុំ គឺយើងត្រូវស្តាប់ យុ ឆាំង ខ្លួនឯង ដើម្បីឲ្យគាត់ បញ្ជាក់ពីរឿងហ្នឹង។ ហើយបើសាក្សីផ្សេងទៀត កោះមកហៅពីរឿងនេះ គឺគេមិនអាចដឹងបានទេ ជា ពិសេសនិយាយអំពីការកាន់កាប់ ឬខ្សែចង្វាក់នៃការកាន់កាប់។ លោក យុ ឆាំង ក៏ជាមនុស្សដែលអាច នឹងពន្យល់បានច្បាស់ដែរ អំពីការកាន់កាប់នៃភស្តុតាង អំនៃឯកសារទាំងអស់នេះ ហើយជាពិសេស នឹងភាពជឿជាក់បាននៃឯកសារនោះផងដែរ។

[១០:២០:៤៦]

ចំណុចចុងក្រោយដែលខ្ញុំចង់បញ្ជាក់នោះ គឺថាតុលាការក៏មិនត្រូវតែយកចិត្តទុកដាក់ទៅលើការ កាន់កាប់ឯកសារទេ ក៏យើងត្រូវផ្តោតទៅលើការឆ្លើយថាភាពៗនៃឯកសារនោះផងដែរ វាទំនងជាថា ការិយាល័យសហព្រះរាជអាជ្ញាក៏យល់ថា ឯកសារហ្នឹងយកជាការបាន ដោយហេតុថា គេមានជា អង្គការមួយវា ត្រូវមានយថាភាព។ អ៊ីចឹងការបកប្រែ ជាការបកស្រាយនោះ គឺថាមិនអាចកំណត់បែប ហ្នឹងបានទេ ពីព្រោះថា យុ ឆាំង មិនទាន់បានបញ្ជាក់ថាហ្នឹងមានយថាភាពនៅឡើយទេ។

ដូច្នេះជាការចាំបាច់ណាស់ ជាការសួរ យុ ឆាំង អំពីការបណ្តុះបណ្តាលរបស់គាត់ អំពីចំណេះ ដឹងរបស់គាត់ វិធីសាស្ត្រ ហើយនិងអ្វីដែលគាត់ពន្យល់បានអំពីការសរសេរទះដៃរបស់គាត់ យើងអាច នឹងធ្វើកោសល្យវិច័យលើសំណេរហ្នឹងទៅទៀតទើបបានជាក់ច្បាស់។

[១០:២១:៣៥]

អ៊ីចឹងមានតែគាត់ទេ ដែលអាចនឹងបញ្ជាក់ថាអាហ្នឹង ឯកសារហ្នឹងពិត មិនពិត ឬក៏មានយថា ភាព ដែលគាត់ត្រូវបញ្ជាក់។

ដូចដែលខ្ញុំជម្រាបតុលាការម្សិលមិញ គឺថានៅដំណាក់កាលនេះ គឺថាការធ្វើតេស្តខាងកោសល្យ វិច័យនេះ គឺថានឹងត្រូវធ្វើដើម្បីបង្ហាញថាតើឯកសារហ្នឹងមានយថាភាពពិតប្រាកដដែរឬអត់? បើសិនជាគាត់មិនអញ្ជើញមកទេ មិនមានអ្នកណាអាចបញ្ជាក់ពីវិធីសាស្ត្ររបស់គាត់ ដែលគាត់ធ្វើនោះបានទេ។

ដូច្នេះដើម្បីសង្ខេបពីជំហររបស់យើង ប្រសិនបើយើងមិនបានការបំភ្លឺនេះទេ វិធីសាស្ត្ររបស់ ឌី.ស៊ី.ខេម ទៅលើឯកសារផ្សេងៗដែលទទួលបាននោះគឺថាបើយើងមិនបានស្តាប់ យុ ឆាំង ទេ យើងមិនអាចទុកថាឯកសារនោះអាចមានយថាភាព អាចជឿជាក់បាន ដូចជាឯកសារតុលាការនោះទេ លុះត្រាតែយើងដឹងថា វិធីសាស្ត្រ ការបញ្ជាក់អ្វីជាដំណើរការត្រឹមត្រូវនៃការគ្រប់គ្រង។ មានតែវិធីនោះទេដែលយើងអាចឲ្យតុលាការមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការសម្រេចថា ភស្តុតាងហ្នឹងមានយថាភាព អាចជឿជាក់បាន ធ្វើជាភស្តុតាងនៅក្នុងតុលាការ។

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

[១០:២២:៥០]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីការពារក្តីលោក អៀង សារី។ សូមអញ្ជើញ!

**លោក ម៉ៃខល ការណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងសវនាការទាំងមូល។ សូមអភ័យទោស ខ្ញុំនិយាយត្រូវលឿនបន្តិច ដោយហេតុថា ខ្ញុំមានពេលតិចពេក ហើយយើងមានរឿងច្រើនដែលត្រូវនិយាយ។

ជាបឋមយើងមើលទៅត្រឡប់ក្រោយ ដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយអំពីបទដ្ឋានអប្បបរមាដែលប្រើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតទាក់ទងទៅនឹងឯកសារថាវាមានយថាភាពមានភាពជឿជាក់បាន ហើយវាមានភាពពាក់ព័ន្ធ។ តើបទដ្ឋានអ្វី? យើងដាក់សំណើជាច្រើន ហើយគេបានឃើញ ហើយវិធីសាស្ត្រ ហើយនិង*ម៉ូដាលវិធី* គឺថាបែបបទនៃការងារ។ ក៏ប៉ុន្តែ អូ.ស៊ី.អាយ.ជេ ការិយាល័យចៅក្រមស៊ើបអង្កេត គឺថាមិនបានបញ្ជាក់ទេក្នុងការធ្វើតេស្តអំពីយថាភាព ឬភាពជឿទុកចិត្តបាននូវឯកសារភស្តុតាងទាំងអស់នោះ។

ដូច្នេះយើងគ្រាន់តែនិយាយថា ក.ស.ជ.ស ហ្នឹង គឺថាគ្រាន់តែបានលើកឡើងអំពីគំនិតមួយ ដូចដែលថា អ្វីដែលមិនបានគ្រប់គ្រាន់ នេះជាពាក្យរបស់ខ្ញុំ។ អ៊ីចឹងហើយ គឺថាជាដូចជាការតស៊ូទៅវិញទៅមកទាក់ទងទៅនឹងនៅអង្គ ឬក៏ស្ថាប័ននៃតុលាការមួយនេះ។ ខ្ញុំមិនគិតថាយើងគ្រាន់តែ មិនអាចនិយាយថាភាពជឿជាក់បានទាំងមូលនៃស្ថាប័ននោះទេ។ បើសិនជាយើងពិនិត្យមើលឯកសារហ្នឹង គឺថាយើងមាននៅមានចម្ងល់។

[១០:២៤:២១]

ខ្ញុំសូមអនុញ្ញាតនិយាយអំពី ឧទាហរណ៍ដោយសង្ខេប ដែលលើកឡើងដោយសហព្រះរាជអាជ្ញាជាតិ ដែលលោកលើកឡើងថា តាមទស្សនៈរបស់ខ្ញុំ គឺថាយើងពិនិត្យឃើញថា ជាសំណើដាក់ដើម្បីបង្ហាញភស្តុតាង គឺគ្រាន់តែដាក់ឯកសារដែល ដោយមិនច្បាស់លាស់ ដែលថាមិនជឿ មិនមានមូលដ្ឋានផង គាត់ថាមានយថាភាព ហើយគាត់បានអះអាងថាខ្លឹមសារ គឺស្របជាមួយឧទាហរណ៍អំពីឃ្លា ឃ្លោងទាំងឡាយ ដែលយើងមាន។ នេះហើយជាសក្ខីកម្ម ជាសម្ដីរបស់គាត់។ អានេះជាសំណើសុំដាក់ភស្តុតាងដែលសហព្រះរាជអាជ្ញាជាតិលោកលើកឡើង ប៉ុន្តែជាក់ស្តែង ជាសេចក្ដីសន្និដ្ឋាននោះ គឺតាមវិធីមួយ គឺថាពាក្យ ឬក៏ឃ្លាទាំងអស់នេះ គឺវាស្របជាមួយនឹងបុគ្គលម្នាក់ៗ ឬក៏អង្គការ ស្ថាប័ននោះដែរឬទេ? បើវាពិតអ៊ីចឹងមែន ហេតុអ្វីក៏យើងមិនហៅបុគ្គលទាំងអស់នោះឲ្យមកបង្ហាញថាហេតុអីបានស្រប ឬក៏មិនស្របទៅក្នុងកម្រិតណាមួយនៃភស្តុតាង? ការគ្រាន់តែដាក់នូវសំណើ ឬក៏សេចក្ដីសន្និដ្ឋានដែលថាខ្លួនចង់ស្នើដាក់នូវភស្តុតាងដែលថាវាមិនគ្រប់គ្រាន់បែបនេះនោះ។ នេះហើយគឺជាចំណុចមួយ ខ្ញុំពិនិត្យឃើញថាសហព្រះរាជអាជ្ញា គឺគាត់បានស្នើសុំដាក់ភស្តុតាង ប៉ុន្តែគាត់ចង់ប្តូរបន្ទុកនៃការភស្តុតាងទៅមេធាវីការពារវិញ។

អ៊ីចឹងខ្ញុំសូមស្នើដល់តុលាការថា ហើយយើងវាត្រូវធ្វើផ្ទុយពីហ្នឹងទៅវិញទេ គឺសហព្រះរាជអាជ្ញាទេជាអ្នកមានបន្ទុកក្នុងការផ្តល់បង្ហាញភស្តុតាង មិនមែនមេធាវីការពារទេ។

[១០:២៥:៥៨]

ពីម្សិលមិញនោះ យើងបានឮរឿងក្តី *ប្រលឹក* នៅក្នុងតុលាការអន្តរជាតិដែលថា ជារឿងគេថា *ដេហ្សាក្វ* គឺថាដូចជារឿងថ្មីមួយសម្រាប់ខ្ញុំ ដែលលោកលើកឡើងបែបនេះ ហើយនៅក្នុងនីតិវិធីដែលនឹងប្រើនៅក្នុងរឿងក្តីនោះ *ប្រលឹក* ហ្នឹងនៅក្នុងសវនាការ គេហៅថាប្រតិបក្ស។ ប៉ុន្តែយើងនេះគឺជាប្រព័ន្ធ

តុលាការចម្រុះ។ ឥឡូវនេះខ្ញុំស្នើដាក់ភស្តុតាង ក៏ប៉ុន្តែសូមឲ្យសេចក្ដីសម្រេចទាំងអស់នេះ គឺវាទាក់ទងនឹងភាពអាចទទួលយកបាននៃភស្តុតាង។

សហព្រះរាជអាជ្ញាត្រូវតែបង្ហាញនូវសាក្សីមួយចំនួនដែលចាំបាច់ មិនចាំបាច់តែ គឺថាខ្សែចង្វាក់នៃការកាន់កាប់ទេ ក៏ប៉ុន្តែឯកសារហ្នឹង វា*ជឿញាន(?)* វាពិតប្រាកដទេ វាត្រឹមត្រូវទេ ហើយនិងសេចក្ដីសន្និដ្ឋាននៃសក្ខីកម្មសាក្សី បន្ទាប់មកសហព្រះរាជអាជ្ញាក៏បានសំណើថាឲ្យប្រើឯកសារនេះ។ អ៊ីចឹងហើយមេធាវីការពារជំទាស់។ អ៊ីចឹងហើយតុលាការជំនុំជម្រះសាលាដំបូង គឺត្រូវពិនិត្យនូវឯកសារនៅក្នុងពេល គឺថាពេលវេលាមានកម្រិត បែរជាលោកថា ហៅសាក្សីមិនបានទេ។ អ៊ីចឹងថាតើចៅក្រមអាចនឹងសម្រេចម្ដេចបាន បើគ្រាន់តែលោកស្នើបែបនេះ ហើយភាគីមិនអាចស្នើមកបញ្ជាក់បាន ហើយថាឲ្យតុលាការសម្រេចទៅ។ នេះហើយគឺថាដំណើរការមួយខុសគ្នាស្រឡះពីគោលការណ៍ដែលយើងប្រើនៅទីនេះ បើសិនជាយើងនិយាយអំពីស្ដង់ដារអន្តរជាតិវិញ ខ្ញុំមិនគិតថាស្ដង់ដារនោះគឺថាសហព្រះរាជអាជ្ញាអះអាងបែបនេះនោះទេ។

[១០:២៧:២៨]

យើងគ្រាន់តែគិតថា សូមឲ្យតុលាការពិនិត្យមើលភាពពាក់ព័ន្ធ។ អ៊ីចឹងហើយយើងសន្និដ្ឋានថាពាក់ព័ន្ធតែមើលតែឯកសារលើក្រដាស។ ប៉ុន្តែភាពទុកចិត្តបាន ហើយខ្លឹមសារហ្នឹងគឺជាកត្តាមួយដែលថា អាចសម្រេចទៅពេលក្រោយ ហើយបន្ទាប់មកទៅនឹងកត្តាវាស់ថ្លឹងថ្លែង។ នេះមិនមែនជាករណីទេ ហើយខ្ញុំទទួលស្គាល់ថា ការបំពេញបន្ថែម។ ប៉ុន្តែយើងស្ដាប់អំពីការតទល់បែបបណ្ឌិតសភាពីម្សិលមិញ គឺថានេះជាកត្តាសំខាន់ណាស់ ខ្ញុំបានពន្យល់ ប៉ុន្តែខ្ញុំមិនមានស្នើថាសុំឲ្យតុលាការចាត់តាំង ឬក៏អ្នកណាឲ្យបញ្ជាក់ថា យថាភាព ឬក៏ថាឲ្យបញ្ជាក់ថាទុកចិត្តបានទេ។ ប៉ុន្តែបើអនុវត្តបែបនេះ គឺថាវាកត្តាមួយដែលឆាប់រហ័ស ដូចដែលយើងខ្ញុំបានស្នើបែបនោះ។ ត្រូវតែមានវិធីសាស្ត្រមួយជាក់លាក់ ដើម្បីឲ្យតុលាការពិនិត្យមើលភស្តុតាងទាំងអស់នេះ ដើម្បីឲ្យសម្រេចបានថា ចេញពីស្ថាប័នមួយ ថាតើមានសញ្ញានេះ មានរូបសញ្ញាបណ្ណនេះចេញមកពីកន្លែងណា? ពីសហព្រះរាជអាជ្ញា ថាតើអាចទុកចិត្តបានមានយថាភាពទេឯកសារហ្នឹង វាគ្រប់គ្រាន់ដែរឬទេ?

[១០:២៨:៤០]

នៅទីបំផុតហ្នឹង ទាក់ទងទៅនឹងអត្ថបទសារព័ត៌មាន ហើយនិងកាសែតផ្សេងៗនោះវិញ។ ជាពិសេសដូចជា ចំណុចពីរចុងក្រោយរបស់ខ្ញុំ។ នៅក្នុងតុលាការខ្លះ អង្គជំនុំជម្រះខ្លះ ហើយខ្ញុំជឿជាក់ថា

ក្នុងរឿង ស្កាឃីក រឿងក្ដីរបស់ ស្កាឃីក នោះ គឺថាសេចក្ដីសម្រេចរបស់ចៅក្រម ផាកឃ័រ ដែលជាប្រធាននៅក្នុងរឿងក្ដីមួយនេះ មិនបានទុកចិត្តទៅលើសារព័ត៌មាន អត្ថបទសារព័ត៌មាននោះទេ។ អង្គជំនុំជម្រះនៅក្នុងករណីនោះ ក៏បានសម្រេចថាមិនគ្រប់គ្រាន់ទេឯកសារបែបនោះ។ ហើយខ្ញុំមិនអាចយល់ទេនៅក្នុងរឿងក្ដីនេះ ក្នុងសាលាក្ដីនេះ ហើយយើងអាចចង់មើលអត្ថបទសារព័ត៌មានទាំងអស់នោះ នេះគឺគ្រាន់តែ គឺថាអ្នកសរសេរ ដូចជា វ៉ាស៊ីនតោនប៉ុស្ដិ៍ ឬក៏សារព័ត៌មានណាមួយ យើងទុកចិត្តបានភ្លាម ហើយយើងអាចប្រើថាអាហ្នឹងអាចបញ្ជាក់ការពិតបាននោះទេ។

[១០:២៩:៣៤]

នៅទីបំផុតនៅក្នុងចំណុចចុងក្រោយរបស់ខ្ញុំ លោក លោកស្រីចៅក្រម ទាក់ទងទៅនឹងករណីឌុច ក្នុងរឿងក្ដីឌុច ខ្ញុំមិនបាននៅក្នុងរឿងក្ដីឌុចនោះទេ។ មេធាវីផ្សេងទេ ជាអ្នកការពារ ជាអ្នកតំណាង គេមានយុទ្ធសាស្ត្រផ្សេង ហើយគេបាន គាត់បានសម្ដែងការសារភាពពីពិរុទ្ធភាពរបស់គាត់នៅក្នុងដំណើរការជំនុំជម្រះក្នុងការកំណត់ថា តើគាត់មានពិរុទ្ធភាព ឬអត់? នេះជាប្រព័ន្ធច្បាប់ស៊ីវិលឡូ។ ក៏ប៉ុន្តែការនិយាយថាធ្វើបែបនេះដោយសារមានការសម្រេចនៅក្នុងរឿងក្ដី ឌុច យើងមកក្នុងរឿងក្ដីនេះម៉េចនឹងត្រូវកើត។ ខ្ញុំសូមគោរពតុលាការពិនិត្យមើលតេស្ដផ្សេងពីនោះ នៅក្នុងរឿងក្ដីនេះជារឿងក្ដីថ្មី ហើយយើងត្រូវមើលភស្តុតាងទាំងអស់ចេញពីបទដ្ឋានផ្សេង។ ខ្ញុំនៅទីនេះ ខ្ញុំការពារលោក អៀង សារី ខ្ញុំមានសេរីភាពក្នុងជំទាស់ក្នុងនាមគាត់ ហើយខ្ញុំនឹងស្នើសុំឲ្យព្រះរាជអាជ្ញាបង្ហាញបទដ្ឋានអប្បបរមាក្នុងការបញ្ជាក់ភស្តុតាងទាំងហ្នឹង។ មិនមែនខ្ញុំទេ គឺកូនក្ដីរបស់ខ្ញុំ លោក អៀង សារី មិនត្រូវផ្ដន្ទាទោសដោយសារតែមេធាវី ឌុច សម្រេចចិត្តថា មិនមែនជាអត្ថប្រយោជន៍របស់ខ្លួនទេ មិនមែនតែក្នុងទ្រឹស្ដីរបស់គាត់ ខ្លួនមិនបានជំទាស់ឯកសារ យកទ្រឹស្ដីនោះមកអនុវត្តក្នុងរឿងក្ដីនេះមិនអាចត្រឹមត្រូវទេ។

[១០:៣០:៥៧]

នេះជាទីបញ្ចប់ដែលថា នេះមិនមែនគ្រប់គ្រាន់សម្រាប់ពេលប៉ុណ្ណោះទេ ក៏ប៉ុន្តែខ្ញុំសូមថ្លែងអំណរគុណដែលតុលាការបានផ្ដល់ឱកាសឲ្យខ្ញុំធ្វើសេចក្ដីសន្និដ្ឋានឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាចុងក្រោយនេះអង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្ដីលោកខៀវ សំផន។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការ។ ខ្ញុំបាទសូមធ្វើការជំទាស់ចំពោះការថ្លែងរបស់សហព្រះរាជអាជ្ញា ដែលថាសមត្ថភាពក្នុងការពិនិត្យឯកសារក្នុងរយៈពេលបួនឆ្នាំកន្លងមកនេះ គឺគ្រប់គ្រាន់សម្រាប់ឲ្យមេធាវីការពារពិនិត្យ។ ប៉ុន្តែការពិតវាមិនដូច្នោះទេ ខ្ញុំលើកកាលពីលើកមុនហ្នឹង គឺមានមូលដ្ឋាន ហើយមូលដ្ឋានដែលខ្ញុំនិយាយនេះ គឺថាយើងជាមនុស្សក្នុងសមត្ថភាពជាមនុស្ស មិនមែនជាទេវតា មិនមែនជាគ្រឿងម៉ាស៊ីន ហើយការពិនិត្យឯកសារវាមានភាពដែលអាចធ្វើទៅបាន។ ម្យ៉ាងទៀត សហព្រះរាជអាជ្ញាបានលើកដោយច្រឡំថា ឯកសារដែលគាត់មានរាប់ពាន់ឯកសារនោះ គឺកើតឡើងក្នុងពេលតែមួយ គឺតាំងពីបួនឆ្នាំមុន បានន័យថា មានឯកសាររាប់ពាន់ឆ្នាំក្នុងពេលតែមួយ តែជាក់ស្តែងវាមិនដូច្នោះទេ។

[១០:៣២:២៣]

ឯកសារវាកើតឡើង បានដាក់បញ្ចូលជាបន្តបន្ទាប់ ហើយមានបញ្ហាត្រូវការបកប្រែភាសា ហើយមេធាវីការពារមិនមានសមត្ថភាពពិនិត្យទៅលើភាសាគ្រប់ជ្រុងជ្រោយ។ នោះក៏ជាបញ្ហាដែលមានការលំបាកក្នុងការពិនិត្យទៅលើឯកសារជាលម្អិតដែរ។

ទីពីរ ទាក់ទងទៅនឹងកម្រិតនៃការ ឬក៏ជាមូលដ្ឋាននៃការវាស់ភស្តុតាងដែលសហព្រះរាជអាជ្ញាបានលើកអម្បាញ់មិញថា រឿងក្តីនេះវាជារឿងក្តីធំ ដូច្នេះមូលដ្ឋាន ឬក៏កម្រិតក្នុងការពិនិត្យភស្តុតាងនេះ វាអាចមានកម្រិតទាបជាងរឿងក្តីធម្មតា អាចឲ្យតុលាការពិនិត្យ ទោះបីថា រឿងក្តីនោះ-- ភស្តុតាង ឬ ឯកសារទាំងអស់នោះមិនជាប់ពាក់ព័ន្ធក្នុងកម្រិតខ្ពស់ក៏ដោយ។

[១០:៣៣:១១]

ការលើកឡើងនេះ ពុំមានភាពជាមូលដ្ឋានផ្នែកច្បាប់ទេ ពីព្រោះថា បើយើងនិយាយអំពីការទទួលយកភស្តុតាងវាត្រូវតែអនុវត្តស្មើគ្នាទាំងអស់កម្រិតនៃការទទួលយកភស្តុតាង ទោះបីរឿងក្តីតូចក៏ដោយ រឿងក្តីធំក៏ដោយ។ ម្យ៉ាងទៀតសម្រាប់រឿងក្តីធំបែបនេះ គួរតែមានការពិនិត្យពិចារណាដិតដល់លម្អិតជាជាងរឿងក្តីតូចតាចទៀតផង។

ទាក់ទងនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាដែរថា ឌី.ស៊ី.ខេម បានដើរតួនាទីដូចជាប៉ូលិសក្នុងតុលាការធម្មតា នៅក្នុងនីតិវិធីធម្មតា ដែលថាយើងដឹងអាចទទួលស្គាល់ថា ប៉ូលិសប្រហែលជាមានភាពលម្អៀង អីចឹងឯកសារដែលប៉ូលិសបានធ្វើមិនគួរយកមកពិចារណា ឬមួយយ៉ាងម៉េច?

[១០:៣៤:០៧]

ជាការពិតណាស់គឺថាប៉ូលិស ឬនគរបាល គាត់មានតួនាទី សមត្ថកិច្ចក្នុងបែបបទជាសាធារណៈ ជាផ្លូវការដើម្បីការពារក្តីផលប្រយោជន៍សាធារណៈ។ ដោយឡែកចំពោះ ឌី.ស៊ី.ខេម អង្គការឯកសារកម្ពុជា គាត់មានលក្ខណៈជាឯកជន។ ក៏ប៉ុន្តែបម្រើ អាចថាបម្រើផលប្រយោជន៍សាធារណៈដែរ ដោយថាគាត់រក្សាទុកនូវឯកសារ ប៉ុន្តែមិនមែនធ្វើឡើងក្នុងលក្ខណៈជាផ្លូវការទេ។ អ៊ីចឹងអាការប្រៀបធៀបរបស់សហព្រះរាជអាជ្ញាក្នុងចំណុចនេះ មិនមានអ្វីជំទាស់ថា ក្រុមប្រឹក្សាជំនុំជម្រះនៅពេលនេះមិនអាចកោះហៅលោក ឆាំង យុ ដើម្បីឆ្លើយបំភ្លឺបានទេ ទោះបីនគរបាលនៅក្នុងយុត្តាធិការនៃតុលាការធម្មតាព្រហ្មទណ្ឌជាតិក៏ដោយ ក៏នគរបាលតម្រូវឲ្យមកឆ្លើយបំភ្លឺនៅចំពោះមុខតុលាការដែរ។ ដូច្នេះ លោក ឆាំង យុ ក៏ត្រូវតែមកឆ្លើយបំភ្លឺចំពោះមុខសវនាការនេះ ដូចគ្នាដែរ។

ទាក់ទងទៅនឹងការប្រើប្រាស់ពេលវេលា លោកសហព្រះរាជអាជ្ញា ក៏ដូចជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកថា បើសិនជាហៅសាក្សីមកច្រើនដើម្បីបំភ្លឺបញ្ហានេះ អាចធ្វើឲ្យខាតពេលវេលាច្រើន មិនដឹងថាពេលណានឹងសវនាការនេះនឹងត្រូវចប់។ ក៏ប៉ុន្តែបើយើងផ្អែកទៅលើការស្វែងរកយុត្តិធម៌ មិនមែនសំដៅទៅលើការមិនប៉ាន់ចំណាយនូវពេលវេលានេះទេ។ ពេលវេលាចំណាយដើម្បីយុត្តិធម៌ វាជារឿងដែលយើងត្រូវធ្វើ ហើយបើសិនជាយើងមិនដឹងការពិត ថាតើឯកសារនោះវាមានភាពជឿជាក់ប៉ុនណា? អាចយកជាការបានប៉ុនណា? ហើយយើងគិតថា ខ្វះពេល ដូច្នេះចេះតែឲ្យចៅក្រម ក្រុមប្រឹក្សាជំនុំជម្រះយកមកពិចារណាធ្វើការសម្រេច អ៊ីចឹងបានន័យថាយើងសម្រេចទៅលើឯកសារដែលមិនត្រឹមត្រូវមិនមានមូលដ្ឋានច្បាស់លាស់។

[១០:៣៦:២១]

ជាក់ស្តែង ខ្ញុំបាទសូមលើកឧទាហរណ៍ ការលើកឡើងរបស់សហព្រះរាជអាជ្ញាជាតិអម្បាញ់មិញនេះថា លោក ខៀវ សំផន ធ្លាប់ធ្វើជាប្រធានប្រមុខរដ្ឋ។ល។ ដូច្នេះគ្រាន់តែយើង-- គ្រាន់តែអម្បាញ់មិញនេះ បើយើងគិតមែនទែនទៅសហព្រះរាជអាជ្ញាគាត់មានការងារធ្វើរហូតដល់ទៅបួនឆ្នាំកន្លងមកហើយ។ ថាតើកូនក្តីខ្ញុំធ្លាប់ជាប្រធានប្រមុខរដ្ឋដែរឬទេ? គឺអត់មានទេ គឺគាត់ធ្វើប្រធានគណៈប្រធានរដ្ឋ មិនមែនប្រធានប្រមុខរដ្ឋទេ។ អាហ្នឹងខ្ញុំគ្រាន់តែចង់លើកបញ្ជាក់ថា ការភ័ន្តច្រឡំវាអាចកើតមានអ៊ីចឹង។ ចុះទម្រាំអ្នកកាសែតគាត់ទៅបានព័ត៌មានពីណាមក? ព័ត៌មានច្បាស់ទេ? អ្នកកាសែតខ្លះជា

អ្នកកាសែតបរទេស គាត់យកព័ត៌មានមកមិនច្បាស់ គាត់ធ្វើសេចក្ដីរាយការណ៍។ អ៊ីចឹងវាធ្វើឲ្យមានការភ័ន្តច្រឡំចំពោះអត្ថបទរបស់គាត់ដែរ។

[១០:៣៧:១៨]

ឧទាហរណ៍មួយទៀត សហព្រះរាជអាជ្ញាជាតិបានលើកថា លោក ខៀវ សំផន ធ្លាប់ធ្វើជានាយករដ្ឋមន្ត្រីស្ដីទី តែការពិតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ ក៏ដូចជាក្រោមក្នុងសម័យតស៊ូពីសម័យមុន៧៥ លោក ខៀវ សំផន មិនដែលធ្វើជានាយករដ្ឋមន្ត្រីស្ដីទីអ្វីទាំងអស់។ ក៏ប៉ុន្តែមានព័ត៌មានមានកាសែតសរសេរថា លោក ខៀវ សំផន ធ្លាប់ធ្វើជានាយករដ្ឋមន្ត្រីស្ដីទី។ អានេះហើយវាជាចំណុចខ្វះខាត បើសិនជាយើងមិនបានពិនិត្យទៅលើការស៊ើបម្រៅនៃការទទួលបាននូវព័ត៌មានទាំងអស់នោះទេ មិនអាចបញ្ជាក់ថា តើព័ត៌មាននោះត្រឹមត្រូវក្នុងកម្រិតណានោះទេ។

[១០:៣៨:០៣]

មួយទៀត យើងមានបញ្ហាជាច្រើន ដែលខ្ញុំបានលើកពីម្សិលមិញនូវចំណុចជាក់លាក់ទៅលើភស្តុតាងមួយចំនួន ឯកសារមួយចំនួន ក៏ប៉ុន្តែសហព្រះរាជអាជ្ញាគាត់មិនបានលើកមកបង្ហាញអំពីចំណុចខ្វះខាតទាំងអស់នោះថា តើមានមែន ឬក៏មិនមែននោះនៅឡើយដែរ។

ជាសរុបសេចក្ដីមកគឺថា ការទាមទារដើម្បីពិនិត្យទៅលើភាពត្រឹមត្រូវនៃឯកសារទាំងឡាយដែលដាក់ជូនចំពោះក្រុមប្រឹក្សាជំនុំជម្រះនៅពេលនេះ គឺជាការចាំបាច់បំផុតសម្រាប់បញ្ជាក់ពីភាពច្បាស់លាស់ដែលអាចទទួលយកបានសម្រាប់ឲ្យក្រុមប្រឹក្សាជំនុំជម្រះ ធ្វើសេចក្ដីសម្រេចចិត្តបានដោយត្រឹមត្រូវ និងយុត្តិធម៌។

បើសិនជាមិនបានទទួលនូវការបញ្ជាក់ឲ្យបានច្បាស់ពីប្រភពឯកសារក្ដី ពីមធ្យោបាយនៃការថែរក្សាទុកឯកសារក្ដី ពីភាពដែលជឿជាក់នៃខ្លឹមសារនៅក្នុងអត្ថបទទាំងនោះក្ដី ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើសេចក្ដីសម្រេចដោយពុំមានយុត្តិធម៌ឡើយ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសមល្មមនឹងឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:៣៩ នាទី ដល់ម៉ោង ១១:០១ នាទី)*

[១១:០១:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តទៅនេះ យើងបន្តធ្វើសវនាការលើការជំទាស់ទៅនឹងឯកសារនានា។ កាលពីម្សិលមិញ និងព្រឹកមិញនេះ យើងបានស្តាប់សេចក្តីជំទាស់ពាក់ព័ន្ធទៅនឹងឯកសារទាំងឡាយដែលអង្គជំនុំជម្រះបានចាត់ថ្នាក់ជាប្រភេទឯកសារ E3។

ជាដំបូងនេះ អង្គជំនុំជម្រះសាលាដំបូងនឹងស្តាប់សេចក្តីជំទាស់ពាក់ព័ន្ធនឹងឯកសារក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលអង្គជំនុំជម្រះសាលាដំបូងមានបំណងដាក់ចំពោះមុខខ្លួន។ អនុលោមតាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងអនុស្សរណៈ E199។ ជាដំបូងនឹងស្តាប់ការជំទាស់ទៅនឹង E159។ ជាដំបូងយើងនឹងស្តាប់ការជំទាស់លើឯកសារប្រភេទ A1។

អង្គជំនុំជម្រះផ្តល់វេទិកាពេលវេលាចំនួនពីរម៉ោងទៅមេធាវីការពារក្តីទាំងបីក្រុមដើម្បីលើកឡើងនូវសេចក្តីជំទាស់របស់ខ្លួន។ ការបែងចែកពេលវេលាពីរម៉ោងនេះ គឺអាស្រ័យទៅលើក្រុមមេធាវីការពារក្តីនីមួយៗពិភាក្សាក្នុងការបែងចែកពេលវេលា។

ផ្ទុយទៅវិញ ប្រសិនបើក្រុមមេធាវីទាំងបីក្រុមមិនមានការបែងចែកពេលវេលាគ្នាទេនោះ មេធាវីក្រុមនីមួយៗមានរយៈពេល៤០នាទី។ ហើយប្រសិនបើមេធាវីមានការបែងចែកពេលវេលាដោយឡែកពីនេះ សូមប្រាប់មកអង្គជំនុំជម្រះ តែប្រសិនបើមិនមានការបែងចែកពេលវេលាទេនោះ គឺមួយក្រុមមានពេលវេលា៤០នាទី។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសូមប្រគល់នាទីនេះទៅមេធាវីការពារក្តី នួន ជា មុនគេ។

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន គ្រាន់តែ សូមអនុញ្ញាតជម្រាបជូនលោកប្រធានថា ពាក់ព័ន្ធទៅនឹងបញ្ហា A1 មេធាវីនាំមុខផ្តល់សិទ្ធិទៅលោក បាណាបេ ណេគ្វី ដើម្បីធ្វើបទអន្តរាគមន៍ពាក់ព័ន្ធនឹងប្រធានបទនេះ។ សូមអរគុណលោកប្រធាន។

[១១:០៥:៤៣]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីការពារក្តីជាតិនៃមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់ព័ត៌មាននេះមុនគេ។ ហើយអង្គជំនុំជម្រះយល់ព្រមតាមការស្នើសុំនេះ។ សូមវេទិកាទៅមេធាវីការពារក្តីលោក នួន ជា។

សូមអញ្ជើញ!

[១១:០៥:០៦]

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមជម្រាបសួរលោកស្រីចៅក្រម ខ្ញុំនឹងលើកឡើងការជំទាស់ជាទូទៅទាក់ទងទៅនឹងឯកសារឧបសម្ព័ន្ធទីមួយ ហើយខ្ញុំនឹងប្រើពេលតែ១៥នាទីទេ ច្រើនបំផុត។ ខ្ញុំដឹងថា លោក សុន អរុណ មិនមានមតិទេ។ ដូច្នេះ ពេលនេះប្រហែលជាតែ១៥នាទីសម្រាប់ខ្ញុំ ហើយខ្ញុំនឹងចាប់ផ្តើម ហើយនិងសេចក្តីយោងទៅនឹងសេចក្តីសន្និដ្ឋានដែលខ្ញុំបានលើកឡើងពីម្សិលមិញ គឺថាទាក់ទងនឹងបញ្ហាទូទៅ ដែលលើកឡើងព្រឹកនេះផងដែរ។ ហើយនិងការលើកឡើងនូវឯកសារ ឌី.ស៊ី.ខេម ដែលលើកឡើងកាលពីម្សិលមិញល្ងាចនោះ។

[១១:០៥:៥០]

យើងសូមស្នើថា ការជំទាស់ទាំងអស់នោះ ដែលយើងលើកឡើងពីម្សិលមិញ គឺថាត្រូវអនុវត្តគ្រប់ករណីទាំងអស់ សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ គឺថាឧបសម្ព័ន្ធមួយ ហើយនិងឯកសារទាំងអស់ដែលដាក់ជូនអង្គជំនុំជម្រះ។ ហើយខ្ញុំក៏យោងទៅរកឯកសារ 109 ឧបសម្ព័ន្ធមួយនៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាហ្នឹង គឺថាសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ។ តាមអ្វីដែលខ្ញុំយល់ គឺថាមានសេចក្តីថ្លែងការណ៍១៩ របស់លោក នួន ជា ដែលនៅក្នុងចំណោមឯកសារ២០០ ឯកសារ គឺថា ១៩ឯកសារនេះ វាមានអនុប្រភេទមានប្រាំពីរជាសុន្ទរកថាកម្ពុជាប្រជាធិបតេយ្យ ហើយបទសម្ភាសន៍

១០ ហើយមានសំបុត្រមួយចំនួន ហើយនិងមានឯកសារ អូ.ស៊ី.អាយ.ជេ ការិយាល័យសហចៅក្រម ស៊ើបអង្កេត។ ហើយខ្ញុំនឹងជំទាស់ជាក់លាក់។

[១១:០៦:៥២]

លោក ផេសមិន បានលើកឡើងពីម្សិលមិញរួចហើយ ទាក់ទងទៅនឹងឯកសារនៅក្នុងបញ្ជីនេះ ដែលថាជាឯកសារប្រាំបួននៅក្នុងឧបសម្ព័ន្ធទីមួយ ហើយក៏ដែលនិយាយអំពីលោក ខឹម ងុន ជាចារបុរសរបស់លោក ហ៊ុន សែន លេខប្រាំបួននោះហើយ គឺយើងនឹងប្រកាន់គោលជំហរជំទាស់បែបនោះដដែល។

ឯកសារពីរនៅក្នុងបញ្ជីនេះ បទសម្ភាសន៍ពីរនិយាយជាក់លាក់ គឺថាលេខ១៥នៅក្នុងបញ្ជី D366/7.1.164 ហើយឯកសារ១៦នៅក្នុងបញ្ជី IS-- បាទហើយជាបទសម្ភាសន៍ពីរដោយមិនធ្វើ--ធ្វើឡើងដោយយើងមិនអ្នកស្គាល់ឈ្មោះទេ។ ដោយអ្នកកាសែតជប៉ុន ហើយយើងបញ្ជាក់ថាឯកសារពីរនេះ មិនបានបំពេញតាមគោលការណ៍ ដែលថាភស្តុតាងដំបូងនោះទេ ហើយយើងជំទាស់ឯកសារទាំងនោះ ថាមិនត្រូវទទួលយកមកដាក់ជាភស្តុតាងជាបានការនោះទេ។

ជាទូទៅ ទាក់ទងទៅនឹងសេចក្ដីថ្លែងការណ៍ ឬចម្លើយទាំងអស់នេះនៅក្នុង១៩នេះ យើងស្នើតុលាការថា ក្នុងកម្រិតដែលអង្គជំនុំជម្រះមានចេតនា និងពឹងផ្អែកណាមួយនៃឯកសារនោះ គឺថាដែលទាក់ទងទៅនឹងអំពើ ឬក៏អត្តចរិតរបស់ជនជាប់ចោទ គឺថាឯកសារទាំងនោះត្រូវតែយកឯកសារពិតមកតុលាការហើយសុំឲ្យលោក នួន ជា ជំទាស់ ឬក៏ឆ្លើយតប។ បើសិនជាគាត់ជំទាស់ទាក់ទងទៅនឹងយថាភាព ឬក៏កត្តាអ្វីផ្សេងទៀត យើងនឹងស្នើឲ្យតុលាការអញ្ជើញអ្នកដែលសម្ភាសន៍នៅក្នុងឯកសារនោះ គឺថាត្រូវអញ្ជើញមកសួរដេញដោលតទល់ដោយផ្ទាល់នៅទីនេះ។

[១១:០៨:៤៨]

ខ្ញុំនិយាយអំពីបញ្ហាដែលលើកឡើងពីម្សិលមិញ និងថ្ងៃនេះ គឺថា ដែលថាអាចនឹងធ្វើឲ្យគាំងសវនាការ ប្រសិនបើយើងធ្វើបែបនេះ។ អ៊ីចឹង ត្រឹមតែឯកសារ១៩ ប៉ុណ្ណឹង មិនអាចធ្វើសវនាការរាំងស្ទះនោះទេ។ គឺថាមិនអាចថាជំទាស់បានទេ គឺថាបើសិនជាមានឯកសារច្បាប់ដើម គឺថាយើងត្រូវតែយកមក លោក នួន ជា នៅទីនេះ គាត់អាចនឹងបញ្ជាក់ថាឯកសារនេះត្រូវតែមាន ហើយដាក់តទល់ចំពោះមុខគាត់ផងដែរ។

ចំពោះឯកសារមួយទៀត គឺថានៅក្នុងលេខ១១នៃបញ្ជី ហើយមិនមានឯកសារ-- មិនមានលេខទេ នេះគឺគ្រាន់តែសំបុត្រដែលបញ្ជូនចេញពី នួន ជា ទៅលោក ហ៊ុន សែន ជាឧទាហរណ៍។ ឯកសារនោះក៏ត្រូវដាក់តទល់ជាមួយ នួន ជា ដើម្បីឲ្យគាត់ផ្តល់មតិយោបល់ បើសិនជាគាត់ជំទាស់ ពេលនោះគឺថាត្រូវកោះអញ្ជើញលោក ហ៊ុន សែន មកតុលាការ។ បើសិនជាចង់ពឹងផ្អែកទៅលើឯកសារលិខិតមួយនេះនោះ។

[១១:០៩:៥១]

ប្រភេទពិសេសមួយទៀត គឺថានៅចុងពីរ គឺថាឯកសារ១៨, ១៩ នៅក្នុងបញ្ជីនេះ គឺថា C8 ហើយ D20។ ឯកសារពីរនេះត្រូវបានរៀបចំឡើងដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងគាត់បង្ហាញខ្លួនជាបឋម ហើយកំណត់ត្រានេះគឺថា នៅក្នុងសវនាការតទល់នេះ នៅពេលដែលគាត់ឃុំខ្លួន គឺថាយើងមិនជំទាស់ទៅនឹងឯកសារទាំងនេះទេ ជាឯកសារសំណុំរឿង ហើយយើងទទួលស្គាល់ថា សេចក្តីថ្លែងការណ៍ធ្វើឡើងដោយ អូ.ស៊ី.អាយ.ជេ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា លោក នួន ជា ពេលដែលគាត់ធ្វើសេចក្តីថ្លែងការណ៍នោះ គឺថាមិនមានមេធាវីតំណាងទេ។ តាមដែលខ្ញុំចាំត្រឹមត្រូវនោះគឺថា លោក សុន អរុណ មិនទាន់បានចាត់តាំងត្រឹមត្រូវនៅឡើយទេ ហើយគាត់មិនបានចូលរួមទេ ហើយមិនមានមេធាវីអន្តរជាតិវត្តមានទេនៅពេលនោះ មិនទាន់បានចាត់តាំង។ ហើយសហចៅក្រមស៊ើបអង្កេតគឺថា មិនមានឱកាសណាមួយ ហើយចៅក្រមអង្កេតបែរជាកំណត់ថា លោកនួន ជា បោះបង់សិទ្ធិក្នុងការមានមេធាវី ហើយមិនបានជូនដំណឹងពីសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបនោះទេ។

[១១:១១:០៤]

ដូច្នេះហើយ សូមលោក លោកស្រីតុលាការពិនិត្យមើល ពិចារណាឯកសារទាំងអស់នេះឡើងវិញ។ ប៉ុន្តែយើងស្នើថា ត្រូវពិចារណាលើកាលៈទេសៈជុំវិញនៃករណីនេះ។ ជាឧទាហរណ៍ ប្រសិនបើជម្រើសរបស់តុលាការក្នុងការវាយតម្លៃ ឬក៏ថ្លឹងថ្លែងនេះ ក៏ត្រូវពិនិត្យមើលថា ក្នុងករណីនេះលោក នួន ជា មិនមានមេធាវីតំណាងទេ។ ការដែលបញ្ជាក់ថា គាត់បោះបង់សិទ្ធិនោះគឺមិនជាការត្រឹមត្រូវទៅតាមនីតិវិធីច្បាប់ទេ។

[១១:១១:៣៤]

ទាក់ទងនឹងឯកសារផ្សេងទៀត ដូចខ្ញុំបានជម្រាបនោះ យើងប្រកាន់នូវជំហរដូចដែលលោក នួន ជា បានអះអាងថា ឯកសារផ្សេងៗទៀត ២២០ ទៅដល់ ២២២ ហ្នឹងគឺថា វាទាក់ទងទៅនឹងជនជាប់

ចោទនោះ ហើយយើងនឹងប្រកាន់ជំហរទូទៅក្នុងកម្រិតមួយដែលថា អង្គជំនុំជម្រះពឹងផ្អែកលើឯកសារណាមួយនោះ ហ្នឹងគឺថា ដែលជាឯកសារពាក់ព័ន្ធទៅនឹងអំពើ និងអត្តចរិតរបស់ជនជាប់ចោទ អាចនឹងធ្វើដូច្នេះបាន គប្បីតែកោះអញ្ជើញសាក្សី ហើយនិងទុកឲ្យជនជាប់ចោទអាចនឹងតទល់ទៅលើអ្នកទាំងនោះ ដើម្បីអាចចាត់ទុកថា ឯកសារហ្នឹងអាចនឹងយកមកដេញដោលបាន។

[១១:១២:១៩]

តាមពិត ដែលខ្ញុំសូមអរគុណ បើសិនជាសហសេវិករបស់ខ្ញុំមានមតិ អាចនឹងប្រើពេលនេះបាន ដូច្នេះ ខ្ញុំសូមអរគុណអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកមេធាវីការពារក្តី នួន ជា។ ហើយជាបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកាទៅមេធាវីការពារក្តីលោក អៀង សារី ដើម្បីបង្ហាញនូវសេចក្តីជំទាស់របស់ខ្លួន។

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរ លោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងអង្គសវនាការទាំងមូល។ អ្វីដែលច្រើន ដែលខ្ញុំផែនការនៅក្នុងរៀបចំនៅពេលនេះ គឺថាបានពិភាក្សារួចមកហើយពីម្សិលមិញ ហើយនិងថ្ងៃនេះ នៅក្នុងការបដិសេធចុងក្រោយរបស់ខ្ញុំ ហើយខ្ញុំនឹងនិយាយសង្ខេបទេពេលនេះ។

ខ្ញុំមិនពិនិត្យឃើញថា ដែលខ្ញុំពិនិត្យមើលឯកសារនីមួយៗនោះទេ។ យើងនៅចាំថា នៅថ្ងៃទី៥ មករា ឆ្នាំ២០១២ យើងបានដាក់នូវសេចក្តីជំទាស់ សំណើជំទាស់មួយ ដែលមានសេចក្តីលម្អិត រួមទាំងឧបសម្ព័ន្ធផងដែរ នៅពេលដែលយើងមានឯកសារមួយចំនួន ដែលសហព្រះរាជអាជ្ញាបានលើកឡើង ហើយយើងបានផ្តល់សេចក្តីលម្អិត ជាការឆ្លើយតបទៅជាឯកសារបញ្ជាក់ច្បាស់ៗ ដោយអាស្រ័យទៅលើប្រភេទនៃឯកសារដែលយើងជំទាស់។

[១១:១៣:៥១]

ហើយយើងបានកំណត់នូវការឆ្លើយតបជាទូទៅ ដែលថាចាំបាច់សម្រាប់ករណីនេះ។ ហើយយើងបានការឆ្លើយតប-- យើងបានកែប្រែការឆ្លើយតបដើម្បីឲ្យវាឆ្លុះបញ្ចាំងពីឯកសារនីមួយៗ ដូចខ្ញុំកត់សម្គាល់ពីម្សិលមិញ សហព្រះរាជអាជ្ញាបានដាក់ទាំងដុំ អ្វីៗទាំងអស់ចូលនៅក្នុងប្រភេទតែមួយ

ដែលគាត់បញ្ជាក់នៅក្នុងទឡ្ហីករណ៍របស់គាត់ដូចជា ទស្សនាវដ្ដី-- អត្ថបទសារព័ត៌មាន កាសែត ដូចជាសុន្ទរកថាដែលអះអាងថា លោក អៀង សារី បានអាននោះ ជាសេចក្ដីថ្លែងការណ៍។

តាមពិតយើងខ្ញុំយល់ឃើញថា ការជំទាស់ដំបូងរបស់ខ្ញុំគឺថា ដំបូងបំផុតសូមឱ្យសហព្រះរាជអាជ្ញាឱ្យច្បាស់លាស់ អ្វីដែលខ្លួនអះអាងថា តើជាអត្ថបទសារព័ត៌មាន ជាសេចក្ដីថ្លែងការណ៍អន្តរជាតិ ជាអត្ថបទសារព័ត៌មាន តើកាលៈទេសៈនោះអ្វីខ្លះ?

ជាឧទាហរណ៍ ប្រសិនបើយើងមើលឧទាហរណ៍មួយនៅក្នុងចំណុចនេះ គឺយើងឃើញថា ឯកសារ D312.2.8។ នេះជាការអះអាងដែលថា ជាឯកសារសេចក្ដីថ្លែងការណ៍របស់លោក អៀង សារី។ ប៉ុន្តែនៅពេលដែលយើងមើលទៅ គឺជាអត្ថបទសារព័ត៌មានទេ ដូចដែលយើងបញ្ជាក់ម្សិលមិញ បើមានឧបសម្ព័ន្ធអ្វី លើកលែងតែយើងមានឱកាសក្នុងការតទល់បុគ្គល ដែលសង្ខេប ឬក៏អ្នកដែលសរសេរអត្ថបទសារព័ត៌មាន ឬក៏ប្រើពាក្យរៀបរាប់ពីលោក អៀង សារី ហ្នឹង គោលជំហរចម្បងរបស់យើងខ្ញុំ គឺថាភស្តុតាងនោះ គឺមិនត្រូវតុលាការទទួលយកទេ។ បើសិនតុលាការទទួលយកត្រូវតែដាក់ឱ្យមានការថ្លឹងថ្លែងនូវតម្លៃ ហើយត្រូវមើលកត្តាចង្អុលបង្ហាញពីតម្លៃនោះ មានការធ្វើតេស្តពីកត្តានោះផង។

[១១:១៥:៥០]

ខ្ញុំជូនឧទាហរណ៍មួយផ្សេងទៀត ទាក់ទងនឹងករណីបែបនេះដែរ។ នៅទីនេះឯកសារ D366/7.1.633 នេះជាគេកំណត់ប្រភេទថា ជាសេចក្ដីថ្លែងការណ៍របស់លោក អៀង សារី នៅក្នុងអត្ថបទសារព័ត៌មានវ៉ាស៊ីនតោនប៉ុស្ដិ៍ គឺថាការបញ្ជាបិទផ្លូវច្រកចូលនៅកម្ពុជា។ នេះជាអត្ថបទសារព័ត៌មានដែលសរសេរដោយ អេលីហ្សាប៊េត បេកយ័រ ដែលទាក់ទងទៅនឹងករណីដែលអង្គហេតុនោះ។ ប៉ុន្តែយើងមិនមានមតិយោបល់ជាក់ស្ដែងរបស់ អៀង សារី ទេ ប៉ុន្តែជាសម្ដីរបស់អ្នករាយការណ៍សារព័ត៌មានគាត់សរសេរ។ ដូច្នេះយើងត្រូវសួរ ថាតើហេតុអ្វីបានជាវាមានកត្តាសំខាន់ដែលគេអះអាងថា ជាកត្តាសំខាន់ថាឯកសារនេះ វាទាក់ទងទៅនឹងលោក អៀង សារី?

[១១:១៦:៤៩]

ខ្ញុំសូមស្នើថា ឱ្យពិនិត្យមើលអត្ថបទសារព័ត៌មានរបស់ អេលីហ្សាប៊េត បេកយ័រ នៅក្នុងទស្សនាវដ្ដីវ៉ាស៊ីនតោនប៉ុស្ដិ៍ ខែកញ្ញា ឆ្នាំ១៩៧៥ រហូតទៅដល់មានការបោះពុម្ពផ្សាយដោយប្រើខ្លឹមសារ អ្វីដែល បេកយ័រ អះអាងថា ជាសម្ដីរបស់ អៀង សារី ថាជាភស្តុតាងសារវន្តជាសារធាតុ។ ដូច្នេះយើងយល់ថា មិនអាចទុកចិត្តបាន ហើយក៏មិនគប្បីតុលាការទទួលយកថាជាភស្តុតាងនោះដែរ។ តាមពិតប្រសិនបើ

អេលីហ្សាប៊ែត គាត់មកធ្វើសក្ខីកម្មគាត់ត្រូវបង្ហាញថា អត្ថបទនេះអ្នកណាជាអ្នកសរសេរ? ហើយឲ្យគាត់ផ្តល់ភស្តុតាង ថាតើអង្គជំនុំជម្រះអាចយល់ឃើញថា ជឿថា អត្ថបទមួយនេះ និងខ្លឹមសាររបស់វា ឬក៏កម្មវត្ថុនៃសារព័ត៌មាននេះ មានការទាក់ទងដែរឬទេ? ហើយយើងសន្និដ្ឋានថា ប្រសិនបើវាពិតជាអ៊ីចឹងមែន បន្ទាប់មកយើងនឹងអាចមានសិទ្ធក្នុងការតទល់ នៅក្នុងហេតុការណ៍ដែលមានចែងនៅក្នុងករណីហ្នឹង។ ហើយអាកប្បកិរិយារបស់អាមេរិកាំង ដែលថាសហរដ្ឋអាមេរិក ដែលថាគេបន្តការងារហ្នឹង ដូចថា គេធ្វើការវាយប្រហារខាងពាក្យសម្តី។ គេនិយាយថា មិនមានការរងគ្រោះអ្វីទេ ចំពោះជនដែលអាមេរិកាំងចាប់បាននោះ។ គឺថាមានតែការបាត់បង់កងទ័ពអាមេរិកទេនៅទីនោះ។

[១១:១៨:២៣]

ប៉ុន្តែ យើងមិនមានអ្វីដែលថា ត្រូវធ្វើទាក់ទងទៅនឹងថា តើអ្វីជាករណីពិសេសនៅសាលាក្តីនេះទេ ខ្ញុំគ្រាន់តែលើកឡើងថា ជាឧទាហរណ៍មួយតែប៉ុណ្ណឹងទេ។ ដោយហេតុថា ឧបសម្ព័ន្ធរបស់យើងខ្ញុំមិនចង់ពិនិត្យមើលឧទាហរណ៍នីមួយៗទេ លោកចៅក្រម។ ប៉ុន្តែយើងធ្វើការជំទាស់ លោកស្រីចៅក្រមមានហើយ ហើយខ្ញុំគិតថា ខ្ញុំត្រូវប្រើពេលនេះឲ្យល្អ ដើម្បីជូនជាឧទាហរណ៍ ជាគំរូមួយដើម្បីឲ្យលោកចៅ លោកស្រីចៅក្រមអនុវត្តនូវវិធីសាស្រ្តណាមួយដែលត្រូវប្រើសម្រាប់ថ្លឹងទម្ងន់នៃឯកសារនេះ។

[១១:១៩:០៣]

ឧទាហរណ៍មួយទៀតនោះ គឺថាឯកសារ 366/7.1.363 នេះជាឯកសារ នេះមានចំណងជើងថាសេចក្តីថ្លែងការណ៍របស់ អៀង សារី ភ្នំពេញ វិទ្យុផ្សាយសំឡេងក្នុងស្រុក សុន្ទរកថានិយាយពីការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេស។ នេះជាសេចក្តីដកស្រង់ដែលដកស្រង់ពីសេចក្តីប្រកាសរបស់វិទ្យុ។ បើដោយយើងសន្និដ្ឋានទៅ គឺថាជាការផ្សាយរបស់វិទ្យុ យើងមិនដឹងទេ ថាផ្សាយរបៀបណា។ ដូច្នេះបើសិនជាត្រូវការប្រើ គឺថាត្រូវតែមានភស្តុតាងពីសហព្រះរាជអាជ្ញា បង្ហាញថាទាក់ទង ថាតើឯកសារមួយនេះ តើខ្លួនចង់អះអាងថា ជាឯកសារអ្វី? តាមពិតយើងមិនស្នើអ្វីដែលថា ធ្វើទៅមិនបាននោះទេ។

ខ្ញុំសូមជូនលោកចៅក្រមអំពីឧទាហរណ៍មួយទៀត។ មានឧទាហរណ៍អំពី D56/124 ដែលគេអះអាងថា សេចក្តីថ្លែងការរបស់ អៀង សារី ដែលគេបានសម្ភាសដោយ *ផល ស្តាយហ្គេន (Pal Steigan)* ហើយនិង *អ៊ីឌី (Eide)* មកពីតំបន់របបកុម្មុយនីស្ត-- បក្សកុម្មុយនីស្ត ហើយយើងស្នើឲ្យតុលាការថា នេះមិនមែនជាសេចក្តីថ្លែងការណ៍ទេ។ នេះជាអត្ថបទបកប្រែមួយផ្នែកៗនៃសៀវភៅដែលនិយាយពីការវាយប្រហារដោយវៀតណាមមកលើកម្ពុជា។ ជាក់ស្តែងយើងមិនគិតថា មានតម្លៃជា

ភស្តុតាងទេនៅក្នុងពេលនេះ។ ជាពិសេសដោយហេតុថា ពីព្រោះថា គឺវាផ្អែកទៅលើហេតុផល ឬក៏ផលវិបាកនៃព្យសនកម្មមួយដែលថា សហព្រះរាជអាជ្ញាអាចនាំមកនូវអ្នកនិពន្ធនៃអត្ថបទនេះ ឬក៏អ្នកបកប្រែនោះ ដើម្បីបញ្ជាក់នៅក្នុងកម្រិតមួយឲ្យច្បាស់ ថាតើអ្វីជាលក្ខណៈជាក់ស្តែងនៃសេចក្តីថ្លែងការណ៍ ប្រសិនបើគេប្រមូលសេចក្តីថ្លែងការណ៍ហ្នឹងពីលោក អៀង សារី ដើម្បីឲ្យយើងអាចនឹងសួរដេញដោលតទល់គ្នាចំពោះសក្ខី-កម្មមួយនេះ ដែលថាវាជាការបកប្រែជាភាសាអង់គ្លេសមួយផ្នែកនៃសៀវភៅនេះ ដែលមិនអាចបកស្រាយថា ជាខ្លឹមសារដែលលោក អៀង សារី បាននិយាយនោះទេ។ បើយើងពិនិត្យមើល គឺវាមិនគ្រប់គ្រាន់ទេ តែចំណុចនេះ-- ឧទាហរណ៍មួយទៀត ជូនតុលាការ។

[១១:២០:០៩]

នេះជាឧទាហរណ៍ចុងក្រោយ លោកស្រីចៅក្រម អាចនឹង-- យើងបានផ្តល់សេចក្តីសន្និដ្ឋាន និងសំណើពិស្តាររួចហើយ ដូច្នេះខ្ញុំមិនចាំបាច់លើកទាំងអស់នោះទេ គ្រាន់តែលើកមួយចំនួន។ គឺឯកសារ D366/7.1.5 ទំព័រទី៩ ហើយសហព្រះរាជអាជ្ញាបានដាក់ថា សេចក្តីថ្លែងការណ៍របស់ អៀង សារី, អៀង ធីរិទ្ធ ហើយនៅក្នុងឯកសារ អ៊ីម៉ែល មកពី ភីតធ័រ ម៉ាខ្វៃអ៊័រ *(Peter McGuire)* ហើយក៏បន្តប្រតិចារឹកថា ឯកសារកម្ពុជាប្រជាធិបតេយ្យ។ ហើយយើងមើលឯកសារជាក់លាក់មួយនេះ យើងនឹងឃើញថា យើងក៏ត្រូវចោទសំណួរថា ហេតុអ្វីបានជាបង្ហាញឯកសារបែបនេះ? យើងមិនដឹងពីមូលហេតុ។

[១១:២៣:០៥]

នេះជាឯកសារមួយ គឺថាវាក្រៅពីយុត្តាធិការពេលវេលានៃ អ.វ.ត.ក ហើយមិនគប្បីដាក់ចូលទេ នេះជាសំណើរបស់យើងខ្ញុំ គឺថាឯកសារហ្នឹងមិនសមស្របនឹងបង្ហាញពីភស្តុតាងពីអង្គហេតុដែលត្រូវផ្តល់ទេ ជាឯកសារអ៊ីម៉ែលផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលអ្នកសរសេរនោះបានផ្តល់នូវសេចក្តីលម្អិតដែលគាត់អាចធ្វើបែបនោះបាន។ ប៉ុន្តែយើងសូមស្នើតុលាការថា ប្រសិនបើឯកសារនេះចូលមកដល់ដៃតុលាការ វាត្រូវតែមានការបង្ហាញពីមូលហេតុថា ឯកសារនេះខ្លួនឯងមកតាមរបៀបណា? ថាតើខ្លឹមសារហ្នឹងត្រូវប្រើដោយសហព្រះរាជអាជ្ញា ត្រូវតែបង្ហាញភស្តុតាងពីអ្វីមួយ ហើយត្រូវតែបញ្ជាក់នៅក្នុងដីកាដំណោះស្រាយ។ បើមិនមានផ្តល់ជាអត្ថប្រយោជន៍ដល់ជនជាប់ចោទទេ ដើម្បីសួរដេញដោលអ្នកនិពន្ធឯកសារហ្នឹងទេ ដែលថាអ្នកនោះក៏នៅរស់ នៅមាន ហើយយើងក៏អាចធ្វើបាន បើខកខាន មិនបានដូច្នេះ គឺថាបើយើងប្រើអ៊ីម៉ែលទៅ-- ដែលផ្ញើទៅលោក យុ ឆាំង បែបនេះ ជាឧទាហរណ៍ ដែល

ចាប់ផ្តើមឡើងដោយខ្លឹមសារថា "លោក យុ ជាទីគោរព! ខាងក្រោមនេះជាសេចក្តីដកស្រង់ដែលលោក អៀង សារី, អៀង ធីរិទ្ធ និយាយពីបញ្ហាមួយដ៏គួរឲ្យអស់សំណើច"។ ហើយខ្ញុំនឹងមិនអានតទៅទៀតទេ ប៉ុន្តែខ្ញុំត្រូវតែមានសិទ្ធិនឹងសួរដេញដោលមតិដែលគេសរសេរបែបហ្នឹង។ សូមឲ្យតុលាការកោះឯកសារនេះ យកមកដាក់ដេញដោល។ បើមិនផ្តល់ឱកាសឲ្យមេធាវីការពារ ឬ អៀង សារី ដើម្បីសួរដេញដោល ឬសួរខ្វែងទៅនឹងម្ចាស់ឯកសារនេះទេ គឺថាខ្ញុំយល់ឃើញថាជាការមិនសមស្របទេ ដូចដែលខ្ញុំបញ្ជាក់ព្រឹកមិញនេះគឺថាយើងមិនពិនិត្យឯកសារទាំងអស់ទេ។ ប៉ុន្តែនៅក្នុងឯកសារ ប៉ុន្តែខ្លឹមសារខ្លះនៅក្នុងនុ៎ង ក៏ត្រូវតែបង្ហាញពីភាពពាក់ព័ន្ធនូវអ្វីដែលស្ថិតនៅក្នុងដីកាដំណោះស្រាយ ដែលថាឯកសារខ្លះឯងបើមិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីឲ្យទទួលស្គាល់ថាជាឯកសារទេ។ ហើយព្រះរាជអាជ្ញាមិនអាចនិយាយថា អ្នកឯងកុំព្រួយអំពីយថាភាព និងភាពទទួលយកទេ គឺយើងនឹងចូលទៅដល់ភាព ឬក៏ការអនុវត្តការថ្លឹងថ្លែងដោយចៅក្រមទេ។ ពេលនោះ គឺយើងអាចវាយតម្លៃភស្តុតាងបាន ប៉ុន្តែយើងសូមស្នើតុលាការថា មុននឹងទទួលឯកសារបែបនេះ ដែលកំណត់ឈ្មោះខុសថាជាសេចក្តីថ្លែងការណ៍ តាមពិតវាមិនមែនជាសេចក្តីថ្លែងការណ៍ទេ។

[១១:២៥:៥២]

មិនគប្បីដាក់ចូលទៅក្នុងឯកសារទេ លើកលែងតែសហព្រះរាជអាជ្ញារៀបចំពន្យល់អំពីភាពជឿទុកចិត្តបាននៃឯកសារនិងចម្លើយភស្តុតាង។ ឧទហរណ៍ថា យើងយកអត្ថបទមួយមកពីញូវយ៉កប៉ុស្តិ៍ ។ ហើយយើងនឹងជំទាស់ថា ឯកសារនេះមិនមាននៅក្នុងសារព័ត៌មាន។ អ៊ីចឹង ក្នុងករណីហ្នឹងយើងមិនជំទាស់ពីយថាភាពទេ គឺថាបើយើងដាក់ញូវយ៉កប៉ុស្តិ៍ ជាអត្ថបទសារព័ត៌មានមក យើងនឹង-- ឧទាហរណ៍ វ៉ាស៊ីនតោនប៉ុស្តិ៍ ឬក៏ ញូវយ៉កថាមស៍ ជាអត្ថបទសារព័ត៌មានជាច្បាប់ចម្លង។ ប៉ុន្តែខ្លឹមសារដែលនៅក្នុងនោះទេ ដែលជាបញ្ហា។ តើគួរឲ្យទុកចិត្តបានទេ នៅក្នុងន័យដែលថា ដែលគេចុះហ្នឹង ឬក៏អត្ថបទសារព័ត៌មានហ្នឹងគឺថាវាអះអាងជាហេតុការណ៍អីមួយ? ថាតើវាចូលមកដោយស្វ័យប្រវត្តិបើយើងយកជាផ្នែកមួយនៃភស្តុតាង អាហ្នឹងជាភស្តុតាងពាក្យចចាមអារ៉ាម។

[១១:២៦:៥២]

ថាតើវាអាចបង្ហាញពីការពិតតាមគោលបំណងតុលាការ តាមទិសដៅដែលចូលមកទេ ឬក៏យើងច្រានចោល? យើងសូមស្នើថា គោលការណ៍បែបនេះ គឺថាសហព្រះរាជអាជ្ញា បើព្យាយាមចង់បង្ហាញភស្តុតាងថាតើអត្ថបទសារព័ត៌មាននេះពិតជាទាក់ទងដែរឬទេ? ទីពីរ គឺថាសំខាន់បំផុត ប្រសិនបើ

អត្ថបទសារព័ត៌មាននោះ ដូចជាអត្ថបទរបស់ ប៊ែកយ័រ មានសេចក្ដីដកស្រង់អំពីសេចក្ដីថ្លែងការណ៍របស់ អៀង សារី។ ចុះអសេចក្ដីផ្សេងទៀត ក្នុងនោះគាត់និយាយថាអីខ្លះ? តើគេសួរគាត់ពីអី? តើគាត់ឆ្លើយជាក់ស្ដែងនោះម៉េច? វាក្រៅពីការកត់ត្រាសម្រួលដែល អេលីហ្សាប៊ែត ប៊ែកយ័រ កត់នោះ? ហើយអ្នកនិពន្ធនាយកពិនិត្យមើលគាត់កែទៀត អីទៀត។ អ៊ីចឹងគឺថា តើយើងទុកចិត្តអានីតិវិធីហ្នឹង គឺថាតើមានកំហុសប៉ុនណា? ដែលមាននៅក្នុង-- តើសារព័ត៌មានបោះពុម្ពផ្សាយហ្នឹងវាឆ្លុះបញ្ចាំងពីសម្ដីពិតរបស់គាត់ដែរឬទេ? នេះជាខ្លឹមសារនៃមាត្រានៃអត្ថបទនោះ គឺថាបើអាចថាជាឈាននៃការចោទប្រកាន់ជាការអះអាង អាហ្នឹងវាខុសគោលបំណងនៃតុលាការនៃការស្វែងរកយុត្តិធម៌ការពិតហើយ។

ដូច្នេះយើងនឹងពិនិត្យមើល តើវាមានអត្ថន័យម៉េច? ខ្លឹមសារម៉េចទាំងស្រុង? មិនយកតែសេចក្ដីដកស្រង់នោះទេ។ ដើម្បីជាសេចក្ដីសរុប យើងខ្ញុំសូមទទូចសុំឱ្យតុលាការពិនិត្យមើលគ្រប់ឧបសម្ព័ន្ធទាំងអស់ ហើយយើងនឹងធ្វើការជំទាស់លើអ្វីៗដែលយើងជឿជាក់ថា ប្រភេទឯកសារនេះមិនគប្បីដាក់ចូលទេ។ ដោយយើងជឿជាក់ថា ដែលថាត្រូវតែមានការធ្វើតេស្តផ្ទៀងផ្ទាត់ជាមុនសិនក្នុងការពិនិត្យឯកសារទាំងអស់ជាមុនសិន។

[១១:២៨:៣៨]

ហើយយើងខ្ញុំស្នើថា នីតិវិធីដ៏ល្អបំផុត ដ៏ល្អនៅទីនេះដែលសហព្រះអាជ្ញាត្រូវកំណត់អត្តសញ្ញាណនរណាជាសាក្សីដែលខ្លួនជឿថា អាចបង្ហាញជាមូលដ្ឋានគ្រឹះទាក់ទងទៅនឹងកំណត់ប្រភេទនៃឯកសារ? ថាតើជាតេឡេក្រាម ទូរលេខ ឬជាកំណត់ហេតុអង្គប្រជុំ ឬក៏ឯកសាររបស់ យូ.អ៊ិន។ ប្រសិនបើមានបញ្ជីបែបនោះ ប្រហែលជាសហព្រះរាជអាជ្ញាត្រូវអញ្ជើញឱ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅបុគ្គលទាំងអស់នោះនៅពេលណាមួយ គឺឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន ឬក៏នៅពេលណាមួយដើម្បីឱ្យគាត់កំណត់ពីមូលដ្ឋានគ្រឹះដ៏សមស្រប។ ប្រសិនបើធ្វើបែបនោះបាន ប្រហែលជាយើងមិនត្រូវអនុវត្តលំបាកអ្វីជាងហ្នឹងទៀតទេ។ ដូចជាទាក់ទងទៅនឹងលោក ឆាំង យុ វិញ ដោយហេតុថាឯកសារមួយចំនួនច្រើនដែលថាស្ថិតនៅក្នុងសំណើរបស់សហព្រះរាជអាជ្ញា ដែលខ្លួនបានលើកឡើង ដែលខ្ញុំហៅថាអាហ្នឹងគឺជាការស្នើសុំដាក់ឯកសារមកទេ។ គឺគាត់បានពឹងផ្អែកទាំងស្រុងទៅលើលោក ឆាំង យុ ហើយនិង ឌី.ស៊ី.ខេម ហើយយើងស្នើថាវាមិនគ្រប់គ្រាន់ទេ។ ឯកសារទាំងអស់នេះវាមកពី ឌី.ស៊ី.ខេម មែន ក៏ប៉ុន្តែភាពប្រាកដ ថាតើទុកចិត្តបានដែរឬទេ? ជឿបានឬទេ? ដោយហេតុថាឯកសារហ្នឹងមកចេញមកពីបណ្ណសារ។ នោះមិនមែនមានន័យថា ឯកសារនោះមានយថាភាពជឿជាក់បាននោះទេ។ លើក

លែង ហើយលុះត្រាណាតែមានភស្តុតាងពីបណ្ណសារថា ពិនិត្យចម្រាញ់ដោយខ្លួនឯង ហើយកំណត់ថាឯកសារណាមួយមានយថាភាព ហើយទុកចិត្តបាន។

[១១:៣០:៣៣]

អ្វីជាធម្មតាដែលកើតឡើងនៅក្នុងបណ្ណាសារគឺថា បង្កើតឡើងដោយ ឌី.ស៊ី.ខេម ហ្នឹងគឺគ្រាន់តែប្រមូលហើយនិងកត់ត្រាទុក។ ដូច្នេះ ការងាររបស់គាត់នោះគឺតាមពិត គាត់ៗបានពិនិត្យមើលគ្រាន់តែត្រួតពិនិត្យចម្រាញ់ បន្ទាប់មកគាត់-- ហើយគ្រាន់តែបញ្ជាក់ប៉ុណ្ណឹងថា ត្រូវយកមកប្រើនៅតុលាការ។ ដូច្នេះជាឯកសារដែលនិយាយថា អ្ហូក! នេះឯកសារមួយគ្រប់គ្រាន់។ ពេលនោះមេធាវីការពារថា នោះមិនគ្រប់គ្រាន់ទេ លើកលែងតែអ្នកបង្ហាញភស្តុតាងឲ្យច្បាស់ពីកត្តាបង្ហាញថា តើអត្ថបទនោះយកមកពីណា? ឯកសារនោះយកមកពីណា? សេចក្តីដកស្រង់ពីថ្លែងការណ៍របស់ អៀង សារី ហ្នឹងដកពីកន្លែងណា? អាស្រុងផ្សេងទៀតនៅកន្លែងណា? ឬក៏ការសម្រួលឃ្លាដែលលោក អៀង សារី បាននិយាយនោះវាឃ្លាដើមនោះយ៉ាងម៉េច? អានេះយើងចង់ដឹងឲ្យច្បាស់បែបនេះ។

[១១:៣១:២៩]

យើងខ្ញុំស្នើថា ដោយមានលក្ខខណ្ឌ បដិបញ្ញត្តិ-- មុបដិបញ្ញត្តិមួយដែលថា លើកលែងតែយើងមានកត្តាចង្អុលបង្ហាញដោយឯករាជ្យក្នុងការបញ្ជាក់សុពលភាពឲ្យបានច្បាស់ទេ។ បើមិនដូច្នោះទេ ការអះអាងថាលោក អៀង សារី បាននិយាយនៅក្នុងសេចក្តីដកស្រង់នោះមិនអាចផ្តល់ទម្ងន់ ឬក៏ថ្លឹងថ្លែងថាជាភស្តុតាងបានទេ។

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម នេះគឺជាចំណុចចុងក្រោយ។ ខ្ញុំនឹងឆ្លើយប្រសិនបើអង្គជំនុំជម្រះសួរខ្ញុំ។ សូមអរគុណ។

[១១:៣២:១០]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅមេធាវីការពារក្តីឲ្យលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការលើកឡើងនូវសេចក្តីជំទាស់របស់ខ្លួនទៅនឹងឯកសារប្រភេទ A1។

សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការ។ ខ្ញុំបាទ

សូមលើកបទអត្ថាធិប្បាយទាក់ទងនឹងឧបសម្ព័ន្ធមួយ ដែលសហព្រះរាជអាជ្ញាបានលើកជាបន្ទុកសម្រាប់ការចោទប្រកាន់។

នៅក្នុងឯកសារលេខ E158 ដែលបង្ហាញពីតម្រុយនៃភាពដែលគួរឲ្យជឿជាក់បានរបស់ឯកសារមួយចំនួន។ សហព្រះរាជអាជ្ញាបានផ្តល់ត្រឹមតែការចង្អុលបង្ហាញជាទូទៅប៉ុណ្ណោះ។ ជាងនោះទៅទៀតសហព្រះរាជអាជ្ញាបាននិយាយថា ខ្លួនបានកត់សម្គាល់សញ្ញាសម្គាល់ ដែលបានចែកសម្រាប់ប្រភេទឯកសារនីមួយៗគឺមានលក្ខណៈជាការបង្ហាញ ហើយគ្មានចេតនាសម្រាប់ជាការបញ្ជាក់ច្បាស់លាស់គ្មានសេសសល់អំពីទ្រង់ទ្រាយលក្ខណៈនៃភាពជឿជាក់បាន និងជាយថាភូតនៃឯកសារទាំងនោះឡើយ។

[១១:៣៤:១១]

ដោយសារឯកសារទាំងនោះមានចំនួនច្រើនក្នុងបញ្ជីឯកសារ ការធ្វើដូច្នេះគឺកាន់តែមានជាបន្ទុកហួសហេតុ។ ដូច្នេះ សហព្រះរាជអាជ្ញាធ្វើឲ្យគេយល់ថា ដោយសារចំនួនដ៏ច្រើននៃឯកសារដែលខ្លួនមានបំណងប្រើជាភស្តុតាង ខ្លួនពេញចិត្តនូវស្ងៀមមិនផ្តល់ព័ត៌មានលម្អិតអំពីយថាភូត និងភាពជឿជាក់បាននៃឯកសារនីមួយៗនេះ។

អ៊ីចឹង យើងសុខចិត្តថា ទង្វើនេះការដែលមិនបង្ហាញនេះវាអាចជាការធុញទ្រាន់មួយ។ តែវាពិតជាមិនមែនជាការងាររបស់មេធាវីការពារដើម្បីមកបង្ហាញការងារនេះ ជំនួសសហព្រះរាជអាជ្ញានោះទេ។ បើសហព្រះរាជអាជ្ញាយល់ថា ឯកសារដែលមាននៅក្នុងបញ្ជីរបស់ខ្លួនទាំងនោះ មានចំនួនច្រើនពេក។ អ៊ីចឹង យើងអាចធ្វើការសើរើយកឯកសារណាដែលមានប្រយោជន៍សម្រាប់រឿងក្តី សម្រាប់ការដាក់បន្ទុកដើម្បីយកមកធ្វើការដេញដោល។

ក្នុងចំណោមឯកសារចំនួន២៣៣ នៅក្នុងឧបសម្ព័ន្ធមួយនេះ មានតែឯកសារមិនដល់៧០ផងដែលសហព្រះរាជអាជ្ញាបានផ្តល់តម្រុយពីភាពជឿជាក់ ប៉ុន្តែសួរថាតម្រុយទាំងអស់នោះ ក៏មិនទាន់មានភាពច្បាស់លាស់នៅឡើយដែរ។ យើងអាចសម្គាល់បានថា សហព្រះរាជអាជ្ញាច្រឡំនូវសញ្ញាណពីរដែលយើងបានពិភាក្សាតាំងពីម្សិលមិញ ពីយថាភូតរបស់ឯកសារ ហើយនិងភាពជឿជាក់ទៅលើខ្លឹមសារនៃឯកសារនោះ។ ហើយយើងក៏បានពិភាក្សាទៅលើភាពពាក់ព័ន្ធនៃឯកសារនោះផងដែរ ដែលយើងអាចចាត់ទុកថាជាចំណុចដំបូងដើម្បីលើកយកឯកសារណាមួយយកមកធ្វើការដេញដោល។

[១១:៣៦:៥០]

ខ្ញុំសូមបញ្ជាក់ថា វាមានភាពខុសគ្នារវាងឯកសារមួយដែលមានតម្លៃរបស់វា អាស្រ័យទៅលើ

យថាភូត ឬយថាភាពរបស់វា និងឯកសារមួយទៀតដែលមានតម្លៃរបស់វាអាស្រ័យទៅលើភាពជឿជាក់បាន។ ក្នុងចំណុចនេះ ខ្ញុំសូមបញ្ជាក់ថា ការលើកបង្ហាញរបស់សហព្រះរាជអាជ្ញាត្រូវកំណត់យកថាតើឯកសារទាំងអស់នោះ វាជាប់ពាក់ព័ន្ធនៅក្នុងរឿងក្ដីដែរឬទេ?

នៅពេលដែលឯកសារមួយដែលបានក្នុងទស្សនៈរបស់សហព្រះរាជអាជ្ញាយល់ថា វាជាប់ពាក់ព័ន្ធហើយ គឺត្រូវបញ្ជាក់អំពីយថាភាពរបស់ឯកសារ ថាតើបានធ្វើត្រឹមត្រូវ? ឧទាហរណ៍ បើសិនជាឯកសារនោះ ជាប្រភេទព័ត៌មាន ជាកាសែត សួរថា វាជាកាសែតដើមដែលចេញពីឈ្មោះកាសែត ឬក៏អ្នកនិពន្ធពិតប្រាកដដែរឬទេ? វាមិនមែនជាកាសែតដែលកូពីចម្លងដែលអាចឲ្យមានការច្រឡំការវាយពាក្យខុស ឬក៏ច្រឡំខ្លឹមសារអីផ្សេងទៀតដែរឬទេ? នេះបញ្ជាក់ពីភាពដើមនៃឯកសារ។

[១១:៣៨:២១]

ទីពីរ នៅពេលដែលយើងពិនិត្យទៅលើខ្លឹមសារនៃកាសែតនោះ គឺត្រូវពិនិត្យថា តើវាមានភាពជឿជាក់ប៉ុនណា? បានន័យថា ខ្លឹមសារដែលនៅក្នុងសារព័ត៌មាននោះ វាមានប្រយោជន៍ដែរឬទេសម្រាប់ជាការដាក់បន្ទុក។ ជួនកាលទៅវាអាចមានប្រយោជន៍ ប៉ុន្តែវាជាព័ត៌មានដែលមិនពិតប្រាកដព័ត៌មានក្លែងក្លាយ ជាការបំផ្លើស។ ដូច្នេះ ភាពចាំបាច់នៃការពិនិត្យទៅលើចំណុចទាំងពីរយ៉ាងនេះ គឺត្រូវតែធ្វើដាច់ខាតចំពោះឯកសារ។ ឧទាហរណ៍ក្នុងឯកសារលេខ E158 របស់សហព្រះរាជអាជ្ញាបានពន្យល់ពីសេចក្ដីថ្លែងការណ៍របស់ជនជាប់ចោទចំនួន៣១ឯកសារ ដែលបានផ្សាយក្នុងកាសែតល្បីៗដូចជា ញូវស្វីក ញូវយ៉កថាមស៍ និងវ៉ាស៊ីនតោនប៉ុស្ដិ៍។ ប៉ុន្តែយើងសួរថា តើឯកសារទាំងអស់នោះ បានដោយរបៀបណា? នៅក្នុងការបញ្ជាក់របស់សហព្រះរាជអាជ្ញាបានបង្ហាញថា ឯកសារខ្លះបានពីប្រភពសាធារណៈ ខ្លះបានមកពីមជ្ឈមណ្ឌលឯកសារ (ឌី.ស៊ី.ខេម) ហើយខ្លះទៀតត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងដោយសហចៅក្រមស៊ើបអង្កេត។ អ៊ីចឹងព័ត៌មានដែលយើងបានទទួលនេះ វាខ្លីពេក វាមិនគ្រប់គ្រាន់សម្រាប់ឲ្យយើងបញ្ជាក់អំពីយថាភាពនៃឯកសារ ឬក៏ភាពជឿជាក់នៃឯកសារនោះបានទេ។

[១១:៤០:៣១]

ម្យ៉ាងទៀត ព័ត៌មានបែបនេះគ្មានប្រយោជន៍អ្វីសម្រាប់ឯកសារប្រភេទនេះឡើយ។ ជាក់ណាស់ការដេញដោលនៅទីនេះមិនមែនដើម្បីចង់ដឹងអត្ថបទរបស់កាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍ និងញូវញ៉ កថាមស៍មានយថាភាព ឬអត់ទេ? អ្វីដែលយើងត្រូវការមែនទែននោះ គឺភាពជឿជាក់ទៅលើខ្លឹមសារ មិនមែនទៅលើទម្រង់របស់វាទេ។

ដូចគ្នានេះដែរ ចំពោះសេចក្ដីថ្លែងរបស់ជនជាប់ចោទក្នុងអំឡុងពេលស៊ើបអង្កេតនាពេលសួរចម្លើយ ការបង្ហាញខ្លួនជាលើកដំបូង ឬក៏កិច្ចពិភាក្សាដេញដោល សហព្រះរាជអាជ្ញាបានពន្យល់ថាឯកសារទាំងនោះត្រូវបានរៀបចំឡើង ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត និងមានទម្រង់ផ្នែកខាងក្នុងសំខាន់ៗ ដូចជាផ្តិតមេដៃ ឬក៏ចុះហត្ថលេខា ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង និងមានការបោះត្រាជាផ្លូវការដោយតុលាការជាដើម។

[១១:៤២:០៣]

យើងសូមអបអរសាទរចំពោះកិច្ចប្រឹងប្រែងរបស់សហព្រះរាជអាជ្ញា ដែលបានបង្ហាញអំពីអត្ត-បទសារព័ត៌មាន និងកំណត់ហេតុស្តាប់ចម្លើយទាំងនេះ ថាមានយថាភូត។ ប៉ុន្តែបើយើងមើលមែនទែនទៅវាជាលំហាត់មួយដ៏វែង អាចថាគ្មានប្រយោជន៍សម្រាប់រឿងក្តីនេះទៀតផង។ អ្វីដែលយើងចង់ដឹងសម្រាប់ឯកសារប្រភេទនេះ គឺថា តើអត្ថន័យរបស់វាអាចជឿជាក់បានឬអត់? គឺមានន័យថា តើអ្វីដែលជនជាប់ចោទបាននិយាយគួរឲ្យជឿជាក់បានទេ? តើអ្វីដែលអ្នកសរសេរអត្ថបទកាសែតសរសេរនោះគួរឲ្យជឿជាក់បានទេ?

[១១:៤២:៥៧]

សហព្រះរាជអាជ្ញាខកខានមិនបានផ្តល់ការបង្ហាញនូវតម្រុយដែលពាក់ព័ន្ធឲ្យលើសពីភាពដែលអាចជឿជាក់បាននេះទេ។ ដូច្នេះ មានន័យថាការដេញដោល ការពិភាក្សា វាមិនត្រូវកន្លែង មិនត្រូវពេល មិនចំសាច់រឿងដែលយើងត្រូវនិយាយ។ អ៊ីចឹង មានតែការដេញដោលនៅក្នុងអង្គសេចក្តីទេ ដែលត្រូវបង្ហាញពីភស្តុតាង ការដេញដោលដ៏ជាក់លាក់ចំពោះសាក្សី ដើម្បីពិនិត្យថាតើភស្តុតាងដែលមាន ឬក៏ឯកសារដែលមាននោះអាចយកជាការបានប៉ុនណា។

ជាចុងបញ្ចប់ យើងខ្ញុំសូមនិយាយពាក្យមួយទាក់ទងទៅនឹងបទសម្ភាសន៍ជនជាប់ចោទជាមួយនឹងអ្នកផ្សេងទៀត ជាមួយ ពីសហចៅក្រមស៊ើបអង្កេត។ យើងខ្ញុំសូមបញ្ជាក់ថានៅក្នុងឯកសារលេខE158 នេះ សហព្រះរាជអាជ្ញាបានលើកឡើង និងពិពណ៌នាយ៉ាងទូលាយអំពីឯកសារទាំងនេះ ប៉ុន្តែមិនបានផ្តល់តម្រុយទាក់ទងទៅនឹងភាពជឿជាក់ទាល់តែសោះ។ សហព្រះរាជអាជ្ញាបានត្រឹមតែព្យាយាមបញ្ជាក់ថាតើឯកសារទាំងនោះបានដាក់ចូលនៅក្នុងសំណុំរឿងដោយអង្គការណាមួយនៃតុលាការនេះ ឬថា វាត្រូវបានទទួលស្គាល់ជាភស្តុតាងនៅក្នុងសំណុំ០០១ រួចហើយឬក៏អត់នោះ?

[១១:៤៥:២៥]

ពីព្រឹកមិញក្រុមប្រឹក្សាជំនុំជម្រះប្រាកដជាបានស្តាប់ឮលោកមេធាវី ម៉ៃខល កាណាវាស បានបង្ហាញពីជំហរទាក់ទងទៅនឹងឯកសារដែលបានដាក់ចូលទៅសំណុំរឿង០០១ ហើយថា វាមិនមែនជាឯកសារដែលត្រូវតែយកមកប្រើនៅក្នុងសំណុំរឿង០០២ នេះជាស្វ័យប្រវត្តិនោះទេ។ វាទាមទារឲ្យមានការដេញដោល ការត្រួតពិនិត្យពីភាគីដែលជាប់ពាក់ព័ន្ធទាំងអស់។ ពីព្រោះថា គោលជំហរក៏ដូចជាវិធីសាស្ត្រ និងការយល់ដឹងការជាប់ពាក់ព័ន្ធនឹងរឿងក្តីរបស់ភាគីមិនដូចគ្នាទេ។ ដូច្នេះឯកសារដែលមានរឿងក្នុងសំណុំរឿង០០១ វាជាឯកសារដោយឡែក គឺប្រើសម្រាប់០០១។

[១១:៤៦:១៤]

នៅពេលដែលយើងពិភាក្សាពីករណី០០២ ឯកសារនោះត្រូវតែដាក់ដេញដោលសាជាថ្មី។ ឯកសារទាំងនេះមានដូចជាកំណត់ហេតុ ឬសេចក្តីសង្ខេបកំណត់ហេតុក្នុងពេលធ្វើសម្ភាសន៍ជាមួយអ្នកកាសែត ឬអ្នកប្រវត្តិសាស្ត្រ។ ជួនកាលសេចក្តីសង្ខបកំណត់ហេតុទាំងនោះមិនទាំងបានធ្វើឡើងដោយអ្នកសម្ភាសន៍ខ្លួនឯងទេ។ អ្នកផ្សេងអ្នកសម្ភាស ឯអ្នកធ្វើសេចក្តីសង្ខេបអ្នកផ្សេងមួយទៀត។ ដូច្នេះវាមិនឆ្លើយតបទៅនឹងភាពត្រឹមត្រូវពិតប្រាកដ នៃខ្លឹមសារដើមចំពោះអ្នកដែលផ្តល់សម្ភាសន៍ ឬក៏អ្នកទទួលសម្ភាសន៍នោះទេ។

[១១:៤៧:១៤]

ចំពោះឯកសារទាំងនេះ បញ្ហាលើភាពជឿជាក់បានមានពីរកម្រិត ដូចដែលខ្ញុំបានលើកឡើងអម្បាញ់មិញពីយថាភាពនិងពីភាពជឿជាក់នោះ។ ដូច្នេះ អង្គសវនាការត្រូវតែពិនិត្យទៅលើឯកសារនីមួយៗ ដែលសហព្រះរាជអាជ្ញាលើកយកសម្រាប់ជាការដាក់បន្ទុក។

ចំណែកឯបទសម្ភាសន៍ដែលធ្វើឡើងដោយអ្នកកាសែត ឬក៏អ្នកប្រវត្តិសាស្ត្រ យើងខ្ញុំមិនត្រឹមតែរក្សាសិទ្ធិសង្ស័យទៅលើភាពជឿជាក់ ទៅលើពាក្យពេចន៍ដែលប្រើប្រាស់ប៉ុណ្ណោះទេ តែលើសពីនោះទៀតគ្មានអ្វីដែលបង្ហាញប្រាប់យើងខ្ញុំសោះថា កំណត់ហេតុទាំងនោះ ឬសេចក្តីសង្ខេបលើកំណត់ហេតុទាំងនោះមានភាពត្រឹមត្រូវ និងពាក្យពេចន៍ដែលបាននិយាយនោះឡើយ។

ដូច្នេះ គប្បីសហព្រះរាជអាជ្ញាផ្តោតការយកចិត្តទុកដាក់ទៅលើការខិតខំបង្ហាញឲ្យបានច្បាស់លាស់ ថាកំណត់ហេតុទាំងនោះត្រូវធ្វើឡើងដោយដូចម្តេច។ វាមានប្រយោជន៍ជាងការបង្ហាញថាសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទនៅចំពោះមុខចៅក្រមស៊ើបអង្កេត ថាពិតជាបានបោះត្រាដោយតុលាការ ឬក៏បានផ្តិតមេដៃនោះ។

[១១:៤៩:១១]

និងថាតើកំណត់ហេតុទាំងនោះធ្វើឡើងក្នុងពេលធ្វើបទសម្ភាសន៍ ឬក៏ធ្វើឡើងច្រើនថ្ងៃបន្ទាប់ពីធ្វើការសម្ភាសរួចហើយ។ តើកំណត់ហេតុទាំងនោះ ធ្វើឡើងដោយផ្អែកទៅលើការបកស្រាយ ឬក៏ជាការកត់ស្គាល់ទៅលើសម្តីរបស់អ្នកដែលផ្តល់បទសម្ភាសន៍។ ប្រសិនបើដូច្នេះមែន តើយើងមានមធ្យោបាយអ្វីដើម្បីផ្ទៀតផ្ទាត់មើលថា តើការបកស្រាយពិតជាត្រឹមត្រូវដោយការប្រើពាក្យពេចន៍តាមការថ្លែងរបស់សាក្សី ឬក៏អ្នកដែលផ្តល់សម្ភាសនោះដែរឬទេ?

ទាំងនេះ ជាសំណួរដែលយើងខ្ញុំចាប់អារម្មណ៍ ហើយដោយសារតែមូលហេតុនេះ ទើបយើងខ្ញុំមានបំណងចង់សួរដេញដោលតទល់ជាមួយនឹងឯកសារនីមួយៗ នៅក្នុងសវនាការអង្គសេចក្តីនេះ។

[១១:៥០:២៤]

មានតែធ្វើបែបនេះទេ ទើបយើងអាចទទួលបានចម្លើយនឹងសំណួរទាំងនោះ ហើយជាទស្សនៈរបស់ខ្ញុំ សំណួរដ៏ពិតៗដែលអង្គជំនុំជម្រះត្រូវចោទសួរមុននឹងផ្តល់តម្លៃ ដែលគួរឲ្យជឿបាន ណាមួយដល់ឯកសារទាំងអស់នោះ។ ដូច្នេះ យើងខ្ញុំជំទាស់ទៅនឹងការដែលអង្គជំនុំជម្រះសន្មតចំពោះភាពជឿជាក់ទៅលើឯកសារ ហើយផ្តល់តម្លៃទុកចិត្តណាមួយទៅលើឯកសារ ដែលធ្វើកំណត់បង្ហាញនៅក្នុងសវនាការនេះដោយពុំមានការដេញដោល។

[១១:៥១:៣១]

ខ្ញុំសូមជូនឧទាហរណ៍មួយដល់អង្គជំនុំជម្រះ អំពីការប្រុងប្រយ័ត្នជាពិសេស ដែលគួរធ្វើចំពោះអត្ថបទសារព័ត៌មាន។ ឧទាហរណ៍ ឯកសារ 165 នៅក្នុងឧបសម្ព័ន្ធមួយ ដែលមានលេខកូដ D313/1.2.310។ ឯកសារនេះ ជាប់ពាក់ព័ន្ធទៅនឹងការថ្លែងរបស់លោក ខៀវ សំផន។ ចំណងជើងអត្ថបទនោះ គឺថាមានឈ្មោះថា៖ "*អ៊ីនធីវីយូ បាយ ឆៅឡាប្រ៊េនទី អ៊ីនស្ទីទុយឡេ* ខៀវ សំផន", "*អ៊ីនធីវីយូ អន អ៊ិចសេសឆ្យូសិន ណាស្យូណល ប្រ៉េបប្លឹម*" (ជាភាសាអង់គ្លេស)។

បើតាមសហព្រះរាជអាជ្ញាលោក ខៀវ សំផន-- សហព្រះរាជអាជ្ញាបានលើកឡើងថា លោក ខៀវ សំផន អាចធ្វើបទសម្ភាសន៍ទាក់ទងទៅនឹងអត្ថបទដែលខ្ញុំ-- ចំណងជើងអត្ថបទដែលខ្ញុំបានលើកអម្បាញ់មិញនេះនៅថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៧៦ គឺខែតុលា ឆ្នាំ១៩៧៦។ តែអត្ថបទនោះត្រូវបានបោះពុម្ពផ្សាយ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៦ ទៅវិញ។ អ៊ីចឹងបានន័យថា ការសន្និដ្ឋានរបស់សហព្រះរាជ

អាជ្ញា ថាលោក ខៀវ សំផន ធ្វើបទសម្ភាសន៍នោះវាមុនពេលដែលកាសែតហ្នឹងចេញទៅទៀត។ អ៊ីចឹងបានន័យថា ចេញកាសែតហើយបានសម្ភាសលោក ខៀវ សំផន តាមក្រោយ។

[១១:៥៣:៥៦]

ម្យ៉ាងទៀតទាក់ទងនឹងទីកន្លែងសម្ភាស អត្ថបទកាសែតនោះបានបង្ហាញថា បទសម្ភាសន៍ប្រហែលជាធ្វើនៅទីក្រុងកូឡុំបូ។ ក៏ប៉ុន្តែនៅក្នុងលិខិតមួយច្បាប់របស់លោក ហ្វ្រង់ស័រ ប៉ង់សូ។ ខ្ញុំសូមប្រកបឈ្មោះ “F-R-A-N-C-O-I-S” ប៉ង់សូ “P-O-N-C-H-A-O-D”។ ផ្ញើជូនទៅលោក ណោម ចមស្គី, ណោម “N-O-A-M” ចមស្គី “C-H-O-M-S-K-Y”។ លោក ហ្វ្រង់ស័រ ប៉ង់សូ គាត់បានផ្ញើលិខិតជូនលោក ណោម ចមស្គី ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៧៧។ លោកបានបង្ហាញថា ខ្ញុំមិនបានលើកឡើង ពីឈ្មោះ ហ្វាមីលីយ៉េ គ្រីស្ទីណា នៅខែកញ្ញា ឆ្នាំ១៩៧៦ នោះទេ។ ពីព្រោះថា ខ្ញុំដឹងពីប្រភពច្បាស់លាស់ណាស់គឺថា “ស្ត្រីអ្នកកាសែតសញ្ជាតិអ៊ីតាលីនោះ មិនដែលបានសម្ភាសលោក ខៀវ សំផន ទេ។ នាងមកជាមួយអ្នកកាសែតបារាំងហើយ មិនបានដើរចេញពីអ្នកកាសែតបារាំងនោះមួយជំហានឡើយ”។

ដូច្នេះចំណុចនេះ ឃើញវាផ្ទុយបាត់។ ការលើកឡើងថា មានអ្នកកាសែតទៅសម្ភាសលោក ខៀវ សំផន នៅពេលនោះគឺមានការបង្ហាញថា វាអត់មាន។ ការពិតអត់មានអ្នកដែលទៅសម្ភាសលោក ខៀវ សំផន ទេ។

អ៊ីចឹងសួរថាតើយើងពឹងផ្អែកទៅលើកាសែតនោះ ដែលនិយាយថា ដកស្រង់សម្ដីលោក ខៀវ សំផន អ៊ីចេះមួយ អ៊ីចុះពីរ? តើយើងអាចយកវាមកធ្វើជាប្រយោជន៍សម្រាប់សវនាការនេះបានទេ? វាអត់ធ្វើទៅកើតទេ។ អ៊ីចឹងហើយបានទាមទារឲ្យមានការដេញដោលពិភាក្សាទៅលើភាពត្រឹមត្រូវ ភាពគួរឲ្យជឿជាក់បាននៃឯកសារទាំងអស់នោះ។

[១១:៥៦:៣៨]

លោក វីល្លៀម សក្រូស *(William Shawcross)* បានបង្ហាញថា គ្មានអ្នកកាសែតណាម្នាក់មានវត្តមាននៅក្នុងសន្និសីទនៅទីក្រុងកូឡុំបូ អាចចេញទៅជួបលោក ខៀវ សំផន នោះទេ ទោះបីជិតឬឆ្ងាយក៏ដោយ។ ទាំងអស់នេះជាការអះអាងបន្ថែមទៅលើសម្ដីអ្នកកាសែតពីររូបដែលមានវត្តមាននៅក្នុងសន្និសីទ ដែលបានអះអាងថាអ្នកកាសែតម្នាក់នោះ មិនអាចធ្វើបទសម្ភាសន៍បានឡើយ ហើយវាជាការក្លែងក្លាយ។ អ៊ីចឹងបានន័យថាគាត់ប្រឌិត។ អ្វីដែលចេញពីអត្ថបទកាសែតនោះ មិនមែនជាការពិតជាអត្ថបទក្លែងក្លាយ។

[១១:៥៧:៣៣]

ចំណែកឯលោក ណោម ចមស្គី វិញលោក វាយតម្លៃអត្ថបទនោះថា (ខ្ញុំសូមអានជាភាសាអង់គ្លេស៖)"ប្រហែលជាមានការប្រឌិតទៅលើក្រុមគ្រួសាររបស់ គ្រីស្ទីណា" កិច្ចសម្ភាសន៍ គ្រីស្ទីណា"។ ខ្ញុំសូមប្រកបឈ្មោះ ហ្វាមីលា គ្រីស្ទីណា "F-A-M-I-J-L-I-A" គ្រីស្ទីណា "C-R-I-S-T-I-A-N-A"។ ឧទាហរណ៍នេះ គឺជាការបង្ហាញមួយទៀត ឲ្យយើងឃើញថា អង្គជំនុំជម្រះត្រូវតែវិភាគពិចារណាទៅលើឯកសារដែលត្រូវដាក់ជូនដោយសហព្រះរាជអាជ្ញានេះម្តងមួយៗជាការចាំបាច់។

ជាចុងក្រោយ ដោយសារពេលវេលាខ្លី ហើយដោយសារសហព្រះរាជអាជ្ញាក៏មិនបានបង្ហាញតម្រុយឲ្យគ្រប់ជ្រុងជ្រោយទៅលើភាពជឿជាក់បាននៃឯកសារទាំងនោះ យើងខ្ញុំមិនអាចធ្វើការជំទាស់ទៅលើឯកសារនីមួយៗដែលមាននៅក្នុងឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញានៅសប្តាហ៍នេះឡើយ។ ក៏ប៉ុន្តែតាមរយៈមូលហេតុដែលបានលើកឡើងនេះ ខ្ញុំសូមលើកដដែលៗថា ការវាយតម្លៃត្រូវតែធ្វើឡើងទៅលើឯកសារនីមួយៗជាចាំបាច់ គឺធ្វើនៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះ នៅក្នុងការជំនុំជម្រះលើអង្គសេចក្តីនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយនិងសាមសិបនាទី រសៀលសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ ហើយឲ្យនាំគាត់ត្រឡប់មកកាន់សាលសវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

សូមអញ្ជើញសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០០ នាទី ដល់ម៉ោង ១៣:៣៤ នាទី)*

[១៣:៣៤:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅដល់សហព្រះរាជអាជ្ញា ដើម្បីលើកអំណះអំណាងរបស់ខ្លួន។ សហព្រះរាជអាជ្ញាមានពេលវេលាមួយម៉ោងក្នុងការលើកអំណះអំណាងរបស់ខ្លួន។

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក សេង ប៊ុនឃាង៖**

បាទសូមអរគុណលោកប្រធាន។ តំណាងសហព្រះរាជអាជ្ញាសូមធ្វើការឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីការពារក្តី។

តំណាងសហព្រះរាជអាជ្ញាសូមជម្រាបជូនអង្គសវនាការថា ឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ១ រួមមានឯកសារជាច្រើនប្រភេទដែលមានធាតុរួមជាច្រើនដូចជា សេចក្តីថ្លែងការណ៍ ឬក៏ចម្លើយរបស់ជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន។ ហើយសេចក្តីថ្លែងការណ៍ ឬក៏ចម្លើយរបស់ជនជាប់ចោទនោះរួមមានដូចជា៖ សុន្ទរកថាធ្វើឡើងដោយជនជាប់ចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលបានផ្សព្វផ្សាយដោយវិទ្យុសំឡេងភ្នំពេញ និងរបាយការណ៍របស់សេវាផ្សព្វផ្សាយព័ត៌មានបរទេសដែលហៅកាត់ថា ហ្វេ.ប៊ី.អាយ.អេស ឬក៏សេចក្តីសង្ខេបព័ត៌មានពិភពលោករបស់ ប៊ី.ប៊ី.ស៊ី ហៅកាត់ថាប៊ី.ប៊ី.ស៊ី.អេស.ដាប់ប៊ែលយូ.ប៊ី ឬក៏ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតរបស់បក្សកុម្មុយនីស្តកម្ពុជាជាដើម។

[១៣:៣៦:២៤]

មួយទៀត គឺសុន្ទរកថារបស់ជនជាប់ចោទក្នុងអំឡុងពេលដែលជនជាប់ចោទបានធ្វើដំណើរទៅក្រៅប្រទេស រួមមានសុន្ទរកថា ដែលបានថ្លែងនៅអង្គការសហប្រជាជាតិ និងសុន្ទរកថានៅពេលធ្វើដំណើរទៅទស្សនកិច្ចនៅប្រទេសចិន និងប្រទេសផ្សេងៗទៀត។ ហើយត្រូវបានរាយការណ៍ដោយអេស.ប៊ី.អាយ.អេស ឬក៏ ប៊ី.ប៊ី.ស៊ី.អេស.ដាប់ប៊ែលយូ.ប៊ី ឬក៏ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិផ្សេងទៀតដែរ។

[១៣:៣៦:៥៧]

សេចក្តីថ្លែងការណ៍មួយទៀតគឺ សន្និសីទសារព័ត៌មានដែលធ្វើឡើងដោយលោក អៀង សារី ឬក៏លោក ខៀវ សំផន នៅពេលដែលគាត់នៅក្រៅប្រទេស ដែលបានរាយការណ៍ដោយប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិផ្សេងៗទៀត។

មួយទៀតគឺបទសម្ភាសន៍ ឬក៏សេចក្ដីថ្លែងការណ៍របស់ជនជាប់ចោទជាមួយអ្នកសារព័ត៌មាន អ្នកប្រវត្តិសាស្ត្រ ឬក៏បុគ្គលផ្សេងៗទៀតផងដែរ។

សេចក្ដីថ្លែងការណ៍មួយទៀត គឺឯកសារ ឬក៏លិខិត ឬក៏សៀវភៅដែលបានសរសេរដោយជនជាប់ចោទផ្ទាល់។ ហើយមួយទៀតគឺ សេចក្ដីថ្លែងការណ៍របស់ជនជាប់ចោទ ដែលបានធ្វើជាផ្លូវការនៅក្នុងដំណើរការនីតិវិធីរបស់តុលាការយើងនេះ។

[១៣:៣៧:៥០]

ជាបន្តទៅទៀតនេះ ខ្ញុំសូមលើកអំពីការជំទាស់របស់ជនជាប់ចោទ យើងឃើញថាមានតែក្រុមមេធាវីការពារក្ដីរបស់លោក អៀង សារី តែប៉ុណ្ណោះដែលបានដាក់ការជំទាស់របស់ខ្លួនចំពោះឧបសម្ព័ន្ធដែលបានណែនាំដោយអង្គជំនុំជម្រះសាលាដំបូងនេះ។ ការជំទាស់របស់ក្រុមមេធាវីការពារក្ដីលោក អៀង សារី ចំពោះឧបសម្ព័ន្ធ១ នេះរួមមាននៅក្នុងឯកសារចំនួនពីរ៖ ទីមួយគឺឯកសារដែលមានលេខ E131/1/10.1 ដែលបានដាក់នៅក្នុងខែមករា ឆ្នាំ២០១២ នេះ ដែលបានជំទាស់ទៅនឹងឯកសារចំនួន ១៦៧ នៃឯកសារឧបសម្ព័ន្ធ១ របស់ការិយាល័យសហព្រះរាជអាជ្ញា។ ទីពីរ គឺឯកសារលេខ E131/21.2 ដែលបានដាក់នៅក្នុងខែធ្នូ ឆ្នាំ២០១១ ដែលបានជំទាស់ទៅនឹងឯកសារចំនួន៦៨ នៃឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធមួយ របស់ការិយាល័យសហព្រះរាជអាជ្ញា។

[១៣:៣៩:០៥]

តាមរយៈឯកសារទាំងពីររបស់ក្រុមមេធាវីការពារក្ដីជនជាប់ចោទ អៀង សារី បើពិនិត្យឲ្យហ្មត់ចត់ទៅឃើញថា គឺជំទាស់រាល់ឯកសារទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធមួយ នេះតែម្ដង។ ហើយការជំទាស់របស់ក្រុមមេធាវីការពារក្ដី អៀង សារី គឺបានធ្វើឡើងដដែលៗនូវទម្រង់នៃការជំទាស់ចំពោះឯកសារនីមួយៗដោយមិនបានពិនិត្យអំពីអ្វីជាការពិត អ្វីដែលជាការកំណត់អំពីភាពជឿជាក់នៃឯកសារច្បាស់លាស់ណាមួយថា វាមានបញ្ហានោះទេ។

[១៣:៣៩:៤១]

ទម្រង់នៃការជំទាស់ដដែលៗនេះ ជាទូទៅ គឺមិនឃើញមានអត្ថាធិប្បាយឲ្យបានច្បាស់លាស់នៅមូលដ្ឋាននៃការជំទាស់ចំពោះឯកសារ ដើម្បីឲ្យការធ្វើជំទាស់របស់ខ្លួននេះគឺមានន័យនោះទេ។ ទាក់ទងនឹងការជំទាស់របស់ក្រុមមេធាវីការពារក្ដី អៀង សារី ចំពោះឯកសារដែលបានធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយើងនេះ ឃើញថា គឺជាគុណវិបត្តិមួយក្នុងចំណោមគុណវិបត្តិជា

ច្រើន នៃការជំទាស់របស់មេធាវីការពារក្ដី អៀង សារី អាចត្រូវបានគេមើលឃើញថា គឺជាការជំទាស់ទៅនឹងសេចក្ដីថ្លែងការណ៍ ឬចម្លើយនានារបស់ជនជាប់ចោទ ដែលបានកត់ត្រាជាផ្លូវការ ហើយដែលបានធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ រួមមានដូចជា កំណត់ហេតុសួរចម្លើយជនជាប់ចោទ ឬកំណត់ហេតុនៃការចូលខ្លួនលើកដំបូងផងដែរ។

[១៣:៤០:៤៣]

ខ្ញុំសូមលើកឧទាហរណ៍ចំពោះការជំទាស់នេះ គឺថាការជំទាស់របស់ អៀង សារី ទៅនឹងឯកសារដែលមានលេខរៀងទី១៨ និងលេខរៀងទី១៩ នៃឧបសម្ព័ន្ធមួយ ដែលជាកំណត់ហេតុនៃកិច្ចពិភាក្សាដេញដោលទៅលើជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងកាលពីថ្ងៃ៩ ខែកញ្ញា ឆ្នាំ២០០៧ ដែលមានឯកសារលេខ C8។ និងមួយទៀត គឺកំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ គឺមានឯកសារលេខ D20។

[១៣:៤១:២៨]

ការជំទាស់នេះ គឺមានលើកឡើងនៅក្នុងឯកសារជំទាស់លេខ E131/1/10.1 ត្រង់លេខរៀងទី១៦ និង១៧ នៃសេចក្ដីជំទាស់តវ៉ារបស់ក្រុមមេធាវីការពារក្ដី អៀង សារី។ នៅក្នុងឯកសារទាំងពីរដែលមេធាវីរបស់ អៀង សារី បានជំទាស់ គឺឯកសារលេខ C8 និងឯកសារលេខ D20 គឺជាអ្វីដែលលោក នួន ជា បានលើកឡើងអំពីតួនាទី និងភារកិច្ចរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍ផ្សេងៗក្នុងអំឡុងពេលនោះ ដូចជាចម្លើយ ដែលថាមានភ្នាក់ងារ សេ.អ៊ី.អា អាមេរិក កា.ហ្សេ.បេ សូវៀត ខ្មែរសេរី និងភ្នាក់ងារសម្ងាត់វៀតណាម បានបង្កប់ខ្លួននៅក្នុងបក្ស ដូចដែលមានលើកឡើងនៅក្នុងឯកសារលេខ២០ ត្រង់ទំព័រទី៤។ និងថាគណៈកម្មាធិការឃោធាមានភារកិច្ចការពារជាតិ និងបោសសម្អាតផ្ទៃក្នុង។ ហើយចំណុចនេះ ក៏មាននៅក្នុងឯកសារលេខC8 ត្រង់ទំព័រទី៤ផងដែរ។

[១៣:៤២:៤៥]

លើសពីនេះទៀត បើយើងពិនិត្យឃើញថា សូម្បីតែចម្លើយរបស់ខ្លួនគាត់ផ្ទាល់ដែលបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយដែលបានកត់ត្រា និងដែលស្ថិតនៅក្នុងដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក៏ដោយ ក៏លោក អៀង សារី ជំទាស់ដែរ។ ការជំទាស់នេះ គឺមាននៅក្នុងឧបសម្ព័ន្ធមួយ ត្រង់លេខរៀងទី១៣៣ និង១៣៤ ដែលជាកំណត់ហេតុនៃការចូលខ្លួនដំបូង ដែលធ្វើឡើងនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧។ ឯកសារមានលេខ D38 និងកំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល

ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ដែលឯកសារមានលេខ C19។ ការជំទាស់នេះ គឺមានលើកឡើងនៅក្នុងឯកសារជំទាស់លេខ E131/21/2 ត្រង់លេខរៀង៥៥ និង៥៨ ផងដែរ។

[១៣:៤៣:៥៦]

នៅក្នុងឯកសារនេះ អៀង សារី បានរៀបរាប់អំពីប្រវត្តិផ្ទាល់ខ្លួនរបស់គាត់ តួនាទី និងការទទួលខុសត្រូវរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចដែលមានលើកឡើងក្នុងឯកសារលេខ C19 ត្រង់ទំព័រទីបី និងឯកសារលេខ D38 ត្រង់ទំព័រទីពីរ។ លោក អៀង សារី ក៏បានជំទាស់ទៅនឹងកំណត់ហេតុនៃការសួរចម្លើយលោក ខៀវ សំផន ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលមាននៅក្នុងឯកសារជំទាស់លេខរៀងទី២២៧, ២២៨ និង២២៩ ជំទាស់ទៅនឹងកំណត់ហេតុនៃការសួរចម្លើយលោក ខៀវ សំផន ដែលធ្វើឡើយដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងខែធ្នូ ឆ្នាំ២០០៧ ដែលឯកសារនេះ មាននៅក្នុងសំណុំរឿង។ មានដូចជាឯកសារលេខ D47, D48 (អ៊ំ សុំទោស) មានឯកសារដូចជា D46, D47 និងD49។ ហើយការជំទាស់នេះ គឺមានលើកឡើងនៅក្នុងឯកសារជំទាស់លេខ E131/21.2 ត្រង់លេខរៀងទី៦៣ ដល់ ៦៥។

ដូចដែលអង្គជំនុំជម្រះបានដឹងរួចហើយថា ឯកសារទាំងអស់នេះ គឺជាការសួរចម្លើយលោក ខៀវ សំផន ដែលគាត់បានផ្តល់ភស្តុតាងទាក់ទងនឹងប្រវត្តិសាវតាររបស់គាត់ រចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ ហើយនិងតួនាទីភារកិច្ចរបស់គាត់ក្នុងរបបនោះ។

[១៣:៤៥:៣៩]

ជាបន្តទៀតនោះ ខ្ញុំសូមលើកមកបង្ហាញជូនអង្គសវនាការ អំពីភាពជឿជាក់លើឯកសារ ដោយលើកជាឧទាហរណ៍ជាក់ស្តែងមួយចំនួន ដែលមេធាវីបានជំទាស់។

ឯកសារដែលមានលេខរៀងទី២៥ និង ២៧ នៃឧបសម្ព័ន្ធទីមួយរបស់ការិយាល័យសហព្រះរាជអាជ្ញា។ ឯកសារលេខរៀងទី២៥ នៃឧបសម្ព័ន្ធទីមួយរបស់ការិយាល័យសហព្រះរាជអាជ្ញានេះ គឺជារបាយការណ៍ព័ត៌មានដែលបានរាយការណ៍ដោយភ្នាក់ងារសារព័ត៌មាន ស៊ិនហួរ អំពីសន្និសីទសារព័ត៌មាន ដែលបានធ្វើឡើងដោយលោក អៀង សារី នៅពេលដែលគាត់ធ្វើដំណើរទៅកាន់ទីក្រុងញូវយ៉កនៅចុងខែសីហា ឆ្នាំ១៩៧៥។ លោកអៀង សារី បានផ្តល់អត្ថាធិប្បាយទាក់ទងទៅនឹងមូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ហើយឯកសារលេខរៀងទី២៧ នៃឧបសម្ព័ន្ធទី១ របស់ការិយាល័យសហព្រះរាជអាជ្ញានេះគឺ ជាបទសម្ភាសន៍របស់លោក អៀង សារី ដែលបានផ្សព្វផ្សាយ

ដោយសារព័ត៌មាន ញូវស្វីក នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៧៥ ដែលបានដកស្រង់ចេញពីកិច្ចប្រជុំនៃប្រទេសមិនចូលបក្សសម្ព័ន្ធកាលពីសប្តាហ៍មុន នៅពេលដែលលោក អៀង សារី ឋិតនៅលីម៉ា នៃប្រទេសប៉េរូ ដែលនៅពេលនោះ លោក អៀង សារី បានរៀបរាប់អំពីមូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញផងដែរ។

[១៣:៤៧:១១]

ឯកសារទាំងពីរនេះ គឺជាឧទាហរណ៍ដ៏ប្រពៃដើម្បីបញ្ជាក់អំពីភាពផ្ទុយគ្នារវាងការលើកឡើងជំទាស់របស់មេធាវីការពារក្តី ដែលបានបញ្ជាក់ឲ្យឃើញថា វាមិនមានករណីចាំបាច់ណាដែលត្រូវកោះអញ្ជើញអ្នកនិពន្ធ អ្នកសរសេរអត្ថបទ នៃរបាយការណ៍ទាំងនោះមក ដើម្បីបង្កើតភាពជឿជាក់ក្នុងចម្លើយជនជាប់ចោទបន្ថែមទៀតនោះទេ។

នៅក្នុងករណីនេះ ភាពជឿជាក់នៃចម្លើយ ឬសេចក្តីថ្លែងការណ៍ ដែលបានធ្វើឡើងដោយលោក អៀង សារី ត្រូវបានបញ្ជាក់ដោយឯកសារផ្សេងៗផងដែរ។ ឧទាហរណ៍ដូចជាការពន្យល់អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលបានលើកឡើងដោយលោក អៀង សារី នៅក្នុងទីក្រុងញូវយ៉កនៅចុងខែសីហា ឆ្នាំ១៩៧៥ ព្រមទាំងរបាយការណ៍របស់អ្នកសារព័ត៌មានស៊ីនហួរ គឺស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងការពន្យល់ដែលលោក អៀង សារី បានផ្តល់ទៅឲ្យអ្នកសារព័ត៌មានញូវស្វីក នៅប៉េរូអ៊ីចឹងដែរ។

[១៣:៤៨:១៨]

ឯកសារទាំងពីរនេះ គឺលោក អៀង សារី បានលើកឡើងថា “មានមូលហេតុពីរ ដែលតម្រូវឲ្យធ្វើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ មូលហេតុទីមួយ គឺដោយសារស្ថានភាពស្បៀង និងមូលហេតុទីពីរ គឺដោយសារស្ថានភាពខ្មាំង” ហើយនៅក្នុងសន្និសីទសារព័ត៌មានរបស់លោក អៀង សារី គាត់បានលើកឡើងទាក់ទងនឹងស្ថានភាពស្បៀងនេះផងដែរ។ ហើយខ្ញុំសូមដកស្រង់សម្តីរបស់គាត់គឺថា៖ “ក្រោយពេលរំដោះ ប្រទេសយើងត្រូវប្រឈមមុខនឹងកិច្ចការបន្ទាន់ពីរ គឺការដោះស្រាយបញ្ហាស្បៀងអាហារដល់ប្រជាជន និងការរក្សាការពារសន្តិភាពនិងសន្តិសុខជាតិ។ ពាក់ព័ន្ធនឹងបញ្ហាទីមួយនេះ យើងរំពឹងថា នឹងស្វែងរកស្បៀងអាហារសម្រាប់ប្រជាជនជិតបីលាននាក់នៅភ្នំពេញ និងបណ្តាខេត្តក្រុងមួយចំនួន ដែលធ្លាប់ទទួលបានម្ហូបអាហារពីបីម៉ឺនទៅបួនម៉ឺនតោនជារៀងរាល់ខែពីសហរដ្ឋអាមេរិកកាលពីមុនពេលរំដោះ។ ក្រោយពេលរំដោះ ប្រសិនបើយើងទុកឲ្យប្រជាជនទាំងនេះបន្តរស់នៅទីក្រុង

ភ្នំពេញទៀតនោះ យើងនឹងធ្វើឲ្យពួកគេប្រឈមនឹងភាពអត់ឃ្លាន និងរងទុក្ខវេទនាជាមិនខាន។ ប្រសិនបើពិចារណាលើកត្តានេះ លក្ខខណ្ឌទំនាក់ទំនងមិនអំណោយផលដល់ការដឹកជញ្ជូនស្បៀងអាហារពីជនបទមកទីក្រុងឡើយ។ យើងមានកាតព្វកិច្ចជម្លៀសប្រជាជនចេញពីទីក្រុងទៅកាន់ជនបទ ដែលមានរក្សាទុក និងបានរៀបចំគ្រប់គ្រងស្បៀងអាហារបានត្រឹមត្រូវ សម្រាប់ទទួលប្រជាជនទាំងនោះ”។ ចប់ការដកស្រង់សម្តី។

[១៣:៥០:០៥]

នៅសប្តាហ៍បន្ទាប់មកទៀត គឺនៅក្នុងបទសម្ភាសន៍ជាមួយសារព័ត៌មាន ញូវស្វីក នៅពេលដែលសួរសំណួរថា “តើហេតុអ្វីបានជាមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ បន្ទាប់ពីការកាន់កាប់នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ នោះ? ពេលនោះលោក អៀង សារី បានឆ្លើយបញ្ជាក់ថា មានមូលហេតុពីរ។ មូលហេតុទីមួយ គឺកត្តាស្បៀង ហើយបានគិតថា មានប្រជាជនចំនួនពីរលាននាក់នៅភ្នំពេញ ប៉ុន្តែពេលយើងបានចូលទៅដល់ យើងបានដឹងថាមានបីលាននាក់។ កាលពីមុនសហរដ្ឋអាមេរិកបានដឹកជញ្ជូនស្បៀងចំនួនបីម៉ឺនទៅបួនម៉ឺនតោនក្នុងមួយខែចូលភ្នំពេញ។ យើងពុំមានមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់ ដើម្បីជញ្ជូនស្បៀងចូលទីក្រុង។ ដូច្នោះប្រជាជនត្រូវធ្វើដំណើរទៅកន្លែងដែលមានស្បៀង”។

[១៣:៥១:១០]

ហើយអត្ថបទមួយទៀត នៅទីក្រុងញូវយ៉ក លោក អៀង សារី បានផ្តល់បទសម្ភាសន៍ទាក់ទងទៅនឹងស្ថានភាពខ្មាំងថា៖ “ចំពោះការការពារសន្តិសុខជាតិ យើងចាប់បានឯកសារមួយដែលបង្ហាញថាខ្មាំងបានត្រៀមរៀបចំផែនការនយោបាយ និងកងទ័ព ដើម្បីដណ្តើមអំណាចវិញក្នុងរយៈពេលប្រាំមួយខែ។ យើងបានកម្ទេចទីស្នាក់ការ និងអង្គការរបស់ពួកវាហើយ”។

ហើយនៅសប្តាហ៍បន្ទាប់មកទៀត គឺលោក អៀង សារី បានធ្វើសម្ភាសន៍ជាមួយអ្នកសារព័ត៌មានញូវស្វីក ហើយនៅពេលដែលសួរសំណួរឲ្យអត្ថាធិប្បាយ អំពីមូលហេតុទីពីរនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ លោក អៀង សារី បានឆ្លើយថា៖ “យើងបានរកឃើញឯកសារមួយដែលនិយាយលម្អិតអំពីផែនការនយោបាយយោធាសម្ងាត់មួយរបស់ភ្នាក់ងារសម្ងាត់កណ្តាលសហរដ្ឋអាមេរិក និងរបប លន់ នល់ ដួលរលំក្នុងការឲ្យមានការភ័ន្តច្រឡំ បន្ទាប់ពីបរាជ័យរបស់យើង។ ផែនការនោះមានបីចំណុច។ ចំណុចទីមួយ ប្រសិនបើយើងពុំអាចដោះស្រាយបញ្ហាក្រពះរបស់ប្រជាជនបាន ពួកវានឹងបង្កបញ្ហាឲ្យភ្នាក់ងារវាជ្រៀតចូលក្នុងចំណោមប្រជាជន។ ចំណុចទីពីរ ទាហាន លន់

នល់ ភាគច្រើនដែលក្រវីទង់ជ័យស តាមការពិតពួកវាបានលាក់អាវុធទុក។ ពួកវាមានចេតនាវាយយើងក្រោយរំដោះភ្នំពេញរួច។ ហើយចំណុចទីបី ពួកវាមានផែនការធ្វើឲ្យកងទ័ពពួកយើងពុករលួយ និងធ្វើឲ្យស្មារតីតស៊ូពួកយើងចុះខ្សោយ ដោយយកស្រី ស្រា និងមាសប្រាក់មកបំពុល"។

[១៣:៥៣:០៤]

លោក លោកស្រីចៅក្រមជាទីគោរព ដូច្នេះនៅក្នុងករណីនេះ យើងឃើញថា របាយការណ៍សារព័ត៌មានជាច្រើនបានបង្ហាញពីភាពស្ទើរដែលដូចគ្នាចំពោះចម្លើយរបស់លោក អៀង សារី នៅពេលដំណាលគ្នាទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលឯកសារនេះបានបញ្ជាក់យ៉ាងគ្រប់គ្រាន់អំពីភាពជឿជាក់ដែលមាននៅក្នុងសារព័ត៌មានជាច្រើននោះ។ ឯកសារនេះមានភាពច្បាស់លាស់ណាស់ ដែលការដកស្រង់សម្តីរបស់លោក អៀង សារី គឺជាការត្រឹមត្រូវ ពីព្រោះលោក អៀង សារី បានធ្វើសេចក្តីថ្លែងការណ៍ដូចគ្នានេះទៅកាន់អ្នកសារព័ត៌មានផ្សេងៗគ្នា នៅពេលដែលគាត់បានធ្វើដំណើរទៅក្រៅប្រទេស។ ហើយគាត់បានផ្តល់បទសម្ភាសន៍ដល់សហគមន៍អន្តរជាតិ និងបានលើកឡើងអំពីបញ្ហាជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះផងដែរ។

[១៣:៥៣:៥៧]

ឧទាហរណ៍នេះ បានបញ្ជាក់យ៉ាងច្បាស់ថា ជំហររបស់មេធាវីការពារក្តី ដែលស្នើឲ្យកោះអញ្ជើញគ្រប់អ្នកនិពន្ធ ឬអ្នកសរសេរអត្ថបទមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនោះ គឺជាការមិនចាំបាច់នោះទេ។ ហេតុដូច្នេះនៅក្នុងឧទាហរណ៍ដែលបានលើកឡើងនេះ គឺបានបញ្ជាក់ថា មិនមានហេតុផលសមរម្យណាមួយដែលតម្រូវឲ្យអង្គជំនុំជម្រះកោះអញ្ជើញអ្នកនិពន្ធ ឬក៏អ្នកសរសេរអត្ថបទ ឬក៏អ្នករាយការណ៍ព័ត៌មានមកធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះឡើយ។

[១៣:៥៤:៣៧]

ហេតុផលមួយទៀត គឺថា ហេតុអ្វីបានជាមិនមានតម្រូវការចាំបាច់ក្នុងការកោះអញ្ជើញអ្នកនិពន្ធ ឬក៏អ្នកសរសេរអត្ថបទ ឬក៏អ្នករាយការណ៍ព័ត៌មានមកចំពោះមុខអង្គជំនុំជម្រះ? ចម្លើយ គឺថាអ្នកនិពន្ធដែលបានរាយការណ៍អំពីឯកសារទាំងនោះ គឺពួកគាត់មិនបានធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់របស់គាត់ទេ តែវាជាសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទខ្លួនឯងផ្ទាល់។ ហើយដោយសារតែនៅពេលនេះជនជាប់ចោទក៏មានវត្តមាននៅតុលាការនេះផងដែរ វាជាការពិតហើយដែលថាជនជាប់ចោទអាចប្រើសិទ្ធិរបស់ខ្លួនរក្សាភាពស្ងៀមស្ងាត់មិនឆ្លើយតបទៅនឹងសំណួរផ្សេងៗ ប្រសិនជាគាត់ជ្រើសរើសវិធីនេះ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏គាត់នៅតែមានឱកាសក្នុងការបដិសេធចំពោះសេចក្តីថ្លែងការណ៍ទាំងអស់នេះ បើសិនជាគាត់យល់ឃើញថា របាយការណ៍ទាំងនេះមិនត្រឹមត្រូវនោះ គឺគាត់អាចបញ្ជាក់ ឬពន្យល់សេចក្តីថ្លែងការណ៍ទាំងនោះបាន។ ដូច្នេះឃើញថា គ្មានភាពចាំបាច់ណាមួយដែលតម្រូវឲ្យអង្គជំនុំជម្រះកោះអញ្ជើញអ្នកនិពន្ធ ឬអ្នកសរសេរអត្ថបទ ឬអ្នករាយការណ៍សារព័ត៌មាន ដើម្បីផ្តល់សក្ខីកម្មគ្រប់ឯកសារនោះទេ។ ពោល គឺវាមិនអាចធ្វើទៅរួចទេនៅក្នុងសំណុំរឿងដែលមានទំហំធំបែបដោយសារតែមានឯកសារពាក់ព័ន្ធរាប់ពាន់ឯកសារ។ ហើយបញ្ហានេះក៏មិនតម្រូវដោយតុលាការអន្តរ-ជាតិនៅក្នុងសំណុំរឿងបែបនេះផងដែរ។

[១៣:៥៦:១៦]

លោក លោកស្រីចៅក្រមជាទីគោរព ឧទាហរណ៍ស្រដៀងគ្នានេះដែរ ដែលបញ្ជាក់អំពីភាពជឿជាក់នៃសេចក្តីថ្លែងការណ៍ ឬចម្លើយជនជាប់ចោទ ដែលមាននៅលេខរៀងទី៣១ និងលេខរៀងទី៣២ក្នុងឧបសម្ព័ន្ធមួយ របស់ការិយាល័យសហព្រះរាជអាជ្ញា។ ឯកសារលេខរៀងទី៣១ គឺជារបាយការណ៍របស់សារព័ត៌មានវ៉ាស៊ីនតោនប៉ុស្តិ៍ ដែលបានរាយការណ៍នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ អំពីសន្និសីទសារព័ត៌មានដែលបានធ្វើឡើងដោយលោក អៀង សារី នៅទីក្រុងបាងកក។ ដែលលោក អៀង សារី បានបញ្ជាក់ជាផ្លូវការអំពីថា មានការសម្លាប់មេដឹកនាំកំពូលបីនាក់នៃអតីតរដ្ឋាភិបាលទីក្រុងភ្នំពេញ គឺឈ្មោះ ឡុង បូរ៉េត ដែលជាអតីតនាយករដ្ឋមន្ត្រីក្នុងរដ្ឋាភិបាលរបស់ លន់ នល់ និងការសម្លាប់ លន់ ណុន ដែលជាប្អូនប្រុសរបស់លោក លន់ នល់ ហើយនិងការសម្លាប់ សិរិមតៈ ផងដែរ។

[១៣:៥៧:១៦]

នៅពេលនោះលោក អៀង សារី ក៏បានបដិសេធអំពីរបាយការណ៍របស់ជនភៀសខ្លួន ដែលរស់នៅក្នុងជំរំភៀសខ្លួនរបស់ប្រទេសថៃ ទាក់ទងទៅនឹងភាពអត់ឃ្លាន ជំងឺ និងការប្រហារជីវិតនៅក្នុងប្រទេស។ ដោយលោក អៀង សារី បានលើកឡើងថា របាយការណ៍ភៀសខ្លួន របាយការណ៍របស់ជនភៀសខ្លួនទាំងនោះមិនគួរឲ្យជឿបានទេ ដោយសារតែពួកជនភៀសខ្លួនដែលបានទៅប្រទេសថៃនោះគឺជាអ្នកដែលប្រព្រឹត្តនូវបទឧក្រិដ្ឋ។

នៅក្នុងករណីនេះ តើអាចឲ្យអង្គជំនុំជម្រះជឿម្តេចបាន ដែលថាឯកសារនេះមានភាពជឿជាក់គ្រប់គ្រាន់ ដោយមិនចាំបាច់កោះអញ្ជើញអ្នកនិពន្ធ ឬអ្នកសរសេរអត្ថបទ ឬក៏អ្នករាយការណ៍សារ

ព័ត៌មាននោះ? ចម្លើយ គឺថា របាយការណ៍ផ្សេងៗ គឺបានបង្ហាញដូចគ្នានៅក្នុងសន្និសីទនាទីក្រុងបាងកក ដែលបានរាយការណ៍អំពីសេចក្ដីថ្លែងការណ៍របស់លោក អៀង សារី។

[១៣:៥៨:១៨]

ខ្ញុំសូមលើជាឧទាហរណ៍ទាក់ទងនឹងឯកសារលេខរៀងទី៣១ នៃឧបសម្ព័ន្ធមួយនេះគឺជាឯកសារ ដែលបានរាយការណ៍ដោយកាសែតបាងកកប៉ុស្តិ៍។ ឯកសារនេះរួមមានរូបថតរបស់លោក អៀង សារី ជួបជាមួយនឹងរដ្ឋមន្ត្រីក្រសួងការបរទេសថៃ ដែលបានរាយការណ៍អំពីរឿងដែលទាក់ទងទៅនឹងទំនាក់ទំនងរវាងប្រទេសទាំងពីរ និងបានពិភាក្សាអំពីការជួបប្រជុំផងដែរ។ ហើយនៅក្នុងអត្ថបទសារព័ត៌មាន ដែលមានចំណងជើងថា "មានការទទួលស្គាល់ថា មានការប្រហារជីវិត"។ ក្នុងរបាយការណ៍នេះក៏បាន លើកឡើងអំពីការបញ្ជាក់របស់លោក អៀង សារី ក្នុងការប្រហារជីវិតមន្ត្រីរបស់របប លន់ នល់ ដែល លោក អៀង សារី បានលើកឡើងនៅក្នុងសន្និសីទសារព័ត៌មាន ដែលបានធ្វើនៅក្នុងបន្ទប់សន្និសីទរបស់ សណ្ឋាគារអ៊ីរ៉ាវ៉ាន់ ដែលបានចាប់ផ្ដើមនៅវេលាម៉ោងប្រាំបី និងសាបសិបនាទីព្រឹកផងដែរ។

[១៣:៥៩:១៩]

អត្ថបទនេះបានអធិប្បាយអំពីមូលហេតុ ហេតុអ្វីបានជាលោក អៀង សារី លើកឡើងថា ប្រជាជនដែលបានភៀសខ្លួនពីប្រទេសកម្ពុជា គឺជាអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម? ហើយនៅពេលដែលសួរសំណួរទាក់ទងនឹងរបាយការណ៍របស់ជនភៀសខ្លួន ថាមានការប្រហារជីវិតមនុស្សនៅក្នុងប្រទេសកម្ពុជា ពេលនោះលោក អៀង សារី បានលើកឡើងថា "ព័ត៌មានទាំងនេះមិនគួរឲ្យជឿនោះទេ"។

ការិយាល័យសហព្រះរាជអាជ្ញាបានកំណត់អត្តសញ្ញាណនៃរបាយការណ៍របស់លោក អៀង សារី ទាំងនេះ គឺជារបាយការណ៍ ដែលមានសារៈសំខាន់ និងមានភាពពាក់ព័ន្ធសម្រាប់អង្គជំនុំជម្រះ ដោយឈរលើមូលហេតុពីរយ៉ាង ដូចជា មូលហេតុទីមួយ ដូចដែលអង្គជំនុំជម្រះបានដឹងរួចហើយ ថាលោក ខៀវ សំផន បានថ្លែងក្នុងសមាជ និងតាំងរណសិរ្សរួបរួមជាតិនៃកម្ពុជា ដែលបានធ្វើឡើង នៅចុងខែកុម្ភៈ ឆ្នាំ១៩៧៥ បានអំពាវនាវឲ្យមានការសម្លាប់ជនក្បត់ប្រាំពីរនាក់ ជាមន្ត្រីអតីតរដ្ឋាភិបាល លន់ នល់ ដែលរួមមាន ឡុង បូរ៉េត និង សិរិមតៈ ជាដើម។ លើសពីនេះទៀត មាននៅក្នុងចម្លើយ និង ឯកសារផ្សេងៗទៀតជាច្រើននៅក្នុងសំណុំរឿងដែលបញ្ជាក់ថា ឡុង បូរ៉េត បានចុះចាញ់កងទ័ពខ្មែរក្រហមកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅឯទីស្ដីការក្រសួងព័ត៌មាន ហើយ សិរិមតៈ ត្រូវបាន

យកចេញពីស្ថានទូតបារាំងពីរបីថ្ងៃក្រោយមក។ ហើយសេចក្ដីថ្លែងការណ៍របស់លោក អៀង សារី គឺជាការបញ្ជាក់ជាផ្លូវការរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យអំពីការប្រហារជីវិតនេះ។

[១៤:០១:១១]

មូលហេតុទីពីរ គឺរបាយការណ៍ព័ត៌មានទាំងនេះគឺបានបញ្ជាក់នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ទាក់ទងនឹងការប្រហារជីវិត និងភាពអត់ឃ្លាននៅក្នុងប្រទេសកម្ពុជា ដែលបានលើកឡើងដោយលោក អៀង សារី ហើយចម្លើយរបស់លោក អៀង សារី គឺថាក្នុងនាមជារដ្ឋមន្ត្រីក្រសួងការបរទេស និងជាសមាជិកម្នាក់ក្នុងចំណោមសមាជិកអចិន្ត្រៃយ៍ចំនួនប្រាំនាក់របស់បក្សកុម្មុយនីស្តកម្ពុជានោះ គឺមិនបានចាត់វិធានការបញ្ឈប់ការសម្លាប់និងភាពអត់ឃ្លាននោះទេ។ ដោយគាត់គ្រាន់តែបដិសេធអំពីបញ្ហាទាំងនេះនៅចំពោះមុខសហគមន៍អន្តរជាតិ ហើយគាត់ក៏បានចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមជាងបីឆ្នាំក្នុងឋានៈជាថ្នាក់ដឹកនាំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។

ហើយជាបន្តទៅទៀតនេះ ខ្ញុំអនុញ្ញាតលោកប្រធាន ដើម្បីឲ្យសហការីអន្តរជាតិរបស់ខ្ញុំបន្តទៅនឹងការឆ្លើយតបនេះផងដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ នៅក្នុងពេលវេលារបស់ខ្ញុំនេះ ខ្ញុំនឹងលើកឡើងឆ្លើយតបទៅនឹងការជំទាស់លើកឡើងដោយខាងជនជាប់ចោទ ហើយខ្ញុំក៏ធ្វើការឆ្លើយតបទៅលើបញ្ហានៃឯកសារដែលបានលើកឡើងនៅក្នុងថ្ងៃនេះផងដែរ តាមដែលលទ្ធភាព ខ្ញុំអាចធ្វើទៅបានក្នុងរយៈរបស់ខ្ញុំបន្តពីចំណុចដែលបានលើកឡើងដោយសហភាតារបស់ខ្ញុំ។ ខ្ញុំមិនលើកចំណុចជាន់គ្នានោះទេ។ តែថាគ្មានឯកសារណាមួយនោះ គឺមិនអាចយកមកទទួលយកបាន លើកលែងតែយក មានការជំទាស់តវ៉ាដេញដោលទៅលើអ្នកដែលរៀបចំឯកសារឡើង។

[១៤:០៣:១៩]

តាមរយៈឯកសារដែលបានបង្ហាញ ដែលវាបានបង្ហាញត្រឹមត្រូវតាមផ្លូវច្បាប់នោះ គឺយើងបានពិភាក្សាគ្នា។ ដូច្នេះហើយយើងមិនចាំបាច់នាំកោះអញ្ជើញ អ្នកដែលជាអ្នកនិពន្ធមកធ្វើការដេញដោលនិងស្ដាប់ផ្ដល់ចម្លើយនោះទេ។ ដូចដែលយើងបានលើករួចមកហើយ សេចក្ដីថ្លែងការណ៍នៅក្នុងសន្និសីទ

និងនៅក្នុងកិច្ចសម្ភាសន៍ ដែលលើកឡើងដោយលោក អៀង សារី តាងនាមឲ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនោះ លោក អៀង សារី បានលើឡើងម្តងហើយម្តងទៀតទៅលើសេចក្តីថ្លែងការណ៍នោះ។

នៅពេលដែលយើងមើលរបាយការណ៍ផ្សេងៗ ថាតើវាមានភាពស៊ីសង្វាក់គ្នាទៅលើសេចក្តីប្រកាស សេចក្តីថ្លែងការណ៍នោះដែរឬទេ? នោះគឺដើម្បីឲ្យយើងអាចជឿអំពីភាពជឿជាក់វាបាន គឺយើងឃើញថាវាមានភាពស៊ីសង្វាក់គ្នា។

ចំណុចទីពីរ ជនជាប់ចោទ គាត់លើកឡើងថា គាត់មិនមានលទ្ធភាពធ្វើការតវ៉ា និងពិនិត្យទៅលើរបាយការណ៍ទាំងអស់នោះ។ យើងខ្ញុំសូមបញ្ជាក់ថា យើងដាក់ជូននូវរបាយការថណ៍ទាំងអស់នោះ ជូនអង្គជំនុំជម្រះដោយសារតែមានសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ។ ដូច្នេះសេចក្តីថ្លែងការណ៍ទាំងអស់នោះ គឺជាសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ មិនមែនរបស់សារព័ត៌មាននោះឡើយ។

[១៤:០៤:៣៧]

ជនជាប់ចោទនៅទីនេះ គាត់តវ៉ាថា គាត់មិនមានឱកាសក្នុងការតវ៉ាឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍ និងឯកសារទាំងអស់នោះ។ ការជំទាស់មួយទៀត ដែលខាងមេធាវីការពារក្តី អៀង សារី បានសរសេរដាក់ជូននោះ គឺយើងបានពិភាក្សាគ្នាក្នុងរយៈពេលពីរថ្ងៃរួចមកហើយ។ ការជំទាស់របស់គាត់ដែលគាត់លើកឡើងថាបានបញ្ចូលនៅក្នុងឧបសម្ព័ន្ធមួយ និងឧបសម្ព័ន្ធដទៃទៀតនោះ គឺឯកសារថ្មីមិនមាននៅក្នុងសំណុំរឿង។ មេធាវីការពារក្តីគាត់ជំទាស់ទៅលើឯកសារទាំងអស់នេះ ដោយសារតែគាត់ត្រូវតែធ្វើយ៉ាងណាឲ្យយើងគោរពទៅតាមវិធាន៨៧ ដែលជាបទដ្ឋានខ្ពស់បំផុត។ យើងដឹងហើយថាឯកសារនៅក្នុងឧបសម្ព័ន្ធមួយ គឺបានដាក់នៅក្នុងខែមេសា ក្នុងឆ្នាំនេះមុនពេលសវនាការចាប់ផ្តើម។ បទដ្ឋានលក្ខខណ្ឌនៅក្នុងវិធាន៨៧(៤) គឺចែងអំពីឯកសារថ្មីដែលបានដាក់ក្រោយពេលសវនាការតែប៉ុណ្ណោះ។ នៅក្នុងករណីនុំងគឺភាគីត្រូវតែបង្ហាញថា គាត់មិនអាចរកឯកសារទាំងអស់នោះនៅមុនដំណាក់កាលសវនាការទើបយើងដាក់ឯកសារថ្មី។ ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះបដិសេធការជំទាស់របស់មេធាវីការពារក្តី ទាក់ទងទៅនឹងការលើកឡើងចំពោះឯកសារនៅក្នុងឧបសម្ព័ន្ធដូចដែលខ្ញុំបានបញ្ជាក់។

[១៤:០៦:១៣]

ចំណុចទូទៅមួយទៀត ដែលខ្ញុំបានស្តាប់ឮ ហើយដែលបានលើកឡើងកាលពីម្សិលមិញរួមទាំងថ្ងៃនេះផងដែរ គឺពាក់ព័ន្ធនឹងរបាយការណ៍ សេចក្តីថ្លែងការណ៍ សុន្ទរកថារបស់ជនជាប់ចោទគឺវាបានយកមកពីរបាយការណ៍ និងឯកសារដែលបានបង្កើតឡើង និងផ្សព្វផ្សាយនៅក្នុងវិទ្យុកម្ពុជាប្រជាធិប-

តេយ្យ។ ឯកសាររបាយការណ៍សុន្ទរកថាទាំងអស់នោះគឺមានប្រភពមួយចំនួន គេដកស្រង់ ហើយគេបានផ្សព្វផ្សាយនៅក្នុងប្រភពមួយ គឺប្រភព *ហ្វីប៊ីស* ដែលជាសារព័ត៌មានមួយដែលគេបានផ្សាយនៅសម្តីនូវសេចក្តីថ្លែងការណ៍សុន្ទរកថាទាំងអស់នេះ។ វាជាវិទ្យុផ្សព្វផ្សាយរបស់ខាងអាមេរិកាំង។ ដូច្នេះវិទ្យុផ្សាយនេះ ជាវិទ្យុផ្សាយនៅទូទាំងពិភពលោកដែលយើងស្តាប់ឮ។ យើងក៏ឃើញមានការយោងសរសេរនៅក្នុងប៊ី.ប៊ី.ស៊ី អេស.ដាប់ប៊ែលយូ.ប៊ី គឺជាការផ្សព្វផ្សាយរបស់សារព័ត៌មានពិភពលោក។ វាជាប្រភពមួយដែលជាវិទ្យុតាមដាន និងផ្សព្វផ្សាយទៅលើវិទ្យុដែលផ្សាយចេញពីវិទ្យុកម្ពុជាប្រជាធិបតេយ្យ។

[១៤:០៧:៣៥]

ដូច្នេះយើងឃើញមានសុន្ទរកថា និងសេចក្តីថ្លែងការណ៍សំខាន់ៗរបស់ជនជាប់ចោទហើយយើងព្យាយាមធ្វើយ៉ាងណាបញ្ចូលឯកសារចាក់ផ្សាយមកពី *ហ្វីប៊ីស* រួមទាំង អេស.ដាប់ប៊ែលយូ.ប៊ី ផងដើម្បីឲ្យយើងបានដឹង។ នៅពេលដែលយើងធ្វើការវិភាគអាចទុកចិត្តបាននោះ គឺយើងអាចមើលទៅលើខ្លឹមសាររបស់វាបាន។

[១៤:០៨:០០]

យើងមិនចាំបាច់ពឹងផ្អែកទៅលើសារព័ត៌មាន ប៊ី.ប៊ី.ស៊ី ឬក៏ហ្វីស នោះទេ យើងក៏មានឯកសារផ្សេងទៀតផងដែរ។ ដូចដែលយើងឃើញមាននៅក្នុងកិច្ចដំណើរការនីតិវិធីរបស់យើង។ មានករណីជាច្រើនដែលសុន្ទរកថាដូចគ្នានេះ គឺបានផ្សព្វផ្សាយដោយបក្សកុម្មុយនីស្តកម្ពុជា ហើយការផ្សព្វផ្សាយនោះមាននៅក្នុងទង់បដិវត្ត។ ដូច្នេះហើយវាជាប្រភពទីបី ដែលយើងអាចធ្វើការផ្ទៀងផ្ទាត់ ហើយវាមានសុន្ទរកថាដូចគ្នា។ ហេតុដូច្នេះ វាមានវិធីជាច្រើនដែលយើងអាចធ្វើការបង្ហាញអំពីភាពទុកចិត្តបាននៃសុន្ទរកថាទាំងឡាយរបស់ជនជាប់ចោទ ដែលយើងមិនចាំបាច់នាំអ្នកនិពន្ធ ឬអ្នកដែលជាអ្នកសរសេរមកធ្វើការដេញដោលដូចដែលមេធាវីការពារក្តីបានលើកឡើងនោះទេ។

ដោយសារតែហេតុទាំងអស់នេះហើយ អង្គជំនុំជម្រះត្រូវតែពិចារណាភស្តុតាងទាំងមូលនៅពេលដែលយើងវិភាគទៅលើសុន្ទរកថាទាំងអស់នោះ។ នៅពេលនេះ ខ្ញុំសូមផ្តល់ជាឧទាហរណ៍មួយថាតើឯកសារមាននៅក្នុងសំណុំរឿងនោះយោងយ៉ាងម៉េច ដោយសហព្រះរាជអាជ្ញា? ដែលក្នុងនោះគឺមានសុន្ទរកថាដែលមានភាពស៊ីសង្វាក់គ្នាយ៉ាងច្រើន។

[១៤:០៩:០០]

លោក លោកស្រីចៅក្រម ប្រហែលជាចាំហើយ ឯកសារមួយក្នុងចំណោមឯកសារទាំងអស់នោះដែលបានដាក់ជូននៅចំពោះមុខលោក នួន ជា ក្នុងសប្តាហ៍ទៅមុននោះ គឺជាសុន្ទរកថាដែលបានធ្វើឡើងនៅក្នុងថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧ ដែលជាការគោរពខួបលើកទីប្រាំបួន នៃកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ នេះគឺជាឧទាហរណ៍មួយដ៏ល្អដែលយើងខ្ញុំសូមបញ្ជាក់នៅទីនេះ។ យើងមានសុន្ទរកថានេះ សរសេរនៅក្នុងបីឯកសារដែលមាននៅក្នុងសំណុំរឿង។ ឯកសារដែលសរសេរមួយនោះ គឺបានផ្សព្វផ្សាយដោយវិទ្យុ ប៊ី.ប៊ី.ស៊ី ឯកសារលេខមួយនៅក្នុងឧបសម្ព័ន្ធមួយ សំណុំរឿD248/6.1.14 យើងមានសុន្ទរកថាដែលផ្សាយដោយវិទ្យុហ្វីប៊ីស ដែលខ្ញុំបានយកមកប្រើប្រាស់នៅក្នុងតុលាការនេះគឺចេញពីឯកសារD262/2/2.6។ នេះគឺជាកម្រងនៃរបាយការណ៍ដែលគេបានផ្សព្វផ្សាយនៅក្នុងរបាយការណ៍ដែលធ្វើឡើងនៅថ្ងៃទី១៦ ខែ១ ឆ្នាំ១៩៧៧។ ឯកសារនេះនៅក្នុងទំព័រលេខ00168465 ដល់លេខ 470 បារាំងគឺមាន 0069844 ហើយទៅដល់លេខ 698450 ខ្មែរគឺ 00679792 រហូតដល់លេខ 7802។

សុន្ទរកថាដដែលដែលខ្ញុំលើកឡើងនេះក៏បានសរសេរបញ្ចូលនៅក្នុងទង់បដិវត្តផងដែរ គឺមានឯកសារ-- ឯកសារនេះមានលេខ D43/2/1/9 ដូច្នេះហើយអង្គជំនុំជម្រះអាចធ្វើការវាយតម្លៃទៅលើភាពទុកចិត្តបាននៃឯកសារទាំងអស់នេះ ហើយយើងវាយតម្លៃទៅតាមប្រភពឯកសារជាច្រើននៅក្នុងការសម្រេចអំពីភាពត្រឹមត្រូវ និងជាពិសេសវាយតម្លៃទៅលើភាពទុកចិត្តបាននៃព័ត៌មានដែលបានដកស្រង់។

[១៤:១១:៥៥]

ប្រសិនបើយើងមើលទៅលើឯកសារទាំងបីនេះគឺ យើងឃើញថាខ្លឹមសាររបស់វាមានភាពស៊ីសង្វាក់គ្នាទាំងបី។ ដូច្នេះបានន័យថាយើងអាចបញ្ជាក់ថា វាជារបាយការណ៍និងសុន្ទរកថាដែលបានផ្សព្វផ្សាយយ៉ាងត្រឹមត្រូវបង្ហាញជាសុន្ទរកថារបស់ជនជាប់ចោទ។

ឧទាហរណ៍មួយទៀត គឺសុន្ទរកថាដែលបានថ្លែងឡើងដោយលោក ខៀវ សំផន នៅក្នុងពិធីរំឭកខួបលើកទីពីរថ្ងៃចាប់យកទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ឯកសារនេះ គឺលេខ 167 ហើយមានលេខឯកសារ IS20.24 ដូច្នេះតាមរយៈឯកសារនេះ អង្គជំនុំជម្រះអាចបញ្ជាក់អំពីសុន្ទរកថាដែលបានធ្វើឡើង ហើយអ្វីដែលបានលើកឡើងក្នុងសុន្ទរកថានោះ បានផ្សព្វផ្សាយបានយ៉ាងត្រឹមត្រូវ ហើយវិទ្យុ និងវិទ្យុផ្សព្វផ្សាយដទៃទៀតក៏បានផ្សព្វផ្សាយទៅលើសុន្ទរកថានេះផងដែរ។

[១៤:១៣:១៤]

ប្រសិនបើយើងមើលឯកសារផ្សេងទៀត 168 ឯកសារ 169 យើងឃើញមានរបាយការណ៍ចេញពីសារព័ត៌មាន *ហ៊ីប ទ្រីប៊ីយូណល* គឺឯកសារចេញមកពី អា.អេស.ប៉េ ដែលជាការផ្សព្វផ្សាយទៅលើសុន្ទរកថារបស់ជនជាប់ចោទផងដែរ ដែលថាវាជាសុន្ទរកថាថ្លែងឡើងយ៉ាងត្រឹមត្រូវពីជនជាប់ចោទ។

ដូច្នេះនៅពេលនេះ គឺខ្ញុំសូមលើកឡើងអំពីឯកសារជាក់លាក់ដែលខាងមេធាវីការពារក្តីជនជាប់ចោទបានលើកឡើងនៅក្នុងមតិយោបល់របស់ពួកគេ។

[១៤:១៤:០៤]

ខ្ញុំសូមចាប់ផ្តើមពីក្រុមមេធាវីរបស់លោក នួន ជា។ លោកមេធាវីនោះគាត់បានលើកឡើងអំពីការជំទាស់ទៅលើឯកសារ ជាពិសេសគាត់ជំទាស់ទៅលើការជជែកលេងរបស់លោក នួន ជា ជាមួយនឹងលោក ខឹម ងុន គឺឯកសារលេខ9 នៅក្នុងឧបសម្ព័ន្ធលេខ១ ឯកសារលេខ IS20.28។ ខ្ញុំសូមលើកមតិយោបល់មួយចំនួនពាក់ព័ន្ធទៅនឹងឯកសារនេះ។

ជាដំបូងនោះពាក់ព័ន្ធទៅនឹងការបង្ហាញពីភាពទុកចិត្តបាន និងភាពទុកចិត្តបានជាបឋមនោះ គឺលោក នួន ជា បានធ្វើឡើងរួចមកហើយ គឺគាត់បានបញ្ជាក់ថា គាត់បាននិយាយជជែកលេងជាមួយនឹងលោក ខឹម ងុន នៅក្នុងពេលនោះ។ លោក នួន ជា បានបញ្ជាក់ថាគាត់បានជួបជាមួយនឹងលោក ខឹម ងុន។ ការជំទាស់របស់លោក នួន ជា នោះ គឺគាត់លើកឡើងអំពីថា តើគាត់បាននិយាយ ឬក៏មិននិយាយទៅលើខ្លឹមសារនុ៎ង? ដូច្នេះហើយ តួនាទីនេះគឺជាការងាររបស់អង្គជំនុំជម្រះក្នុងការវាយតម្លៃទៅលើខ្លឹមសារនៃឯកសារនោះ និងពិចារណាទៅលើឯកសារជារួម។

មតិយោបល់មួយចំនួនទៀត ខ្ញុំសូមលើកឡើងផងដែរ។ ខ្ញុំមិនធ្វើការតវ៉ាជាមួយនឹងជនជាប់ចោទនៅពេលដែលគាត់និយាយអំពីការជជែកលេងជាមួយនឹងលោក ខឹម ងុន នោះទេ។ ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា តាំងពីទំព័រទីមួយនៃឯកសារនោះគឺវាមិនមែនការនិយាយលេងធម្មតាទេ គឺវាមានន័យច្រើនជាងនេះ។

[១៤:១៥:៤៥]

នៅក្នុងឯកសារដើមដំបូងនោះ គឺបានលើកឡើងដូចតទៅ ហើយឯកសារនោះសរសេរនៅក្នុងន័យជាលក្ខណៈបុគ្គលផ្ទាល់តែម្តង គឺឯកសារនោះសរសេរដូចតទៅ។ ខ្ញុំសូមដកស្រង់៖ “គោលបំណងនៅក្នុងការនិយាយរបស់ខ្ញុំនេះ ដើម្បីឲ្យយល់អំពីប្រវត្តិនៃការកសាងបក្សតាំងពីបាតដៃទទេ រហូតមកដល់ពេលបច្ចុប្បន្ន”។ ហើយនៅក្នុងចាប់ផ្តើមនោះ ក៏បានលើកឡើងផងដែរ ដែលលោក នួន ជា បានលើកឡើង៖ “ដូច្នេះប្រសិនបើលោក មិត្តចង់សួរនោះ គឺខ្ញុំអាចពន្យល់បាន។ ខ្ញុំនឹងឆ្លើយតបភ្លាមតែម្តង

ប៉ុន្តែបើសិនបើខ្ញុំមិនអាចឆ្លើយតបភ្លាមៗបាននោះទេ គឺខ្ញុំសូមឲ្យចាំមួយភ្លែតដើម្បីឲ្យខ្ញុំរំឭកការចងចាំរបស់ខ្ញុំឡើងវិញ”។

[១៤:១៦:៤៣]

ខ្ញុំគិតថាឯកសារនេះ គឺជាឯកសារមួយដែលវាបង្ហាញ អំពីបុគ្គលចូលរួមនៅក្នុងចលនាតស៊ូ។ ដូច្នេះ នៅពេលដែលយើងមើលទៅលើខ្លឹមសារនៃឯកសារនេះ វាមិនត្រឹមតែជាការជជែកលេងធម្មតានោះទេ វាគឺជាការនិយាយ និងលើកឡើងរបស់លោក នួន ជា អំពីប្រវត្តិរបស់បក្សដែលបង្ហាញជូនលោក ខឹម ងុន និងសមមិត្តដទៃទៀត។ មានវិធីចំនួនពីរដែលយើងគិតថា ឯកសារនេះទុកចិត្តបាន គឺទីមួយ គឺលោក នួន ជា បានបញ្ជាក់ថាគាត់បានជួបជាមួយនឹងលោកនុ៎ង។ ទីពីរ នៅពេលដែលយើងមើលឯកសារនេះ ជារួមទាំងមូល វាបង្ហាញយ៉ាងច្បាស់ថាចម្លើយទាំងឡាយ ការលើកឡើងនៅក្នុងឯកសារនោះ ចេញពីលោក នួន ជា ៩៥ភាគរយ នៃខ្លឹមសារនៅក្នុងនោះ គឺវាមានខ្លឹមសារដូចគ្នាទៅនឹងអ្វីដែលគាត់រៀបរាប់ជូននៅក្នុងតុលាការនេះ។

ដូច្នេះ ការដែលថាវាមិនលម្អិតជាងនោះទៅទៀតនោះ គឺដោយសារតែវាជាការរៀបរាប់ដោយសង្ខេប។ ដូច្នេះហើយ យើងឃើញមានចំណុចខុសគ្នាតែបន្តិចតែប៉ុណ្ណោះ ក៏ប៉ុន្តែនៅពេលដែលយើងមើលឯកសារនុ៎ង វាគឺជាឯកសារ និងចម្លើយដែលចេញពីលោក នួន ជា ទាំងអស់។

[១៤:១៨:០៤]

ខ្ញុំសូមលើកឡើងនូវលេខយោង ដែលថាតើខ្ញុំមានន័យយ៉ាងម៉េចទៅលើឯកសារនេះ? ខ្ញុំអានចេញពីផ្នែកមួយនៃឯកសារដែលបានលើកឡើងអំពីប្រវត្តិនៃការបង្កើតបក្សនៅក្នុងទសវត្សរ៍ទី៥០។ ការដកស្រង់ ខ្ញុំសូមដកស្រង់ដូចតទៅចេញពីឯកសារនោះ៖ “ដូច្នេះ បុគ្គលដែលប្រើយុត្តិវិធីក្នុងការដោះស្រាយបក្សកុម្មុយនីស្តចិន ហើយធ្វើការដោះស្រាយបក្សកុម្មុយនីស្តនៅក្នុងឆ្នាំ១៩៦១។ នៅក្នុងប្រទេសកម្ពុជាយើងផ្ដល់បក្ស ថាជាបក្សកុម្មុយនីស្តកម្ពុជា ហើយនៅក្នុងប្រទេសឡាវ គឺ បក្សបដិវត្តប្រជាជនឡាវ។ ដូច្នេះ បុគ្គលដែលគាត់បានផ្លាស់ប្ដូរបក្សឈ្មោះនេះ វាស្ថិត-- ការដែលយើងដូរឈ្មោះបក្សនេះ គឺដើម្បីឲ្យយើងធ្វើការគ្រប់គ្រងដោយខ្លួនឯងទៅលើបក្ស ទៅតាមវិធីគ្រប់បែបយ៉ាងដែលយើងអាចធ្វើបាន។ ចំពោះកម្មាភិបាលកម្ពុជា គឺមានចំនួនតូចតែប៉ុណ្ណោះ គឺគាត់-- មួយចំនួននោះ គឺជាអាយ៉ងរបស់គេ”។ ដូច្នេះហើយ ចម្លើយទាំងអស់នេះគឺយើងមានឃើញការលើកឡើងម្ដងហើយម្ដងទៀត ដោយ

លោក នួន ជា ព្រមទាំងការលើកឡើងនៅក្នុងបន្ទប់សវនាការនេះផងដែរ។ ដូច្នេះ អ្វីដែលបានលើកឡើងនៅក្នុងឯកសារនៅក្នុងនោះ គឺវាដូចគ្នាទៅនឹងចម្លើយរបស់លោក នួន ជា នៅក្នុងបន្ទប់សវនាការនេះ។

[១៤:១៩:៤៥]

ដូច្នេះយើងអាចយល់ឃើញថា មានតែលោក នួន ជា ដែលគាត់លើកឡើងទៅលើចំណុចនេះ ពាក់ព័ន្ធទៅនឹងបក្ស ហើយមានសរសេរបញ្ចូលទៅក្នុងឯកសារ។ មានមនុស្សមួយចំនួនតូចតែប៉ុណ្ណោះ ដែលបានចូលរួមនៅក្នុងសន្និបាតលើកទីពីរ ដែលគាត់បានដឹងព័ត៌មានតិចតួច ដែលក្នុងនោះរួមមាន លោក ទូ សាមុត ហើយដែលលោក ទូ សាមុត គាត់បានដឹងព័ត៌មានដូចដែលលោក នួន ជា គាត់បានផ្តល់ជូន។ ឯកសារនេះអាចបង្ហាញឲ្យយើងជឿជាក់ទុកចិត្តទៅលើឯកសារនេះបាន ហើយវាបញ្ជាក់អំពីការលើកឡើង និងការនិយាយរបស់លោក នួន ជា។

[១៤:២០:២៨]

មេធាវីលោក នួន ជា ក៏បានលើកឡើងបញ្ហាឯកសារមួយចំនួនផ្សេងទៀត រួមទាំងឯកសារលេខ ៥០ និង១៥ និង១៦ នៅក្នុងឧបសម្ព័ន្ធមួយ ដែលក្នុងនោះគឺកិច្ចសម្ភាសន៍ដោយបុគ្គលអនាមិក។ ចំណុចឯកសារទី២-- ឯកសារទី១៦ និងឧបសម្ព័ន្ធមួយនោះ គឺបានសម្ភាសឡើយដោយអ្នកសារព័ត៌មានជប៉ុន។

ដូច្នេះនិយាយដោយសរុប និងខ្លីមក ខ្ញុំហាក់ដូចជាមិនយល់អំពីទឡ្ហីករណ៍ដែលលើកឡើងដោយមេធាវី នួន ជា ដែលគាត់លើកឡើងអំពីឯកសារទី១៥ នៅក្នុងឧបសម្ព័ន្ធទីមួយនោះ។ ឯកសារនោះ គឺខ្ញុំមិនបានសួរអំពី នួន ជា នោះទេ។ ប៉ុន្តែវាជាឯកសារនៅក្នុងសំណុំរឿង អនុញ្ញាតឲ្យអង្គជំនុំជម្រះធ្វើការពិចារណា ហើយប្រសិនបើមិនមានភស្តុតាងណាមួយផ្ទុយទៅនឹងឯកសារនោះទេនោះ គឺយើងអាចចាត់ទុកថាវាជាឯកសារផ្ទៀតផ្ទាត់សម្រាប់ឯកសារដទៃទៀត។ ចំពោះអ្នកសារព័ត៌មានជប៉ុន ដែលគាត់ធ្វើការសម្ភាសន៍ដូចដែលមាននៅក្នុងឯកសារលេខ១៦ នៅក្នុងឧបសម្ព័ន្ធមួយ វាគឺជារបាយការណ៍ ឬក៏កិច្ចសម្ភាសន៍ដែលមានការថតជាខ្សែអាត់។ លោក លោកស្រីចៅក្រមអាចពិនិត្យមើលបាន។ ការសម្ភាសនៅពេលនោះ គឺពាក់ព័ន្ធទៅនឹងប្រវត្តិនៃបក្ស ព័ត៌មានទាំងអស់នោះ វាគឺជាព័ត៌មានដែលអាចបញ្ជាក់ថាជាចម្លើយចេញពីលោក នួន ជា។

[១៤:២២:០៨]

ជាថ្មីម្តងទៀត គឺជាឯកសារដែលវាសម្រាប់ផ្ទៀងផ្ទាត់តែប៉ុណ្ណោះ ទោះបីជាខ្ញុំមិនអាចយកមកផ្ទៀត មកសួរដេញដោលទៅកាន់ជនជាប់ចោទក៏ដោយ។ ដូច្នេះ នៅក្នុងដំណាក់កាលក្រោយទៀតនៃ

សវនាការ វាប្រហែលជាអាចមានលទ្ធភាពរកឃើញទៅលើខ្សែអាត់ដែលបានគេធ្វើឡើងនៅក្នុងពេលសម្ភាស។ ហេតុដូច្នេះឯកសារនេះ គឺជាឯកសារដែលវាពាក់ព័ន្ធទៅនឹងទម្ងន់នៃឯកសារ។ ហើយយើងគិតថាឯកសារពាក់ព័ន្ធដែលយើងត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ដូច្នេះ នៅពេលដែលយើងវាយតម្លៃឯកសារទាំងអស់នោះ យើងត្រូវវាយតម្លៃទៅលើឯកសារទាំងមូលនិងឯកសារជារួម។

[១៤:២២:៥៧]

ឆ្លើយតបទៅនឹងការជំទាស់ដែលបានលើកឡើងដោយលោក កាណាវាស ជាមេធាវីខាងលោក អៀង សារី។ ការតវ៉ាដែលមួយគឺយើង-- គេលើកឡើងថាយើងបានដាក់ឯកសារជាច្រើននៅក្នុងឧបសម្ព័ន្ធទី១។ ការជំទាស់នេះ គឺមិនមែនអាចឲ្យអង្គជំនុំជម្រះច្រានចោលនូវឯកសារនេះទេ។ គ្រាន់តែយើងដាក់ឯកសារ យើងបានដាក់ឯកសារដោយសារតែយើងដាក់ជាក្រុម ហើយនៅពេលដែលយើងមើលទៅលើឧបសម្ព័ន្ធនោះ ឯកសារនីមួយៗបានបង្ហាញអត្តសញ្ញាណយ៉ាងច្បាស់ គឺជារបាយការណ៍ចេញមកពីសារព័ត៌មាន ហើយវាជាការផ្សព្វផ្សាយទៅលើសុន្ទរកថារបស់ជនជាប់ចោទ។

ដូច្នេះ ខាងមេធាវីការពារការក្តី គាត់លើកឡើងថា សវនាការគួរតែច្រានចោលឯកសារនេះដោយផ្អែកទៅលើហេតុផលដូចដែលគាត់បានលើកឡើង វាមិនសមស្របនោះទេ។ ចម្លើយទាំងអស់ឯកសារទាំងអស់ គឺមានចម្លើយដែលបានលើកឡើងដោយជនជាប់ចោទ។

[១៤:២៤:០៦]

ឆ្លើយតបទៅនឹងឯកសារមួយចំនួនផ្សេងទៀត ដូចដែលបានលើកឡើងដោយខាងមេធាវី កាណាវាស លោកមេធាវី កាណាវាស បានលើកឡើងឯកសារទី២៦ នៅក្នុងឧបសម្ព័ន្ធរបស់យើង ឯកសារលេខ D366/7.1.633។ ឯកសារនេះ គឺពាក់ព័ន្ធទៅនឹងរបាយការណ៍ ទៅលើកាប៉ាល់ម៉ៃយីហ្គេ ដែលរៀបរាប់ដោយ *អេលីហ្សាប៊ែត បេកឃ័រ*។ ដូច្នេះឯកសារនេះ គឺជាឯកសារដែលយើងដាក់ជូនអង្គជំនុំជម្រះបង្ហាញអំពីហេតុការណ៍ពាក់ព័ន្ធទៅនឹងយោធា។ វាមិនបង្ហាញអំពី-- វាបង្ហាញអំពីជំហររបស់លោក អៀង សារី ធ្វើការការពារទៅលើទំនាក់ទំនងអន្តរជាតិ។ ដូច្នេះ ហើយឯកសារនេះ ខ្ញុំយល់ឃើញថា វាជាឯកសារមួយអាចមានភាពស៊ីសង្វាក់ អាចយកមកផ្ទៀងផ្ទាត់បាន។ ខ្ញុំឯកភាពជាមួយនឹងលោក អៀង សារី ថា យើងមិនមានប្រយោជន៍ក្នុងការដាក់ឯកសារនេះ ក៏ប៉ុន្តែមិនមែនថាយើងដាក់ដើម្បីធ្វើយ៉ាងណា ទាមទារធ្វើបណ្តឹងទៅលើកាប៉ាល់ម៉ៃយីហ្គេ នោះទេ។

[១៤:២៥:៣២]

ចំពោះ៦៧ នៅក្នុងឧបសម្ព័ន្ធមួយ ដូចដែលមេធាវីការពារក្តី អៀង សារី បានលើកឡើង។ ឯកសារ D56 ឯកសារលេខ១២៤ ឯកសារនេះ គឺការសម្ភាសន៍ អៀង សារី ដោយលោក ស្ទីវិន។ ឯកសារនេះ លោកមេធាវីលើកឡើងថា ឯកសារនោះគ្រាន់តែជាការដកស្រង់ការសម្ភាសន៍តែប៉ុណ្ណោះ ជាការឆ្លើយតបខ្ញុំសូមឲ្យអង្គជំនុំជម្រះមើលនៅក្នុងឧបសម្ព័ន្ធត្រង់ឯកសារលេខ៧០ ឯកសារD108/28 .306 ឯកសារលេខនេះ គឺជាកំណត់សម្គាល់ទាំងមូលតែម្តង ដែលការសម្ភាសនោះធ្វើឡើងដោយបុគ្គល *ផ្លូល ស្ទីវិន*។

លោក កាណាវាស ក៏បានលើកឡើងឯកសារ D366/7.1.589 ដែលក្នុងនោះមេធាវីការពារក្តីលើកឡើងថា គ្រាន់តែជាអ៊ីម៉ែលដែលវាបង្ហាញនូវសេចក្តីថ្លែងការណ៍របស់លោក អៀង សារី និង លោក អៀង ធីរិទ្ធ។ ជាការពិត ខាងសហព្រះរាជអជ្ញាមិនមែនពឹងផ្អែកទៅលើអ៊ីម៉ែលនេះ ដើម្បីបង្ហាញជាភស្តុតាងនោះទេ។ អ៊ីម៉ែលនោះ គឺបានបង្ហាញអំពីសេចក្តីថ្លែងការណ៍ចេញពីឯកសារជាខ្សែវីឌអូ ដែលខ្សែវីឌីអូនេះគឺវាពាក់ព័ន្ធទៅនឹងការលើកឡើងរបស់ អៀង សារី និង អៀង ធីរិទ្ធ។

ដូច្នេះសហព្រះរាជអាជ្ញាមានបំណងចង់បង្ហាញនូវខ្សែភាពយន្តទាំងមូលតែម្តង នៅពេលដែលយើងបង្ហាញជាភស្តុតាង។ ខ្សែវីឌីអូនេះ គឺជួយដល់អង្គជំនុំជម្រះ និងយើងទាំងអស់គ្នាបង្ហាញនូវសេចក្តីថ្លែងការណ៍របស់លោក អៀង សារី និង អៀង ធីរិទ្ធ។ ដូច្នេះយើងគិតថា យើងគួរតែដាក់ជូននូវខ្សែវីឌីអូ និងឯកសារមួយនេះ ដើម្បីបង្ហាញជូនអង្គសវនាការឲ្យយើងមើលឃើញទាំងអស់គ្នា។

[១៤:២៧:៤៧]

ចំពោះឯកសារជាក់លាក់ដែលលោក កាណាវាស បានលើកឡើងផ្សេងទៀតនោះ លោក កាណាវាស បានលើកឡើងអំពីការសម្ភាសន៍ ដែលបានធ្វើឡើងដោយ អេលីហ្សាប៊ែត បេកយ័រ ដែល អេលីហ្សាប៊ែត បេកយ័រ សម្ភាសន៍លោក អៀង សារី។ ដែលនៅក្នុងនោះមាន គឺសេចក្តីថ្លែងការណ៍ទាំងមូលរបស់លោក អៀង សារី។ អង្គជំនុំជម្រះប្រហែលជាមិនបានដឹង ចៅក្រមស៊ើបអង្កេតបានសរសេរទៅកាន់ អេលីហ្សាប៊ែត បេកយ័រ ហើយស្នើសុំ អេលីហ្សាប៊ែត បេកយ័រ នូវការសម្ភាសន៍លោក អៀង សារី ទាំងមូល។ ប្រសិនបើអង្គជំនុំជម្រះមើលឯកសារលេខ១០៦, ១០៩ និង១១០ នៅក្នុងឧបសម្ព័ន្ធមួយ គឺលោក លោកស្រីចៅក្រមនឹងឃើញការសម្ភាសទាំងមូលដោយ អេលីហ្សាប៊ែត បេកយ័រ ដែលគាត់បានសម្ភាសលោក អៀង សារី។

[១៤:២៨:៤៧]

លោក កាណាវាស ក៏លើកឡើងថា សហព្រះរាជអាជ្ញានៅពេលនេះ គឺជាអ្នកត្រូវកំណត់ថា តើសាក្សីមួយណាត្រូវមកផ្តល់ជាសក្ខីកម្ម ហើយផ្តល់ជាមូលដ្ឋានទៅលើសារទូរលេខ និងឯកសារដទៃទៀតដែលបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ។ ឆ្លើយតបខ្ញុំសូមបញ្ជាក់ថា សហព្រះរាជអាជ្ញាបានធ្វើអ៊ីចឹងរួចមកហើយ ខ្ញុំសូមឲ្យមេធាវីមើលចម្លើយសាក្សីរបស់យើងខ្ញុំ ដែលក្នុងនោះយើងបានផ្តល់ជូនតាំងពីដើមឆ្នាំមកម្ល៉េះ ដែលចម្លើយនោះ គឺបានបង្ហាញថា សាក្សីជាច្រើនបានបង្ហាញអំពីព័ត៌មាន ហើយអង្គជំនុំជម្រះបានជ្រើសរើសសាក្សីមួយចំនួននោះមកផ្តល់ចម្លើយនៅក្នុងតុលាការ។ ដូច្នេះ យើងនឹងស្តាប់ នៅក្នុងតុលាការនេះយើងនឹងស្តាប់ចម្លើយសាក្សីទាំងអស់នោះ ដែលគាត់នឹងលើកឡើងព័ត៌មានពាក់ព័ន្ធនឹងឯកសារដូចដែលយើងខ្ញុំបានដាក់។

[១៤:២៩:៤៨]

ចំណុចចុងក្រោយ ឆ្លើយតបទៅនឹងមេធាវីលោក ខៀវ សំផន ប្រសិនបើខ្ញុំយល់មិនខុសនោះទេ គឺគាត់បានលើកឡើងអំពីភាពជឿជាក់នៃឯកសារ។ គាត់ថាយើងមិនផ្តល់ព័ត៌មានលម្អិតទៅលើឯកសារនីមួយៗ ខ្ញុំសូមបញ្ជាក់ឆ្លើយតបថា នេះគឺជាឯកសារដាក់ជាទូទៅ គឺវាពាក់ព័ន្ធ-- ចំពោះព័ត៌មានលម្អិតគឺយើងផ្តល់ជូននៅក្នុងឧបសម្ព័ន្ធរបស់យើង ដែលក្នុងនោះរៀបរាប់អំពីឯកសារនីមួយៗ។ មេធាវីខាងលោក ខៀវ សំផន អាចមើលឯកសារទាំងអស់នោះបាននៅក្នុងសំណុំរឿង។

មេធាវីរបស់លោក ខៀវ សំផន ក៏បានតវ៉ាផងដែរ ឯកសារទាំងអស់នោះមិនគួរយកមកដាក់បញ្ចូលសំណុំរឿង០០២ នោះទេ ដោយសារតែបានបញ្ចូលនៅក្នុងសំណុំរឿង០០១ រួចមកហើយ។ គាត់មានសិទ្ធិក្នុងការតវ៉ា ខ្ញុំឯកភាព ហើយករណីដែលថា សំណុំឯកសារទាំងឡាយដែលបានដាក់ចូលនៅក្នុងសំណុំរឿងមួយហើយមិនអាចយកមកដាក់សំណុំរឿងក្រោយទៀតនោះ គឺមិនអាចនោះ។ ដោយសារហេតុនេះហើយ ទើបយើងមកចូលរួមនៅក្នុងសវនាការថ្ងៃនេះ នៅក្នុងថ្ងៃនេះ នៅក្នុងអាទិត្យនេះ ដើម្បីពិភាក្សា និងតវ៉ាទៅលើបញ្ហាហ្នឹង។ ហើយវាមិនត្រឹមត្រូវនោះទេ នៅពេលដែលលើកឡើងថា សំណុំរឿងឯកសារទាំងអស់នោះមិនអាចយកមកដាក់បញ្ចូលសំណុំរឿង០០២នោះទេ ដោយសារតែបានបញ្ចូលនៅក្នុងសំណុំរឿង០០១រួចមកហើយ គឺពិតជាមិនត្រឹមត្រូវ។

ខ្ញុំសូមអរគុណលោក លោកស្រីចៅក្រម នេះគឺជាការឆ្លើយតបរបស់ខ្ញុំជាក់លាក់ទៅលើការជំទាស់របស់ខាងមេធាវីការពារក្តី។ សូមអរគុណ។

[១៤:៣១:៥២]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកសហព្រះរាជអាជ្ញា។ ឥឡូវនេះដល់ពេលសមល្មមនឹងឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី ខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៣ នាទី ដល់ម៉ោង ១៤:៥០ នាទី)*

[១៤:៥០:២៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ជាបន្តនេះ អង្គជំនុំជម្រះ ប្រគល់វេទិកាទៅសហមេធាវីនាំមុខ ដែលមានមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតំណាងដែលបានទទួលសិទ្ធិ ហើយមេធាវីមានរយៈពេល៣០នាទី ដើម្បីធ្វើការអំណះអំណាងតប។ សូមអញ្ជើញ!

**លោក បាណាបេ ណេគ្វី៖**

បាទ សូមអរគុណលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ ពេលតាមឮអំណះអំណាងដែលធ្វើដោយក្រុមដើមបណ្ដឹង-- ភាគីការពារក្ដីទាំងអស់នោះលើឧបសម្ព័ន្ធទីមួយ ដែលជាកម្មវត្ថុនៃការពិភាក្សារបស់យើងនៅថ្ងៃនេះ គឺថាវាលេចចេញមកនៅធាតុស្ថិតស្ថេរមួយពាក់ព័ន្ធទៅនឹងខ្សែគំនិតការពាររបស់ខ្លួន ទាក់ទងនឹងភាពទទួលយកបាននៅលើឯកសារដែលបានដាក់ជូន។

[១៤:៥២:០៩]

ក្រុមការពារក្ដីហាក់ដូចជាយល់ស្របមូលមតិគ្នា ដែលថាខ្លួនមានសិទ្ធិក្នុងការបញ្ជាទៅដល់អង្គជំនុំជម្រះឲ្យតម្រូវថាឲ្យធ្វើអ្វីមួយ ដើម្បីឲ្យភស្តុតាងទាំងអស់នុ៎ងត្រូវអាចទទួលយកបាន។ ក្រុមការពារក្ដីទាំងអស់នោះ យល់ថាខ្លួនមានសិទ្ធិចង្អុលប្រាប់ថា លក្ខខណ្ឌកំណត់នោះគឺចាំបាច់ត្រូវតែចំពោះឯកសារណាក៏ដោយ ដែលដាក់ជូននោះ គឺដែលថាទាក់ទងនឹងការសេចក្ដីប្រកាសរបស់កូនក្ដីរបស់ខ្លួនពីមុននោះ គឺថា តម្រូវឲ្យអ្នកនិពន្ធទាំងអស់ហ្នឹងមកបង្ហាញមុខនៅចំពោះមុខអង្គជំនុំជម្រះ។

ខ្ញុំយល់ថា តាមរយៈអំណះអំណាងដែលបានលើកឡើងតាំងពីដើមនៃការពិភាក្សាយើងនេះ គឺថាគោលជំហររបស់ការពារក្តីនេះ គឺថាសិទ្ធិរបស់ជនជាប់ចោទ ដែលថាត្រូវទទួលបាននូវការជម្រះសេចក្តីដោយយុត្តិធម៌។ គាត់បានលើកឡើងនូវឧទាហរណ៍ទាក់ទងនឹងយុត្តិសាស្ត្រមួយចំនួន។ ចំពោះយើងជាដើមបណ្តឹងរដ្ឋប្បវេណី ហើយបន្ទាប់ពីមានការលើកឡើងរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងការភាពទទួលយកបាននៃឯកសារនេះ។

[១៤:៥៣:៤៨]

ចំពោះយើង យើងយល់ឃើញថាកាតព្វកិច្ចរបស់យើងគឺថាយើងត្រូវតែធ្វើយ៉ាងណា ពិភាក្សារឿងច្បាប់ឲ្យច្បាស់លាស់ ហើយយើងនឹងយកទស្សនករណ៍របស់ភាគីការពារក្តីមកធ្វើជាមូលដ្ឋាន។ កាលពីព្រឹកមិញ ខាងការពារក្តីរបស់លោក អៀង សារី បានរៀបរាប់អំពីការរឿងក្តីរបស់លោក *ពាកាលីក(?)* ដែលនៅក្នុងរឿងក្តីនេះ ក្នុងរយៈពេលប្រាំឆ្នាំ លោក កាណាវាស ដែលគាត់ការពារដោយខ្លាំងក្លានូវប្រយោជន៍របស់កូនក្តីរបស់គាត់។

[១៤:៥៤:៣០]

ហើយអ៊ីចឹងនៅក្នុងរឿងក្តីនោះ វាកើតចេញជាគោលការណ៍មួយចំនួនដែលទាក់ទងទៅនឹងការគ្រប់គ្រងរដ្ឋបាល ទាក់ទងនឹងភស្តុតាងនេះ។ ភាគីការពារក្តីរបស់លោក អៀង សារី បានលើកឡើងអំពីរឿងក្តីនេះ បាននិយាយថា ការគ្រប់គ្រងឯកសារភស្តុតាង និងការទទួលភស្តុតាងនេះបានដោយអង្គជំនុំជម្រះ នៅតុលាការនោះ តុលាការកំពូលបានលើកឡើងថា ជាបឋមសិទ្ធិរបស់ជនជាប់ដែលថាទទួលបានការជម្រះក្តីដោយយុត្តិធម៌នោះ មិនជាការចាំបាច់នោះទេ មិនដាច់ខាតនោះទេ។ ដោយចង្អុលបង្ហាញថា សិទ្ធិនេះត្រូវតែស្រប អនុលោមទៅនឹងវិធានមួយចំនួនទៀតនៃប្រព័ន្ធតុលាការ ប្រព័ន្ធយុត្តិធម៌ដែលថាតម្រូវឲ្យមានការការពារសិទ្ធិ គឺការសម្រេច-- សេចក្តីសម្រេចនៅថ្ងៃទី២៣ វិច្ឆិកា ឆ្នាំ២០០៧ ខ្ញុំគិតថាវាជាការសំខាន់ណាស់ក្នុងការលើកឡើងនូវកថាខណ្ឌមួយ ឬក៏វគ្គមួយនៃកថាខណ្ឌនេះ ដែលមានលើកឡើងថា គឺកថាខណ្ឌ៤១ ជួរទីពីរជាភាសាអង់គ្លេស ហេតុអ្វីបានជាសវនាការរបៀបនេះឲ្យមានការពិនិត្យទៅលើភស្តុតាងប្រឆាំងទៅនឹងជនជាប់ចោទ? គោលការណ៍នេះ មិនមែនជាគោការណ៍ដាច់ខាតនោះទេ គឺនេះគឺជាវិធានមួយនៃអង្គតុលាការកំពូលដែលបានរំឭកនៅក្នុងរឿងក្តីនុំងដែលមានលោកមេធាវីរបស់លោក អៀង សារី ។

[១៤:៥៦:៣៨]

ហើយនៅ ក្រោយមកទៀតនៅក្នុងសាលក្រមហ្នឹងតុលាការកំពូលបានយល់ឃើញថា បញ្ចេញមតិលើភស្តុតាងដោយប្រើពាក្យពេចន៍ដូចតទៅនេះ៖ បាទជាភាសាអង់គ្លេសដែរ “ព្រឹត្តិការណ៍ដែលពាក់ព័ន្ធទៅនឹងបញ្ហានៅចំពោះមុខនេះ ចាប់តាំងពីសំណុំរឿងទីមួយនៃរបស់តុលាការនេះ យុត្តិសាស្ត្រគឺថាត្រូវបានកើតមានឡើងដោយលើកឡើងថា នៅក្នុងប្រព័ន្ធរបស់តុលាការ សេចក្តីថ្លែងការណ៍របស់បុគ្គលម្នាក់អាចធ្វើឡើងនៅក្នុងបទដ្ឋានមួយ បើទោះបីជាសេចក្តីថ្លែងការណ៍នោះធ្វើដោយផ្ទាល់មាត់ដោយសាក្សីណាម្នាក់ក៏ដោយ គឺមិនអាចទទួលយកបាន-- អាចនឹងទទួលយកបាន ទោះបីជាភស្តុតាងដោយប្រយោលក្តី”។

[១៤:៥៨:០៨]

ដូច្នេះនេះ គឺថាយើងកំណត់ឲ្យច្បាស់នូវអ្វីដែលយើងត្រូវធ្វើ នៅពេលដែលយើងត្រូវធ្វើ នៅពេលដែលយើងពិនិត្យលើភាពអាចទទួលយកបាននៃភស្តុតាង ឬក៏ឯកសារភស្តុតាងនៅចំពោះមុខតុលាការយើងនេះផ្ទាល់តែម្តង។ ដូច្នេះវាមិនមែនជាថា យើងត្រូវធ្វើចំពោះឯកសារដែលយើងទទួលបាននោះថាតម្រូវឲ្យអ្នកនិពន្ធហ្នឹងមកបង្ហាញខ្លួននោះទេ។ ដូច្នេះពុំមានមូលដ្ឋានផ្លូវច្បាប់នោះទេ។ ដូច្នេះយើងនៅទីនេះ គឺថា គឺជា-- អ្វីដែលយើងធ្វើគឺថាជាភស្តុតាងនៃសេចក្តីប្រកាស សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទខ្លួនផ្ទាល់តែម្តង។ ដូច្នេះយើងគួរតែដាក់ជូនទៅដល់ចំណាប់អារម្មណ៍របស់លោកចៅក្រមទាំងអស់គ្នានូវវិធានមួយចំនួនដែលចែងដោយតុលាការ យូហ្គោស្លាវី តាមរយៈរឿងក្តីរបស់លោក *អាលីឡូវិច* គឺជាសាលក្រមដែលបានចេញនៅថ្ងៃទី១៩ សីហា ឆ្នាំ២០០៥។

[១៤:៥៩:២២]

ហើយយោងនៃរឿងក្តីនេះ គឺ IT-01-48 AR73.2 ។ ជាការចាប់អារម្មណ៍ណាស់ ដែលខ្ញុំត្រូវនិយាយជូនតុលាការអំពីរឿងក្តីនេះ គឺជាស្ថានភាពមួយដែលលោក *អាលីឡូវិច* ដែលជនជាប់ចោទនៅក្នុងរឿងក្តីនុ៎ង ប្រឆាំងទៅនឹងការបង្ហាញភស្តុតាងដោយសហព្រះរាជអាជ្ញាអំពីសេចក្តីថ្លែងការណ៍របស់ខ្លួនផ្ទាល់ ដោយពុំមានវត្តមានរបស់មេធាវីរបស់ខ្លួននៅក្នុងការជម្រះសេចក្តី។ សហព្រះរាជអាជ្ញានៅពេលនោះគាត់សម្រេចចិត្តដាក់ភស្តុតាងជូនអង្គជំនុំជម្រះ។ ហើយអង្គជំនុំជម្រះដែលពិនិត្យលើភាពទទួលយកបាននៃភស្តុតាង ឯកសារភស្តុតាង ដែលជាសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទផ្ទាល់នោះបានសម្រេចទទួលឯកសារភស្តុតាងហ្នឹង ដោយមិនចាំបាច់នាំជន អ្នកនិពន្ធនៃអត្ថបទនោះមកចំពោះមុខអង្គជំនុំជម្រះ ចំពោះមុខសហព្រះរាជអាជ្ញា។ ហើយកាលនោះៗ អ្នកនិពន្ធគាត់ទំនេរទេ មិន-- លោក

*អាលីឡូវិច* បានជំទាស់របៀបធ្វើរបស់អង្គជំនុំជម្រះហើយចាត់ទុកថា យើងមិនអាចទទួលយកភស្តុតាងដោយពុំមានការសួរផ្ទុញ អ្នកនិពន្ធលើកាលៈទេសៈដែលខ្លួនផ្តល់បទសម្ភាសន៍ឲ្យនោះទេ ឬក៏ដោយមិនគិតថា គាត់នោះមិនមានមេធាវីរបស់ខ្លួន។ ខ្ញុំគិតឃើញថានេះគឺជាការប្រើប្រាស់មធ្យោបាយដូចគ្នានៃភាគីការពារក្តីប្រឆាំងទៅនឹងសហព្រះរាជអាជ្ញា ទាក់ទងទៅនឹងការទទួលយកបាននៃភស្តុតាង។

[១៥:០១:៣៣]

គ្រាន់តែដោយច្បាស់គឺថាមធ្យោបាយដំណោះស្រាយគឺថា តាមរយៈរឿងក្តីរបស់ *អាលីឡូវិច* នោះដែលតុលាការកំពូលបានយល់ឃើញថា ហើយនិងធ្វើសម្រេចជាស្ថាពរថា ទោះបីជាទាក់ទងទៅនឹងភាពយថាភាពនៃឯកសារនោះក៏ដោយគឺថា ខ្លួនមានឆន្ទានុសិទ្ធិក្នុងការសម្រេចលើរឿងទាំងអស់នេះទៅតាមស្ថានភាពនៃបុព្វហេតុនេះ។ នៅពេលដែលអង្គជំនុំជម្រះបានកំណត់លើភាពទទួលយកបាននៃឯកសារទាំងអស់នេះ អ៊ីចឹងដូច្នេះ កាលនោះមានៗតម្រូវឲ្យមានការទទួលយកនូវ-- ពុំមានការតម្រូវឲ្យមាន-- តម្រូវឲ្យមានការធ្វើលើ ការដេញដោលផ្ទាល់នោះទេ។ នៅក្នុងបទអន្តរាគមរបស់សហព្រះរាជអាជ្ញាមុននោះគឺថា នេះជាអ្វីដែលយើងត្រូវធ្វើតែម្តង។ នៅពេលដែលយើងប្រើពាក្យថា “កាតព្វកិច្ច” ខ្ញុំមិនមែនថាកំពុងតែបញ្ហាថានោះទេ នៅទីនេះក៏ដូចគ្នាដែរ គឺថាខ្ញុំនៅទីនេះខ្ញុំគ្រាន់តែចង់រំឭកថា ទៅដល់ភាគីការពារក្តីថា គឺជា-- គឺថាអង្គជំនុំជម្រះ-- គឺថាខាងភាគីការពារក្តីខ្លួនឯងទេដែលត្រូវ (សូមទោស អ្នកបកប្រែសូមកែប្រែ៖) គឺថាអង្គជំនុំជម្រះមានសិទ្ធិសម្រេចលើភស្តុតាង ឬភាពអាចទទួលយកបានលើលក្ខណៈវិនិច្ឆ័យលើភាពជឿជាក់លើភស្តុតាងទាំងអស់នោះ។

[១៥:០៣:៤០]

បើខ្ញុំគិតថាសហព្រះរាជអាជ្ញាបានផ្តល់ព័ត៌មានលើសពីអនុស្សរណៈដែលនៅក្នុងនោះមានចែងថា ដែលមានតម្រុយគ្រប់គ្រាន់ហើយទាក់ទងទៅនឹងភាពអាចទទួលយកបានហើយនិងភាពពាក់ព័ន្ធ។ ហើយថ្ងៃរសៀលនេះតែម្តងគឺថាគាត់បង្ហាញពីភាពស៊ីសង្វាក់គ្នាផងដែរ ដោយផ្អែកលើឧទាហរណ៍របស់ខាងភាគីការពារក្តីដែលបានលើកឡើងហ្នឹង។ អ៊ីចឹងការពន្យល់ពីតម្រុយ ការផ្តល់តម្រុយនេះគ្រប់គ្រាន់ហើយ ដែលនាំឲ្យទាញការសន្និដ្ឋានមួយសមហេតុសមផល គឺថាបានន័យថា សរុបទៅបានន័យថាភស្តុតាងទាំងអស់នេះ គឺត្រូវតែទទួលយកបាន។

[១៥:០៤:៣១]

អស់លោកចៅក្រមជាទីគោរព ការទទួលយកឯកសារអស់នេះមិនមែនបានន័យថា ទទួលជាឯកសារមូលដ្ឋានដែលថា ចៅក្រមនឹងផ្អែកលើដើម្បីចេញសេចក្ដីសម្រេចទៅលើជនជាប់ចោទនោះទេ ក៏ប៉ុន្តែគឺជាឯកសារដែលតម្លៃភស្តុតាងនោះ វាតិចជាងឯកសារផ្សេងទៀត គឺថា គឺជាឯកសារដែលថា វាមានតម្លៃតិចជាងអ្វីដែលដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏ភាគីផ្សេងៗទៀត ចង់មកបង្ហាញទេ។ អ៊ីចឹងទេ លោក នួន ជា គាត់ក៏ចង់មកនិយាយដើម្បីការពារប្រយោជន៍របស់គាត់ដែរ លើអង្គហេតុដែលគេចោទប្រកាន់ទៅលើគាត់នោះ។ ដូច្នេះឥឡូវនេះ យើងមិននិយាយអំពីតម្លៃភស្តុតាងដែលថាយើងចង់ដាក់ជូននោះទេ ដែលថាលោកសហព្រះរាជអាជ្ញាដាក់ជូននោះទេ ក៏ប៉ុន្តែវាជាការផ្ទៀងផ្ទាត់លើភាពអាចទុកចិត្តបាន ឬក៏ការភាពពាក់ព័ន្ធនោះ ដែលយើងអាចទទួលយកបានឬក៏អត់។ យើងទាំងអស់គ្នាជឿជាក់លើតម្រុយដែលមាន យើងទាំងអស់គ្នាក៏យល់ ថាការទាមទាររបស់ភាគីការពារក្ដីពុំមានហេតុផលទេ។ អ៊ីចឹង គឺថាដូច្នេះ ពីព្រោះថាដោយសារខាងភាគីការពារក្ដីខ្លួនឯងនេះ បានផ្ដល់ឯកសារមួយចំនួនដូចតទៅនេះ ដូចជាសៀវភៅរបស់លោក ខៀវ សំផន ជាដើមនោះ ដែលមានយោងជាភាសាបារាំងគឺថា 00595365 - 00595365 លោកចៅក្រម ឡាវែន៍ បានប្រើ-- បានអាន-- យកឯកសារនេះមកប្រើនៅថ្ងៃមុន ពេលដែលគាត់ចង់សួរសំណួរទៅលោក ខៀវ សំផន ដើម្បីចង់បានសេចក្ដីបញ្ជាក់មួយនោះ។ ហើយនៅពេលនោះលោក ខៀវ សំផន បានបញ្ជាក់ថាគាត់ពិតជាអ្នកនិពន្ធមែន ហើយមាន-- កាលណោះមានវគ្គមួយចំនួនដែលលោកចៅក្រមបានអានជូនផងដែរ។

[១៥:០៧:០៥]

អ្វី-- ឥឡូវនេះ អ្វីដែលខ្ញុំចង់លើកឡើងនោះ គឺថាៗគួរឲ្យភ្ញាក់ផ្អើលណាស់ បន្ទាប់ពីសរសេរសៀវភៅនៅទំព័រទី១២នោះ សៀវភៅរបស់ខ្លួនផ្ទាល់នោះ។ បាទ ខ្ញុំសូមអាន ព្រឹត្តិការណ៍ភាគច្រើនដែលខ្ញុំបានលើកឡើងនោះ គឺជាព្រឹត្តិការណ៍ដែលគេស្គាល់ទាំងអស់គ្នា។ អ៊ីចឹង ខ្ញុំផ្អែកលើការស្រាវជ្រាវជាច្រើន ដើម្បីឲ្យបានដឹងពីកាលបរិច្ឆេទច្បាស់លាស់ ហើយនិងដើម្បីចាំអំពីហេតុការណ៍ទាំងឡាយដែលបានភ្លេចមកហើយ។ តើ-- ហើយការផ្សងព្រេងរបស់នេះ គឺថាវាអាចមានភាពចម្រូងចម្រាសជាមួយអ្នកនិពន្ធដែលខ្ញុំបានអាន គឺថាអាចមានចំណុចខ្លះ ខ្ញុំគាំទ្រអ្វីដែលគាត់និយាយ ចំណុចខ្លះ ខ្ញុំមិនគាំទ្រ។ ហើយនៅវគ្គខាងក្រោយទៀត នៅក្នុងសៀវភៅដដែលនោះ លោក ខៀវ សំផន បានបដិសេធព័ត៌មានមួយចំនួន។ ឧទាហរណ៍នៅទំព័រទី៤៣ ដែលធ្វើការសន្និដ្ឋានថា ដោយសារឯកសារនៅក្នុងដែលប្រមូលយកទៅដាក់នៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺថាសុទ្ធតែជាការឯកសារជាសន្ទុតជាមុន។ លោក

ខៀវ សំផន ដោយខ្លួនគាត់ផ្ទាល់តែម្ដង ដែលថានៅក្នុងសៀវភៅមួយដែលលោកជាអ្នកនិពន្ធ ហើយលោកបាននិយាយ ដឹងថាលោកបានធ្វើការស្រាវជ្រាវនូវឯកសារនៅមជ្ឈមណ្ឌលកម្ពុជា ឌី.ស៊ី.ខេម ហើយលោកបានប្រើឯកសារស្រាវជ្រាវផ្សេងៗទៀត ដើម្បីរំឭកឡើងវិញនូវព្រឹត្តិការណ៍ដែលកើតឡើងក្នុងសម័យខ្មែរក្រហម ឬក៏ពីមុនមក។

[១៥:០៨:៥៦]

ហើយសព្វថ្ងៃនេះ បច្ចុប្បន្ននេះ លោក ខៀវ សំផន ហាក់ដូចជាចង់ឲ្យតុលាការជឿថាលោកយោងទៅឯកសារទាំងអស់នោះ ដោយមិនចង់ឲ្យអ្នកនិពន្ធនោះ-- មិនចង់ឲ្យអ្នកនិពន្ធទាំងអស់នោះ មកមានវត្តមាននៅទីនេះ គឺថាជាការប៉ះពាល់ដល់សិទ្ធិរបស់គាត់។

ដូច្នេះឥឡូវនេះ យើងចូលមកនិយាយអំពីការមានហេតុផលវិញតែម្ដង។ បើសិនជា លោកទទួលយកឯកសារទាំងអស់នេះ ដោយពុំមានកត់សម្គាល់បន្ថែមនោះទេ គឺថាវាមានបញ្ហា។ នៅក្នុងករណីលោក អៀង សារី នៅក្នុងអនុស្សរណៈរបស់គាត់ នៅចុះថ្ងៃទី-- ថ្ងៃទី១ មេសា ឆ្នាំ២០១១ ដែលមានចំណងជើងថា "អៀង សារី បញ្ជីបឋម-- ភស្តុតាងបឋមរបស់គាត់"។ មានបញ្ជីឯកសារបឋមដែលបានដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះ។ ឯកសារនេះមានលេខ ENR ជាភាសាអង់គ្លេស 00658454 ជាភាសាខ្មែរ 00664458។ បាទ នៅក្នុងឯកសារនេះ លោកចៅក្រមជាទីគោរព លោក សារី ខ្លួនឯងផ្ទាល់តែម្ដង បានបង្ហាញថា-- បង្ហាញជូនដល់អង្គជំនុំជម្រះថា គាត់ចង់យោងទៅនឹងឯកសារទាំងអស់នេះ ឯកសារដែលបានប្រមូលដោយសហចៅក្រមស៊ើបអង្កេត ហើយចាត់ទុកថាអង្គជំនុំជម្រះមានសិទ្ធិ-- អានេះខ្ញុំសូមលើកយកកថាខណ្ឌទី១២ នៃអនុស្សរណៈនេះ គាត់ថាគាត់នឹងចង់ដាក់ផ្សេងទៀត ដូច្នេះបង្ហាញឲ្យឃើញថា លោក អៀង សារី ហើយនិងមេធាវីរបស់ខ្លួនបានផ្ដល់ភាពជឿជាក់គ្រប់គ្រាន់ទៅដល់ក្នុងបញ្ជីឯកសារទាំងអស់នេះ។ ដូច្នេះ ឥឡូវថ្ងៃនេះយើងមានការភ្ញាក់ផ្អើលមែនទែន ដោយឃើញថា គាត់ត្រឡប់មកនិយាយអំពីឯកសារដដែលនេះ ហើយតម្រូវលក្ខខណ្ឌ ហើយមិនអនុលោមទៅតាមច្បាប់ ឬក៏បទដ្ឋានអីផ្សេងនោះ ដោយសារពេលវេលានិយាយរបស់នេះជិតអស់ទៅហើយ។ អ៊ីចឹងសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសូមគូសបញ្ជាក់ លើសពីការទទួលខុសត្រូវដែលយើងត្រូវទទួលបន្ទុកក្នុងការការពារនៃការ-- ក្នុងឋានៈជាអ្នកការពារក្ដីលោកក៏មានកាតព្វកិច្ចក្នុងការធ្វើយ៉ាងណា ដើម្បីឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដែលថា ជាដែលមានជនរងគ្រោះដែលថាគាត់ទទួលរងឧក្រិដ្ឋកម្មនោះ។ អ៊ីចឹងខាងការពារក្ដីក៏មានកាតព្វកិច្ចក្នុងការធ្វើយ៉ាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីមានភាគីពេញ

សិទ្ធិនៅក្នុងរឿងជម្រះសេចក្ដីនេះ ហើយនិងទទួលសិទ្ធិគ្រប់គ្រាន់។

[១៥:១២:៤៩]

អ៊ីចឹងអ្វីដែលគាត់ទទួលរងនោះ គឺថាសំដៅលើបង្កើតឲ្យមានតុល្យភាពនៅក្នុងរឿងជំនុំជម្រះ ទាក់ទងទៅនឹងសេចក្ដីថ្លែងការណ៍របស់ជនជាប់ចោទខ្លួនឯងផ្ទាល់ ដោយសារមិន-- ដោយសារថាយើងថាមិនមែនថាសេចក្ដីប្រកាសរបស់គាត់នេះ ដើម្បីទម្លាក់បន្ទុកទៅលើគាត់នោះទេ។ ដូច្នេះ-- អ៊ីចឹង គឺថាពុំមានហេតុផលណាជាលក្ខណៈអត្តនោម័តិ ដែលថាខាងភាគីការពារក្ដីនោះបដិសេធឯកសារដែលថាជាសេចក្ដីថ្លែងការណ៍របស់ខ្លួនឯងនោះទេ។ ដូច្នេះ សូមឲ្យអង្គជំនុំជម្រះអនុវត្តឆន្ទានុសិទ្ធិរបស់គាត់ដើម្បីធ្វើការវាយតម្លៃ។

សូមអរគុណ។

[១៥:១៣:៤៦]

**ប្រធានអង្គជំនុំ៖**

បាទសូមអរគុណលោកមេធាវី។ មកដល់ពេលនេះ យើងបានស្ដាប់ការជំទាស់ទៅលើឯកសារ A1 រួចហើយ។ ដូច្នេះបន្តស្ដាប់ការជំទាស់លើឯកសារ A2។ ជាបន្ត ហើយអង្គជំនុំជម្រះទុកពេលវេលាពីរម៉ោង ដើម្បីមេធាវីការពារក្ដីលើកឡើងនូវការជំទាស់ ហើយរយៈពេលពីរម៉ោងនេះ មេធាវីការពារក្ដីអាចបែងចែកទៅក្រុមនីមួយៗដោយខ្លួនឯងក៏បាន។ ប្រសិនបើមេធាវីទាំងបីក្រុម គ្មានការបែងចែកទេនោះមេធាវីការពារក្ដីក្រុមនីមួយៗមានរយៈពេល ៤០នាទីក្នុងការធ្វើសេចក្ដីថ្លែងការជំទាស់នេះ។

ហើយជាដំបូងនេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្ដី នួន ជា ដើម្បីមានឱកាសក្នុងការឡើងធ្វើការជំទាស់ចំពោះឯកសារ A2។

សូមអញ្ជើញ!

[១៥:១៥:០០]

**លោក អេនគ្រូ អ៊ីន្ទូហ្វ៊ី៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម គឺខ្ញុំយល់ឃើញថាប្រហែលជាមួយម៉ោងដែលខ្ញុំមាន ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

មួយក្រុមគឺមានពេលវេលា៤០នាទី។ ដោយសារមិនមានការបែងចែកផ្សេងពីនេះ គឺលោក មួយ

ក្រុមនីមួយៗហ្នឹង គឺមានពេលវេលាតែ៤០នាទីទេ។

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

គឺ សូមអរគុណ។ យ៉ាងហោច-- យ៉ាងណាក៏ដោយ ខ្ញុំនឹងនិយាយដោយសង្ខេប ឆ្លើយតបទៅនឹងការជំទាស់ទៅលើឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមកែតម្រូវអំពីពេលវេលាអម្បាញ់មិញ ដែលបានផ្តល់ឲ្យតាមនូវការកែតម្រូវដោយការកត់សម្គាល់របស់ចៅក្រមប្រឹក្សា ឃើញថាពេលវេលាដែលផ្តល់ឲ្យទៅមេធាវីទាំងបីក្រុមហ្នឹងគឺរយៈពេលមួយម៉ោង។ ដូច្នេះសម្រាប់មេធាវីនីមួយៗ មួយក្រុមៗមានពេលវេលា២០នាទី។

សូមអញ្ជើញ!

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណ ដូចដែលខ្ញុំជម្រាបអ៊ីចឹង គឺខ្ញុំនឹងនិយាយដោយសង្ខេប ខ្ញុំនឹងព្យាយាមនិយាយដោយលម្អិតផងដែរ។ ពាក់ព័ន្ធទៅនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធពីរ ដែលជាបញ្ជីឯកសាររបស់លោកសហព្រះរាជអាជ្ញា គឺឯកសារលេខ E109/4.2 ខ្ញុំមានចំណុចចំនួនបីដែលត្រូវលើកឡើង។ ជាបឋមគឺខ្ញុំសូមយោងទៅលើការជំទាស់ទូទៅរបស់ខ្ញុំ ដែលខ្ញុំបានលើកឡើងកាលពីម្សិលមិញពេលព្រឹក។ ដូច្នេះខ្ញុំសូមបញ្ចូលជាឯកសារយោងនៅក្នុងការធ្វើសន្និដ្ឋានរបស់ខ្ញុំជារួម។

ចំណុចទីពីរ ដែលខ្ញុំចង់លើកឡើង គឺខ្ញុំសូមយោងទៅលើសេចក្តីសន្និដ្ឋានរបស់លោក ហ្សាស្តើប៉ៅ ដែលគាត់លើកឡើងអំពីបញ្ហាឯកសារ ឌី.ស៊ី.ខេម។ ដែលគាត់ក្នុងនោះស្នើសុំឲ្យលោក ឆាំង យុចូលខ្លួនមកក្នុងតុលាការ។

[១៥:១៨:១៣]

ដូច្នេះសឹងតែឯកសារទាំងអស់ ឬក៏ឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធពីរ គឺហុចមកពីខាង ឌី.ស៊ី.ខេម។ ដូច្នេះខ្ញុំសូមជំទាស់ដែលថាយើងដាក់ឯកសារទាំងអស់របស់ ឌី.ស៊ី.ខេម ហើយយើងគួរតែកុំសូវផ្អែកទៅលើភាពទុកចិត្តទៅលើឯកសារទាំងអស់នេះ។ ជាបឋមត្រូវតែស្តាប់ចម្លើយលោក ឆាំង យុសិន បើសិនមិនដូច្នោះទេ គឺយើងមិនអាចទទួលយកបានទេឯកសារទាំងអស់នោះ។

ចំណុចចុងក្រោយ ពាក់ព័ន្ធទៅនឹងឯកសារចំនួនមួយក្នុងបញ្ជីដែលវាមានលក្ខណៈច្របូកច្របល់ យើងមិនដឹងថាតើវាជាឯកសារ ឌី.ស៊ី.ខេម ឬក៏អត់នោះទេ?

ឯកសារលេខ D200/2.1.2 ដែលជាសេចក្ដីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងមន្ទីរ ៨៧០។ ឯកសារនោះ វាហាក់ដូចជាព្យាយាមធ្វើយ៉ាងណាឲ្យមានយថាភាព ដែលឯកសារនេះផ្ដល់ចម្លើយដោយ សេង ម៉ុន។ ខ្ញុំសូមបញ្ជាក់ថា ប្រសិនបើចៅក្រមពឹងផ្អែកទៅលើឯកសារនេះដើម្បីបង្ហាញអំពីតួនាទី និងអំពើរបស់ជនជាប់ចោទ គឺយើងគួរតែនាំ សេង ម៉ុន នេះមកចូលរួមក្នុងតុលាការ ដើម្បីឲ្យមានការតទល់ដោយជនជាប់ចោទ។ សូមអរគុណ។

[១៥:១៩:៤៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ជាបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកាទៅមេធាវីការពារក្ដីលោក អៀង សារី។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្ដី លោកប្រធាន លោក លោកស្រី ចៅក្រមនៅក្នុងបន្ទប់សវនាការ និងជុំវិញសវនាការ។ ខ្ញុំក៏និយាយដោយសង្ខេបផងដែរ ដោយសារតែយើងបានបញ្ជាក់អំពីលក្ខណៈទូទៅរួចមកហើយ នៃការជំទាស់របស់យើងខ្ញុំ។ យើងបានដាក់ឧបសម្ព័ន្ធរបស់ ដែលយើងគិតថា ឧបសម្ព័ន្ធនោះ គឺជាឧបសម្ព័ន្ធមួយច្រំដែល ប្រសិនបើយើង លោក លោកស្រីមើលទៅលើការជំទាស់របស់ខ្ញុំទៅលើឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធពីរ គឺខ្ញុំនឹងលើកឡើងនៅពេលបន្តិចទៀតនេះ។

យើងខ្ញុំគិតថា ឯកសារទាំងអស់នោះនៅក្នុងឧបសម្ព័ន្ធពីរ គួរតែត្រូវបដិសេធចោល លើកលែងតែសហព្រះរាជអាជ្ញាអាចបង្ហាញអំពីយថាភាព ភាពទុកចិត្តបាន និងភាពពាក់ព័ន្ធនៃឯកសារ ហើយអាចបង្ហាញអំពីករណីថា តើនរណាគេជាអ្នករៀបចំឯកសារនោះឡើង? ដូច្នេះ ដើម្បីបំពេញលក្ខខណ្ឌទាំងអស់នេះបាន ជំហររបស់យើងខ្ញុំនោះគឺថា យើងអាចទទួលយកបាន។

[១៥:២១:១៨]

ប្រសិនបើមិនអាចបំពេញលក្ខខណ្ឌទាំងអស់នោះទេ យើងសូមឲ្យបដិសេធចោល។

ក្នុងករណីដែលទទួលយកឯកសារទាំងអស់នោះៗ គឺយើងខ្ញុំក៏ស្នើដូចពីមុនអ៊ីចឹង។ នៅពេលដែលយើងវិភាគវាយតម្លៃទៅលើតម្លៃ និងទម្ងន់នៃភស្តុតាង យើងគួរតែពិចារណាអំពីលក្ខខណ្ឌដូចដែលខ្ញុំលើកឡើង ថាតើគេនរណាគេជាអ្នកបង្កើតឯកសាររៀបចំឯកសារ និងស្ថានភាពយ៉ាងម៉េចនៅពេលដែលគេរៀបចំឯកសារ?

ឧបសម្ព័ន្ធពីរ ចំពោះឧបសម្ព័ន្ធពីរ ឯកសារចំនួនបីដូចដែលខ្ញុំបានលើកឡើង D366/7.9, D366/7.1.32 ឯកសារមួយទៀត D366/1.23 ចំពោះឯកសារទាំងអស់នេះ ដូចដែលខ្ញុំបានបញ្ជាក់វាជាឯកសារដែលខ្ញុំបានជំទាស់ជាលក្ខណ:ទូទៅ។ ដូចដែលខ្ញុំបាននិយាយនាពេលមុននោះ គឺថា ប្រសិនបើសហព្រះរាជអាជ្ញា មានសាក្សីដែលត្រូវបង្ហាញលើឯកសារនេះ គួរតែដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធនេះ។ នៅពេលនេះ សហព្រះរាជអាជ្ញាដឹងហើយថា យើងធ្វើការជំទាស់អំពីភាពអាចទទួលយកបាននៃឯកសារទាំងអស់នោះ។

ដូច្នេះហើយ គឺសហព្រះរាជអាជ្ញាក៏បានស្នើសុំឱ្យមានសវនាការនេះឡើង។

[១៥:២២:៥៣]

សហព្រះរាជអាជ្ញា ជាអ្នកត្រូវតែបង្ហាញថា សាក្សីទាំងនោះដែលយើងដាក់មកនេះ ជាអ្នកបង្ហាញដើម្បីឱ្យយើងអាចបំពេញលក្ខខណ្ឌនៃភាពអាចទទួលយកបាននៃឯកសារ។ ខ្ញុំគិតថា វាមិនគ្រប់គ្រាន់ទេ ដែលសហព្រះរាជអាជ្ញាលើកឡើងថា យើងបានបង្ហាញរួចហើយ នៅក្នុងហ្នឹង ហើយចំពោះម្ហូលនោះនៅក្នុងសមុទ្រនោះយើងគួរតែទៅរកខ្លួនឯងទៅ។

ដូច្នេះប្រសិនបើនិយាយដូច្នេះ ថាតើយើងអាចបង្ហាញអំពីភាពអាចទុកចិត្តបាន និងយថាភាពយ៉ាងម៉េចទៅលើឯកសារ ហើយចៅក្រមមានលទ្ធភាពយ៉ាងម៉េចក្នុងការសម្រេចថាតើឯកសារនោះទទួលយកបាន ឬក៏មិនបាន ប្រសិនបើលើកឡើងត្រឹមតែប៉ុណ្ណោះ? សូមអរគុណ។

[១៥:២៣:៣៩]

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវី។ ជាបន្តអង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្ដីជនជាប់ចោទ ខៀវ សំផន។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការ។ ខ្ញុំបាទសូមលើកទាក់ទងទៅនឹងឧបសម្ព័ន្ធទីពីរ ដែលសហព្រះរាជអាជ្ញាបានលើកជាឯកសារសម្រាប់ដាក់បន្ទុក។ នៅក្នុងឧបសម្ព័ន្ធទីពីរនេះ យើងឃើញមានឯកសារចំនួន ៨៣។ នៅក្នុងឯកសារ D158 សហព្រះរាជអាជ្ញាបានរៀបរាប់អំពីតម្រុយនៃភាពជឿជាក់លើឯកសារចំនួន៨៣ នេះ នៅក្នុងឧបសម្ព័ន្ធទីពីរ ហើយដែលបានធ្វើចំណាត់ថ្នាក់ឯកសារទាំងបីប្រភេទនេះតាមឯកសារបោះពុម្ពផ្សព្វផ្សាយ មាន

ទស្សនាវដ្ដីទង់បដិវត្ត ឬយុវជនបដិវត្តជាច្រើនលេខ។ មានសេចក្ដីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា និងមានឯកសារបោះពុម្ពផ្សាយផ្សេងៗទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា។

ចំណោទដ៏សំខាន់នៅពេលនេះ ដែលជាចំណាប់អារម្មណ៍របស់ខ្ញុំគឺថា ការបង្ហាញពីការថែរក្សា នៃខ្សែចង្វាក់របស់ឯកសារដែលទទួលបាននេះ នៅតែជាបញ្ហាដដែល។ ហើយខ្ញុំបាទនឹងលើកយក ឯកសារមួយចំនួនដែលបង្ហាញពីភាពមិនច្បាស់លាស់ ឬក៏ពីចំណុចសង្ស័យដែលមាននៅក្នុងឯកសារ ទាំងនោះ។ អ្វីដែលមាននៅក្នុងឯកសាររបស់សហព្រះរាជអាជ្ញា ដែលលោកអះអាងថា ជាព័ត៌មាន-- ដែលមានព័ត៌មានពិស្ដារនៅក្នុងឧបសម្ព័ន្ធដែលលោកបានលើកនោះ ការពិតមិនមែនជាព័ត៌មានពិស្ដារ ដូចដែលលោកបានអះអាងនោះទេ។ វាជាព័ត៌មានយ៉ាងខ្លី សង្ខេប ហើយខ្វះព័ត៌មានចាំបាច់សំខាន់ៗជា ច្រើនដែលយើងត្រូវការដើម្បីបញ្ជាក់ថា តើឯកសារទាំងអស់នោះទទួលបានដោយលក្ខណៈគួរឲ្យជឿ ឬក៏ជាឯកសារដែលប្រឌិដ្ឋ?

[១៥:២៦:៥០]

ខ្ញុំបាទសូមលើកពីចំណុចទីមួយទាក់ទងទៅនឹងឯកសារបោះពុម្ពផ្សាយ ក្នុងសម័យកាលកម្ពុជា ប្រជាធិបតេយ្យដែលមាន៥៤ឯកសារ។ នៅក្នុងនោះ គឺមានទស្សនាវដ្ដីទង់បដិវត្តចំនួន២៤លេខ ទស្សនា វដ្ដីយុវជនបដិវត្តចំនួន២៨លេខ និងសេចក្ដីសង្ខេបចំនួន២ នៃទស្សនាវដ្ដីទាំងពីរ ចំនួន២លេខផ្សេង ទៀត។ សេចក្ដីសង្ខេបចំនួនពីរនៃទស្សនាវដ្ដីទាំងពីរលេខនេះ សហព្រះរាជអាជ្ញាមិនបានផ្ដល់នូវព័ត៌មាន ណាមួយដែលអាចឲ្យយើងជឿជាក់ថា ឯកសារទាំងនោះជាឯកសារចម្លងត្រឹមត្រូវតាមឯកសារដែល រៀបរៀងតាមលក្ខណៈសង្ខេបពិតប្រាកដនោះទេ។

[១៥:២៧:៥៨]

លើសពីនេះទៀត សហព្រះរាជអាជ្ញាបានបង្ហាញថា មិនមានឯកសារចម្លងនោះទេ។ ដូច្នេះមិន អាចធានាបានថាសេចក្ដីសង្ខេបនោះ ពិតជាសង្ខេបចេញពីទស្សនាវដ្ដីទាំងពីរលេខពិតប្រាកដនោះ ឡើយ។ ចំពោះទស្សនាវដ្ដីទង់បដិវត្ត ឬយុវជនបដិវត្ត សហព្រះរាជអាជ្ញានិយាយថា ទស្សនាវដ្ដីចំនួន៤៨ លេខក្នុងចំណោម៥២លេខ ត្រូវបានមជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម ប្រមូលពីបណ្ណសារដ្ឋានទួលស្លែង នៅឆ្នាំ១៩៩៩។

ព័ត៌មានដែលយើងទទួលបាននេះ មិនទាន់គ្រប់គ្រាន់ទេ រាល់លើកនៅពេលដែលសហព្រះរាជ អាជ្ញាផ្ដល់នូវព័ត៌មានដែលទាក់ទងនឹងខ្សែចង្វាក់នៃការថែរក្សាឯកសារ សហព្រះរាជអាជ្ញាតែងតែកម្រិត

ត្រឹមភ្ជាប់តែនឹងមូលដ្ឋានទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម តែប៉ុណ្ណោះ។

[១៥:២៩:៥១]

គេត្រូវត្រឡប់ទៅសម្លឹងមើលឲ្យឆ្ងាយជាងនេះបន្តិច ខ្ញុំបានលើករួចហើយកាលពីថ្ងៃចន្ទ ត្រង់ចំណុចដែលយើងចាប់អារម្មណ៍លើបណ្ណសារដ្ឋានទួលស្លែងនោះ។ ចំណុចដែលយើងអាចបង្ហាញនូវភាពសង្ស័យនោះគឺថា មជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម គាត់បានទទួលឯកសារពីមជ្ឈដ្ឋានមួយ ឬក៏ពីបុគ្គលណាម្នាក់។ ក៏ប៉ុន្តែអ្វីដែលខ្វះចន្លោះនោះគឺថា តើឯកសារដែលទទួល ដែលបុគ្គលម្នាក់នោះ ឬក៏បណ្ណសារដ្ឋានបានទទួលនោះចេញពីប្រភពណាទៀតគឺអត់បានដឹងទេ គឺដាច់ព័ត៌មានត្រឹមតែថា មជ្ឈមណ្ឌលឯកសារទទួលព័ត៌មានពីកន្លែងមួយ ឬពីបុគ្គលណាមួយម្នាក់ហើយក៏ចប់ត្រឹមហ្នឹង។ ប៉ុន្តែឯកសារមែនទែនទៅ វាអាចកើតចេញពីប្រភពផ្សេង វាអាចចេញពីទីកន្លែងផ្សេង និងពេលវេលាផ្សេងទៀតដែលធ្វើឲ្យមានការសង្ស័យចំពោះការជឿលើឯកសារ លើខ្លឹមសារឯកសារដែលមាននោះ។

[១៥:៣១:២៩]

ចំពោះទស្សនាវដ្ដីបួនលេខដែលមាននៅក្នុងបណ្ណសារដ្ឋានទួលស្លែង គឺមិនមានប្រភពច្បាស់លាស់ទេ។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ទស្សនាវដ្ដីពីរលេខត្រូវបានកត់ត្រាថា បានទទួលពីសម្ដេច ហ៊ុន សែន។ រីឯទស្សនាវដ្ដីពីរលេខទៀតត្រូវបានផ្ដល់ដោយ-- ដូច្នេះសហព្រះរាជអាជ្ញាមិនបានពន្យល់ថា តើអក្សរ "អេច" ឬក៏អក្សរ "ហាស" ដាក់ក្នុងរង្វង់ក្រចកនៅក្នុងភាសាលេខកូដមានន័យយ៉ាងណាទេពីព្រោះ អក្សរ "អេច" ឬក៏អក្សរ "ហាស" ដែលលោកសហព្រះរាជអាជ្ញាបានទទួលនោះគឺមិនបានបញ្ជាក់។ អ៊ីចឹងសួរថា តើជាបុគ្គលមនុស្ស ឬជាស្ថាប័នសាធារណៈ ឬជាអ្វីផ្សេងទៀត?

[១៥:៣២:៥៤]

សហព្រះរាជអាជ្ញាមិនបានផ្ដល់ព័ត៌មាន មានប្រយោជន៍ណាមួយស្ដីពីកាលៈទេសៈនៃការរកឃើញឯកសារទាំងនោះឡើយថា តាមរយៈសម្ដេច ហ៊ុន សែន ឬតាមរយៈប្រភព "អេច" អក្សរ "ហាស" ដែលគេមិនស្គាល់អត្តសញ្ញាណនោះ។ ថាតើឯកសារទាំងនោះបានមកនៅពេលណា? ទីកន្លែងណា? ពីអ្នកណា? តទៀត សហព្រះរាជអាជ្ញាក៏មិនបាន បានបង្ហាញប្រាប់ថា លោក ឆាំង យុ បានប្រកាសថា មជ្ឈមណ្ឌល ឌី.ស៊ី.ខេម មជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម មានឯកសារដើមមួយចំនួនក្នុងចំណោមឯកសារទាំងនេះ ហើយថាលោក ឈូក រិន បានបញ្ជាក់យថាភាពនៃឯកសារមួយក្នុងចំណោមឯកសារទាំងនោះ។

ដូច្នេះយើងខ្ញុំមានបំណងចង់ឲ្យបង្ហាញឯកសារដើមទាំងនោះនៅក្នុងសវនាការ ព្រមទាំងសូមឲ្យកោះហៅលោក ឈូក រិន មកបង្ហាញខ្លួនក្នុងតុលាការផងដែរ។ បើពុំនោះទេ គេមិនអាចផ្តល់តម្លៃគួរឲ្យជឿជាក់ណាមួយដល់ឯកសារទាំងនោះឡើយ។

[១៥:៣៤:៣២]

ក្រុមប្រឹក្សាជំនុំជម្រះជាទីគោរព ចំណុចទីពីរ ខ្ញុំបាទសូមលើកពីសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា៖ ជាបឋមទាក់ទងទៅនឹងឯកសារមួយចំនួនដែលសហព្រះរាជអាជ្ញាបញ្ជាក់ថា វាគ្មានទាំងលេខរបស់មជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម នោះទៀតផង។ សហព្រះរាជអាជ្ញាទទួលថា មិនមានព័ត៌មានពីភាពដើមរបស់ឯកសារទាំងនោះទាល់តែសោះ។ ចំពោះឯកសារផ្សេងទៀត សហព្រះរាជអាជ្ញាបានបញ្ជាក់នៅក្នុងនោះមានឯកសារបួន ត្រូវបានរកឃើញនៅបណ្ណសារដ្ឋានទួលស្លែងថាគ្មាន វាគ្មានប្រយោជន៍ ពីព្រោះថាគ្មានព័ត៌មានគ្រប់គ្រាន់សម្រាប់បញ្ជាក់ពីភាពគួរឲ្យជឿជាក់បាននៃឯកសារនោះ។ បន្ទាប់មក សហព្រះរាជអាជ្ញាបានបង្ហាញថាឯកសារមួយនៃឯកសារទាំងនោះទំនងជាលោក ប៊ែន ឃៀរណាន-- លោក ប៊ែន ឃៀរណាន ខ្ញុំសូមប្រកបឈ្មោះ "B-E-N" ប៊ែន, ឃៀរណាន "K-I-E-R-N-A-N" បានប្រគល់ឲ្យមជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម ហើយឯកសារពីរទៀត ត្រូវបានប្រគល់ឲ្យ ឌី.ស៊ី.ខេម ដោយលោក ដាវីត ហក។ ដាវីត ហក ខ្ញុំសូមប្រកប "D-A-V-I-D H-A-W-K" ។ ចំណែកឯឯកសារដែលត្រូវបានប្រគល់ដោយលោក ប៊ែន ឃៀរណាន មានលេខសម្គាល់ IS6.3 គឺជាឯកសារពាក់ព័ន្ធនឹងសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។

វាចំណុចផ្ទុយគ្នាពីការទទួលបានឯកសារនេះ ដូចខ្ញុំបានលើកសង្ខេបកាលពីថ្ងៃច័ន្ទ យើងមានបញ្ហាជាមួយនឹងឯកសារនេះ ព្រោះយើងមានព័ត៌មានខុសគ្នា យើងទទួលព័ត៌មានខុសគ្នា ពីកាលៈទេសៈដែលរកឃើញឯកសារនោះផងដែរ។

[១៥:៣៨:០៧]

តាមនាយក ឌី.ស៊ី.ខេម មជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម ឯកសារនេះទំនង-- គាត់ឆ្លើយថា គាត់បានបង្ហាញថាឯកសារនេះ ទំនងត្រូវបានអ្នកតំណាងរណសិរ្ស។ រណសិរ្សកាលណោះគឺប្រហែលជារណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាប្រគល់ឲ្យលោក ខៀវ កាញ៉ារិទ្ធ បន្ទាប់ពីតុលាការបដិវត្តន៍ឆ្នាំ១៩៧៩ បានកាត់ទោសរួចរាល់ហើយ គឺកាត់ទោសក្នុងករណីប៉ុល ពត, អៀង សារី កាលពីឆ្នាំ៧៩នោះ។ ផ្ទុយទៅវិញ លោក ខៀវ កាញ៉ារិទ្ធ បាននិយាយថា គាត់រកឃើញឯកសារនោះដោយខ្លួនឯង។

ស្របជាមួយនឹងកំណត់ហេតុប្រជុំនានារបស់គណៈអចិន្ត្រៃយ៍ គឺថាគាត់បានរកឃើញនៅផ្ទះមេដឹកនាំខ្មែរក្រហម គឺនៅតាមបណ្តោយផ្លូវកម្ពុជាក្រោមនៅក្រុងភ្នំពេញ។

ដូច្នេះ យើងឃើញថាប្រភពនៃការទទួលបានឯកសារនេះ វាជាចំណុចសង្ស័យដែលអាចធ្វើឲ្យយើងគិតដល់ខ្លឹមសារ ថាតើជាខ្លឹមសារដែលយើងអាចទទួលយកបានពុំមានការកែច្នៃ ឬមួយយ៉ាងណានោះ? ហេតុនេះ យើងក៏មិនដឹងប្រាកដថា តើឯកសារនោះបានមកពីណា? ដោយសារយើងមានព័ត៌មានខុសគ្នាពីរយ៉ាងនេះ។ ក្នុងចំណុចនេះ វាមានសារៈសំខាន់សម្រាប់ការការពារ មេធាវីការពារពីព្រោះវាអាចបំភ្លឺពីចំណុចសង្ស័យនានាដែលជាប់ពាក់ព័ន្ធទៅនឹងការកើតឡើងនៃឯកសារ។ ចាប់តាំងពីថ្ងៃច័ន្ទមក យើងអាចពិនិត្យមើលលិខិតឆ្លើយឆ្លងគ្នារវាងលោក ប៉ែន ឃៀរណាន និងសហចៅក្រមស៊ើបអង្កេតពីបញ្ហាឯកសារលេខ D269/4។ ហើយឯកសារនេះត្រូវបានចាត់ទុកថាជាឯកសារសម្ងាត់បំផុត ដូច្នេះយើងមិនអាចដឹងថា ឯកសារនោះមានខ្លឹមសារអ្វីពិតប្រាកដទេ រហូតមកដល់ពេលនេះ។

[១៥:៤១:៣៨]

ចំណុចទាក់ទងទៅនឹងសេចក្តីសម្រេចរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ យើងឃើញថាឯកសារដែលទទួលបានទាំងអស់សុទ្ធតែមានចំណុចសង្ស័យ ដោយឡែក ដោយហេតុថាព័ត៌មានដែលទទួលបានតាមរយៈមជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម។ ត្រឹមតែរយៈពេលមួយ គឺអាចដប់ឆ្នាំ ឬក៏យូរជាងនេះទៅទៀតបន្ទាប់ពីបានឯកសារនោះត្រូវបានផលិត ត្រូវបានបង្កើតឡើង។ ដូច្នេះក្នុងរយៈពេលនេះវាអាចបង្កើតនៅចំណុចសង្ស័យយ៉ាងច្រើន កាលមិនទទួល-- មិនបានដឹងឲ្យបានច្បាស់ពីការទុកដាក់ឯកសារ ក៏ដូចជាការមិនបានពិនិត្យទៅលើភាពដែលគួរឲ្យជឿជាក់បាននៃឯកសារ ធ្វើឲ្យមានការសង្ស័យ ហើយការសង្ស័យនេះមិនអាចឲ្យក្រុមប្រឹក្សាជំនុំជម្រះយកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តីដាក់បន្ទុកនោះទេ។

ខ្ញុំសូមលើកឧទាហរណ៍ឯកសារមួយ គឺជាឯកសារថ្មីដែលមានលេខ ERN 00079290 ដល់ 00079317 គឺជាឯកសារមួយដែលទទួលបានពីក្រសួងមហាផ្ទៃ ហើយដែលមជ្ឈមណ្ឌលឯកសារបានទទួលយក ក៏ប៉ុន្តែសួរថា តើឯកសារនោះ បានចេញពីឯកសារដើម កូពីបានចេញពីឯកសារដើម ឬគ្រាន់តែជាឯកសារដែលមានកូពីតពីកូពីមកទៀត? កូពីតកូពី។

ដូច្នេះសរុបសេចក្តីមក ខ្ញុំបាទសូមបញ្ជាក់ជំហរថាឯកសារដែលត្រូវដាក់ជូននៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះ ត្រូវតែមានការបង្ហាញអំពីទំនាក់ទំនងនៃការរក្សាឯកសារ និងខ្លឹមសារដើម្បីបញ្ជាក់ពី

ភាពដែលអាចជឿបាននៃឯកសារ។

សូមអរគុណ។

[១៥:៤៦:០៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីការពារក្ដីលោក ខៀវ សំផន ប៉ុន្តែអង្គជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងអំឡុងពេលនៃការថ្លែងការណ៍សេចក្ដីជំទាស់របស់លោកអម្បាញ់មិញនេះ លោកបានភ្លេចភ្លាំង បានប្រើនូវនាមពិតប្រាកដរបស់សាក្សី នៅក្នុងបញ្ជីសាក្សីដើមបណ្ដឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះកំណត់ថានឹងកោះហៅគាត់មកផ្ដល់សក្ខីកម្ម។ នៅក្នុងអំឡុងពេលថ្លែងការណ៍ ឬកិច្ចពិភាក្សាផ្សេងៗប្រសិនបើមានការពាក់ព័ន្ធទៅនឹងសាក្សីដើមណ្ដឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះបានរៀបចំបញ្ជីរួចហើយ ដោយកំណត់នូវរហស្សនាមសម្រាប់ប្រើប្រាស់នោះ គឺលោកមេធាវីត្រូវតែប្រើប្រាស់នូវរហស្សនាមរបស់បុគ្គលដែលពាក់ព័ន្ធ ដែលអង្គជំនុំជម្រះបានកំណត់ថានឹងកោះហៅគាត់មកធ្វើជាសាក្សីផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។

កាលពីម្សិលមិញ យើងមានហេតុស្រដៀងគ្នា ប៉ុន្តែខាងមេធាវីការពារក្ដី នួន ជា គឺបានលើកឡើងសុំការអនុញ្ញាតជាមុនចំពោះប្រធាន អនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយសារហេតុថាលក្ខណៈពិសេសនៃស្ថាប័ននោះ ដោយយើងប្រើប្រាស់ក្នុងកម្រិតប្រធានក្ដី អនុប្រធានក្ដី គឺវានាំឲ្យសាធារណជននៅតែយល់បាន គាត់ជាអ្នកណា ហើយដោយសារចរិតលក្ខណៈពិសេសនេះ អង្គជំនុំជម្រះបានអនុញ្ញាតជាពិសេសកាលពីម្សិលមិញ។ អ៊ីចឹងសូមមេធាវីរៀបចំលើបញ្ហានេះ ពីព្រោះយើងអនុវត្តនូវអនុសញ្ញាអន្តរជាតិស្ដីពីកិច្ចការពារសាក្សីនៅចំពោះមុខតុលាការ ដរាបណាសាក្សីមិនទាន់ចូលខ្លួនមកដល់ចំពោះមុខតុលាការទេ គ្រប់ភាគីទាំងអស់ត្រូវតែប្រើនូវរហស្សនាមដែលអង្គជំនុំជម្រះបានរៀបចំ និងកំណត់រួចហើយ។

[១៥:៤៨:១៩]

ជាកិច្ចបន្តអង្គជំនុំជម្រះសូមសួរទៅសហព្រះរាជអាជ្ញា ដោយកម្រិតនៃការជំទាស់របស់មេធាវីការពារក្ដីចំពោះឯកសារ A2 នេះឃើញថា ក៏មានកម្រិតដែរ។ សួរថាតើសហព្រះរាជអាជ្ញារក្សាសិទ្ធិនៅក្នុងធ្វើអំណះអំណាងតបទៅនឹងការជំទាស់នេះដែរឬទេ? ហើយបើសិនជាធ្វើតើត្រូវចំណាយពេលវេលាប៉ុន្មាន? ដើម្បីអង្គជំនុំជម្រះពិនិត្យពិចារណាសម្រេចក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទជម្រាបសួរលោកប្រធាន។ យើងមានចេតនាចង់ឆ្លើយតប ប៉ុន្តែយើងនឹងប្រើរយៈពេល៤៥ នាទី ដែលអង្គជំនុំជម្រះផ្តល់ជូនមកឲ្យយើង ហើយបើអាចថាលើសពីរបីនាទីផងដែរ។

យើងចង់ធ្វើអន្តរាគមន៍នៅថ្ងៃស្អែក ព្រោះថាពេលឥឡូវនេះហាក់ដូចជាមិនសមស្របនោះទេ ដោយសារយើងមិនចង់បំបែកការនិយាយរបស់យើងជាពីរផ្នែក ហើយដោយសារថាយើងចង់បង្ហាញស្លាយផងដែរ។

[១៥:៤៩:៣៦]

អ៊ីចឹង ខ្ញុំគិតថានៅថ្ងៃនេះ យើងមិនមានពេលដើម្បីធ្វើកិច្ចការទាំងអស់នេះនោះទេ។

**ប្រធានអង្គជំនុំ៖**

អរគុណណាស់ ដោយសារមេធាវីការពារ អំសហព្រះរាជអាជ្ញាបានបង្ហាញជំហរយ៉ាងច្បាស់លាស់ហើយ ហើយត្រូវចំណាយពេលវេលាច្រើន។ ដូច្នេះអង្គជំនុំជម្រះមិនចាំបាច់សួរដល់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៀតទេ។ លើកលែងតែមានបញ្ហាផ្សេង។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកចៅក្រមប្រធាន គ្រាន់តែសុំបញ្ជាក់ជូនលោកប្រធានដូចករណីលើកមុន គឺសម្រាប់ករណីបញ្ហា A2 នេះ គឺមេធាវីនាំមុខសូមអនុញ្ញាតលោកប្រធានផ្ទេរសិទ្ធិជូនលោកមេធាវី វ៉ែន ពៅ នៅក្នុងការធ្វើបទអន្តរាគមន៍។ សូមអរគុណ។

[១៥:៥០:២៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតតាមការស្នើសុំ។

ឥឡូវនេះពេលវេលាសមល្មមនឹងផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះហើយ។ ហើយដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ហើយសវនាការនឹងលើកទៅបន្តធ្វើនៅព្រឹកថ្ងៃស្អែក ចាប់ពីវេលាម៉ោងប្រាំបួន។

ហើយអនុរក្សមន្ទីរឃុំឃាំង ឲ្យនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយស្អែក គឺឲ្យនាំខ្លួនគាត់ទាំងបីរូបត្រឡប់មកកាន់ទីកន្លែងសាលសវនាការនេះ។ ចំពោះជនជាប់ចោទ ខៀវ សំផន ហើយពីរនាក់ទៀត នួន ជា និង អៀង សារី គឺរក្សាទុកគាត់នៅបន្ទប់ខាងក្រោម ដែលមាន

ឧបករណ៍សោតទស្សន៍ឲ្យគាត់ទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ដូចដែលយើងបានធ្វើនៅថ្ងៃនេះ។

សូមអញ្ជើញសម្រាកចុះ៕

*(ចៅក្រមចាកចេញពីបន្ទប់សវនាការ)*

*(សវនាការផ្អាកនៅម៉ោង ១៥:៥១នាទី)*